# គោលការណ៍ណែនាំសម្រាប់ព្រះរាជអាជ្ញាអំពីបទឧក្រិដ្ឋកាកសំណល់

ការបរិច្ឆេទ៖ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០

ទម្រង់៖ ២.០

កញ្ចប់ការងារទី៤៖ ការបង្កើតបណ្តាញប្រតិបត្តិការអន្តរជាតិនៅក្នុងតំបន់អឺរ៉ុប អាស៊ីប៉ាស៊ីហ្វិក

លទ្ធផល៤.៣៖ គោលការណ៍ណែនាំស្តីអំពីការកាត់ទោសបទឧក្រិដ្ឋកាកសំណល់



## បុព្វកថា

គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើង ដោយមានកិច្ចសហការរវាងកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ(UNEP) និងសាកលវិទ្យាល័យ United National University (UNU) ក្រោមគម្រោងស្តីអំពី "ការទប់ស្កាត់និងការបញ្ឈប់ការធ្វើពាណិជ្ជកម្មនិងការគ្រប់គ្រងកាកសំណល់ដោយខុសច្បាប់ ដោយបានបង្កើតវិធានការអនុវត្តច្បាប់ ការធ្វើកោសល្យវិច័យ និងការកសាងសមត្ថភាព" (គម្រោង "WasteForce") ។ គម្រោង WasteForce ទទួលបានការឧបត្ថម្ភថវិការពីគណៈកម្មការអឺរ៉ុបរយៈពេល ២ ឆ្នាំ ហើយបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ ២០១៨ ។

គម្រោង WasteForceមានគោលបំណងបង្កើនសកម្មភាពប្រតិបត្តិការនិងសមត្ថភាពរបស់អាជ្ញាធរដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងការធ្វើពាណិជ្ជកម្មនិងការគ្រប់គ្រងកាកសំណល់ដោយខុសច្បាប់តាមរយៈ៖

- ការបង្កើតវិធីសាស្រ្តនិងវិធានការជាក់ស្តែងថ្មីៗ។
- ការពង្រឹងសកម្មភាពកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធចម្រុះ និង
- គាំទ្រចំពោះការបង្កើតបណ្តាញក្នុងចំណោមអ្នកជំនាញនៅអឺរ៉ុបនិងជាមួយដៃគូរបស់ពួកគាត់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ឯកសារគោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងសម្រាប់គម្រោង WasteForce ដោយលោក Matthew Baird (មកពីវិទ្យាស្ថានស្រាវជ្រាវអាស៊ីសម្រាប់ច្បាប់បរិស្ថាន), Amanda Cabrejo le Roux, Georgina Lloyd (UNEP) និង Elise Vermeersch, Susan van den Brink, Elena D'Angelo និង Vittoria Luda di Cortemiglia (UNU)។

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធឯកសារនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូរបស់គម្រោង WasteForce និងសិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការកាត់ទោសបទឧក្រិដ្ឋកាកសំណល់ ដែលត្រូវបានរៀបចំឡើងនៅ Lisbon ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ។ ឯកសារណែនាំនេះ ទទួលព័ត៌មានដែលប្រមូលបាននៅក្នុងកិច្ចប្រជុំប្រឹក្សាយោបល់ស៊ីជម្រៅ ដែលរៀបចំដោយអង្គការ UNEP នៅទីក្រុងបាងកកនៅខែធ្នូ ឆ្នាំ២០១៩ ដែលបានប្រមូលផ្តុំអ្នកចូលរួមចំនួន២១រូប ក្នុងនោះមានតំណាងព្រះរាជអាជ្ញា ស្ថាប័នបណ្តុះបណ្តាលផ្នែកច្បាប់ និង

ភ្នាក់ងារការពារបរិស្ថាន និងភ្នាក់ងារគយមកពី ៧ ប្រទេសក្នុងតំបន់ និងរួមមានតំណាងមកពីដៃគូជាអង្គការអន្តរជាតិផងដែរ។ អ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណដល់បណ្ដាញព្រះរាជអាជ្ញាដើម្បីបរិស្ថាននៃសហភាពអឺរ៉ុប (ENPE) និងជាពិសេសដល់លោក Rob de Rijck ដែលបានផ្ដល់ការព័ត៌មាននិងការគាំទ្រដ៏មានតម្លៃក្នុងការការបង្កើតគោលការណ៍ណែនាំនេះ។

## ការប្រកាសមិនទទួលខុសត្រូវ

ការរៀបចំនិងការធ្វើបទបង្ហាញនៃព័ត៌មានក្នុងឯកសារនេះ មិនបានឆ្លុះបញ្ចាំងនូវទស្សនៈនៃកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិទាក់ទងនឹងស្ថានភាពផ្នែកច្បាប់នៃប្រទេសណាមួយ ទីតាំង ក្រុង ឬតំបន់នៃដែនសមត្ថកិច្ចរបស់ប្រទេសនោះឡើយ ឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់ណាមួយឡើយ។ លើសពីនេះ ទស្សនៈនានានៅក្នុងឯកសារនេះមិនចាំបាច់ត្រូវតែតំណាងឱ្យសេចក្ដីសម្រេចឬគោលនយោបាយដែលបានចែងរបស់កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ សាកលវិទ្យាល័យ United Nations University គណៈកម្មការអឺរ៉ុប ឬដៃគូរបស់គម្រោង WasteForceណាមួយ ហើយការដកស្រង់នូវឈ្មោះឬដំណើររបស់ពាណិជ្ជកម្មណាមួយក៏មិនបានឡើយ ។

# តារាងមាតិកា


សេចក្តីផ្តើម ..................................................................................... 5

១. ព័ត៌មានទូទៅអំពីបទឧក្រិដ្ឋកាកសំណល់និងបរិស្ថាន ..................................... 5

២. វិសាលភាពនៃគោលការណ៍ណែនាំនេះ ................................................... 8

៣. ប្រភេទនៃឧក្រិដ្ឋកម្មបរិស្ថាន ............................................................ 10

៤. គោលការណ៍នៃច្បាប់បរិស្ថាន ............................................................. 13

គោលការណ៍អ្នកបំពុលបរិស្ថានត្រូវទទួលខុសត្រូវចំពោះការចំណាយ .................... 13

គោលការណ៍ការពារប្រសើរជាងព្យាបាល ...................................................... 14

គោលការណ៍អធិបតេយ្យភាពអចិន្ត្រៃលើធនធានធម្មជាតិ និងតួនាទីដែលមិនធ្វើឲ្យប៉ះពាល់បរិស្ថានឆ្លងដែន ............................................................................. 14

គោលការណ៍នៃការចាត់វិធានការទប់ស្កាត់ ................................................... 15

គោលការណ៍នៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ ........................................ 15

គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព ............................................... 15

១.១ យន្តការអន្តរជាតិ ............................................................................ 16

១.២ ការយល់ព្រមដោយបានជូនដំណឹងជាមុនក្រោមសន្និបាត Basel ............................ 20

១.៣ និយមន័យនៃការចរាចរណ៍កាកសំណល់ដោយខុសច្បាប់ ...................................... 21

១.៤ នីតិវិធីបញ្ជូនកាកសំណល់ត្រឡប់ទៅវិញ ....................................................... 22

១.៥ ក្របខណ្ឌច្បាប់ជាតិ ............................................................................ 23

ជំពូក ២ ការចោទប្រកាន់ និងគោលនយោបាយក្នុងការអនុវត្តច្បាប់ ..................... 24

២.១ គោលនយោបាយក្នុងការអនុវត្តច្បាប់បរិស្ថាន ................................................ 24

២.២ នីតិវិធីសម្រាប់បទល្មើស ...................................................................... 26

២.៥ ជម្រើសនៃនីតិវិធីនានា .......................................................................... 30

ជំពូក ៣ ការស៊ើបអង្កេត និងការប្រមូលភស្តុតាង ............................................. 32

៣.១ ការស៊ើបអង្កេត ................................................................................. 32

៣.២ ការប្រមូលភស្តុតាង ........ 35
៣.៣ ការការពារភស្តុតាង ........ 38
៣.៤ ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ........ 38
៣.៥ បញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា ........ 39
**ជំពូក ៤ ទំនួលខុសត្រូវចំពោះមុខច្បាប់ ........ 42**
៤.១ ការកំណត់រកអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មកាកសំណល់ ........ 42
៤.១.១ ទំនួលខុសត្រូវមុខច្បាប់របស់ក្រុមហ៊ុនសាជីវកម្ម នាយក និងបុគ្គលនានា ........ 43
៤.២ អំពើពុករលួយ និងបទឧក្រិដ្ឋកាកសំណល់ ........ 50
៤.២ ក្រុមអង្គការចាត់តាំងឧក្រិដ្ឋកម្ម ........ 51
**ជំពូក ៥ ការផ្តន្ទាទោស និងការរៀបចំរបាយការណ៍ ........ 52**
៥.១ ការផ្តន្ទាទោសចំពោះសំណុំរឿងកាកសំណល់ ........ 52
៥.២ ការផ្តន្ទាទោសចាំបាច់នានា ........ 54
៥.៣ ការរាយការណ៍និងការត្រួតពិនិត្យ ........ 55
**ឧបសម្ព័ន្ធ ........ 57**
ឧបសម្ព័ន្ធ ១ – យន្តការអន្តរជាតិ ........ 57
ឧបសម្ព័ន្ធ ២ – និយមន័យនានា ក្រោមសន្និបាត Basel ........ 58
ឧបសម្ព័ន្ធ ៣ – ក្របខណ្ឌច្បាប់កាកសំណល់របស់សហភាពអឺរ៉ុប ........ 61
ឧបសម្ព័ន្ធ ៤ – ច្បាប់ស្តីពីកាកសំណល់ តាមបណ្តាប្រទេសក្នុងសហភាពអឺរ៉ុប និងអាស៊ីអាគ្នេយ៍ 72
ឧបសម្ព័ន្ធ ៥ – ករណីសិក្សា ........ 77
ឧបសម្ព័ន្ធ ៦ – ការធ្វើសំណាកគំរូ និងការវិភាគសំណាកគំរូ ........ 79
**ឯកសារយោង និងឯកសារណែនាំ ........ 84**

# សេចក្តីផ្តើម

## ១. ព័ត៌មានទូទៅអំពីបទឧក្រិដ្ឋកាកសំណល់និងបរិស្ថាន

មិនមាននិយមន័យច្បាប់ណាមួយនៃឧក្រិដ្ឋកម្មបរិស្ថានដែលគេទទួលស្គាល់ជាសកលឡើយ។ ឧក្រិដ្ឋកម្មបរិស្ថាន ត្រូវបានគេឲ្យនិយមន័យថាជា "ទង្វើ *ដែលគេមិនអនុញ្ញាត ឬជាការខកខានណាមួយដែលរំលោភបំពានច្បាប់ ហើយដូច្នេះហើយទើបត្រូវទទួលទោសព្រហ្មទណ្ឌ និងទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។ បទល្មើសនេះ ធ្វើឱ្យមានគ្រោះឬប៉ះពាល់ដល់សុវត្ថិភាពឬសុខភាពរាងកាយរបស់មនុស្សក៏ដូចជាបរិស្ថានផងដែរ។ ឧក្រិដ្ឋកម្មនេះបម្រើផលប្រយោជន៍ឲ្យស្ថាប័ននានា ជាទូទៅជាក្រុមហ៊ុនសាជីវកម្ម ឬបុគ្គលណាម្នាក់* (Situ and Emmons, 2010)"។ មនុស្សមួយចំនួនផ្សេងទៀត មានទស្សនៈថាឧក្រិដ្ឋកម្មបរិស្ថាន "*ជាទង្វើប្រព្រឹត្តដោយមានចេតនាបង្កគ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូស៊ី និង/ឬប្រព័ន្ធជីវសាស្ត្រ និងដើម្បីរក្សាស្ថេរភាពអាជីវកម្មឬផលប្រយោជន៍ផ្ទាល់ខ្លួន។*" (Bricknell 2010)។

ចុងក្រោយ លោក Bricknell បានសង្កេតឃើញថា៖

> *ការទទួលស្គាល់និងការទទួលយកឧក្រិដ្ឋកម្មបរិស្ថានជាបទល្មើសព្រហ្មទណ្ឌពិតប្រាកដ (ឬថាជាប្រភេទបទល្មើសផ្សេងៗទៀត) ប្រហែលជាមានបញ្ហាច្រើនជាងប្រភេទឧក្រិដ្ឋកម្មដទៃទៀត។ ជាធម្មតាការប្រព្រឹត្តលើបរិស្ថាន មិនត្រូវបានគេមើលឃើញថាមានភាពខុសគ្នាផ្នែកសីលធម៌ដូចនឹងបទល្មើសប្រព្រឹត្តិមកលើមនុស្សឬទ្រព្យសម្បត្តិទេ។ ក្នុងកម្រិតខ្លះ រឿងនេះ ឆ្លុះបញ្ចាំងពីតថភាពនៃអាយុកាលដែលគេ ប្រព្រឹត្តបទល្មើសនេះ ប្រព្រឹត្តដោយនរណា និងក្រោមហេតុផលអ្វី។ ជាមួយនឹងកំណើននៃការយល់ដឹងនិងការឲ្យតម្លៃចំពោះបរិស្ថាន វា បានធ្វើឲ្យមានការវាយតម្លៃឡើងវិញនូវអ្វីដែលបរិស្ថានអាចនិងមិនអាចបន្តនិរន្តរភាពបាន ហើយវា ធ្វើឲ្យមានការទទួលស្គាល់ពីតំរូវការក្នុងការបង្កើតបទប្បញ្ញត្តិ ហើយក្នុងករណីខ្លះ តម្រូវឲ្យមានការកាត់ទោសព្រហ្មទណ្ឌចំពោះការអនុវត្តនានាដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន* (Bricknell 2010) ។

អង្គការ UNEP និង INTERPOL បានកំណត់នូវនិយមន័យការងារនៃឧក្រិដ្ឋកម្មបរិស្ថានដែលរួមបញ្ចូលនូវទង្វើខុសច្បាប់ឬការខកខានណាមួយដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន ដើម្បីទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុនិងប្រយោជន៍ផ្ទាល់ខ្លួន។ ឧក្រិដ្ឋកម្មបរិស្ថាន អាចត្រូវបានគេយល់ថាជា "*ពាក្យរួមមួយ ដើម្បីពិពណ៌នាអំពីទង្វើខុសច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាននិងដើម្បីផលប្រយោជន៍របស់បុគ្គល ឬក្រុម ឬក្រុមហ៊ុននានា តាមរយៈការកេងប្រវ័ញ្ច ការធ្វើឱ្យខូចខាត ការធ្វើពាណិជ្ជកម្ម ឬការលួចធនធានធម្មជាតិ ក្នុងនោះរួមទាំងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំងផងដែរ។*" (UNEP / INTERPOL 2016, p. 7) ។

ខណៈពេលដែលនិយមន័យនេះរួមបញ្ចូលការខកខានណាមួយ ឬទង្វើខុសច្បាប់ណាមួយដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន ឧក្រិដ្ឋកម្មបរិស្ថាននិងជាពិសេសបទឧក្រិដ្ឋកាកសំណល់ ក៏រួមបញ្ចូលផងដែរនូវការបំពានច្បាប់បរិស្ថានដែលមិនបង្កឱ្យមានគ្រោះថ្នាក់(ភ្លាមៗ)ដល់បរិស្ថាន ។ ជាឧទាហរណ៍ ការចាត់ចំណាត់ថ្នាក់មិនត្រឹមត្រូវចំពោះការនាំចេញកាកសំណល់ មិនបង្កគ្រោះថ្នាក់(ដោយផ្ទាល់) ដល់បរិស្ថានទេ ប៉ុន្តវា ជាការបំពានច្បាប់ដែលមានគោលបំណងការពារបរិស្ថាន ហើយដូច្នេះវា នៅតែជាបទឧក្រិដ្ឋកដដែល។

ដូចជាទម្រង់ផ្សេងទៀតនៃបទឧក្រិដ្ឋកពាណិជ្ជកម្មដែរ កត្តាចម្បងជំរុញឲ្យមានឧក្រិដ្ឋកម្មបរិស្ថាន គឺការទទួលបានផលចំណេញផ្ទាល់ខ្លួន។ គេ ទទួលបានផលចំណេញទាំងនេះដោយផ្ទាល់មិនត្រឹមតែតាមរយៈអត្ថប្រយោជន៍ដែលទទួលបានពីទង្វើណាមួយជាក់លាក់ទេ ប៉ុន្តែក៏តាមរយៈធនធានដែលគេសន្សំទុកដោយមិនអើពើពីការធ្វើតាមបទដ្ឋានដែលកំណត់ពីរបៀបអនុវត្តការងារទាំងនេះផងដែរ។ មនុស្សផ្សេងទៀត បានបញ្ចេញទស្សនៈថា "ភាពលោភលន់" និង"ការព្រងើយកន្តើយ" គឺជាមូលដ្ឋានគ្រឹះនៃឧក្រិដ្ឋកម្មបរិស្ថាន។ សម្រាប់សហគ្រាសអាជីវកម្មមួយចំនួនដូចជាអាជីវកម្មកាប់ឈើ គេ ចូលចិត្តអនុវត្តវិធីខុសច្បាប់ ព្រោះវា អាចរកចំណូលបានច្រើនជាងវិធីស្របច្បាប់ ( UNEP 2018, UNEP / INTERPOL 2016 ) ។

ភាពទាក់ទាញនៃប្រាក់ចំណេញខុសច្បាប់ទាំងនេះ កាន់តែកើនឡើង ដោយសារការវិនិយោគក្នុងកម្រិតតិចតួចបំផុតដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មបរិស្ថាន និងវា មានហានិភ័យទាបនៃការដែលត្រូវគេចាប់បាននិងចោទប្រកាន់។ ទម្រង់ជាច្រើននៃឧក្រិដ្ឋកម្មបរិស្ថាន មិនងាយត្រូវបានគេសង្កេតឃើញឬរកឃើញទេ ដោយហេតុថា វា មិនបង្កផលប៉ះពាល់ជាក់ស្តែង និងវា មិនស្ថិតក្រោមរ៉ាដារបស់ភ្នាក់ងារអនុវត្តច្បាប់គ្រប់ពេលវេលាឡើយ។ ចន្លោះប្រហោងនិងភាពទន់ខ្សោយផ្នែកបទប្បញ្ញត្តិ កង្វះឆន្ទៈនយោបាយក្នុងការបង្ក្រាបឧក្រិដ្ឋកម្មទាំងនោះ ផ្គួបផ្សំជាមួយភាពអសមត្ថភាពឬអំពើពុករលួយរបស់មន្ត្រីស៊ើបអង្កេត ពេលខ្លះអាចទាំងកាត់បន្ថយឱកាសនៃការរកឃើញឧក្រិដ្ឋកម្មនេះ ហើយព្រមទាំងជួយឲ្យទង្វើនៃឧក្រិដ្ឋកម្មនេះ នៅតែបន្តកើតឡើងផងដែរ (UNEP / INTERPOL 2016 ) ។

ការកើនឡើងនៃឧក្រិដ្ឋកម្មបរិស្ថាន ត្រូវបានគេទទួលស្គាល់ថាជារឿងគ្រោះថ្នាក់មួយក្នុងចំណោមរឿងដែលមានគ្រោះថ្នាក់បំផុតចំពោះបរិស្ថានសព្វថ្ងៃ។ ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងការការពារបរិស្ថាននិងការគ្រប់គ្រងកាកសំណល់ មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍនីតិរដ្ឋបរិស្ថានមួយដ៏រឹងមាំ។ ( UNEP 2019 )

ការកាត់ទោសឧក្រិដ្ឋកម្មបរិស្ថាន មានសារៈសំខាន់ដូចគ្នានឹងការកាត់ទោសឧក្រិដ្ឋកម្មដទៃទៀតដែរ។ ការកាត់ទោសនេះ មិនត្រឹមតែលើកកម្ពស់ការគោរពច្បាប់ប៉ុណ្ណោះទេ តែថែមទាំងមិនជំរុញឲ្យមានការរំលោភច្បាប់ផងដែរ។ ផលប៉ះពាល់នៃឧក្រិដ្ឋកម្មបរិស្ថានមិនត្រឹមតែ ប៉ះពាល់ដល់សុខភាពមនុស្សនិងបំផ្លាញបរិស្ថានប៉ុណ្ណោះទេ។ ឧក្រិដ្ឋកម្មសេដ្ឋកិច្ចដែលនាំឲ្យមានគ្រោះថ្នាក់ដល់សេដ្ឋកិច្ច ជាទូទៅផ្សារភ្ជាប់ជាមួយនឹងឧក្រិដ្ឋកម្មបរិស្ថាន។ អង្គការ INTERPOL បានសន្និដ្ឋានថាភស្តុតាងដំបូង ផ្សារភ្ជាប់ឧក្រិដ្ឋកម្មបំពុលបរិស្ថានទៅនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ហើយក្នុងករណីខ្លះគេ រកឃើញថាវាមានទំនាក់ទំនងទៅនឹងភេរវកម្ម។ ( INTERPOL 2006 )។

អង្គការ INTERPOL បានសង្កត់ធ្ងន់បន្ថែមទៀតពីសារៈសំខាន់នៃការកាត់ទោសឧក្រិដ្ឋកម្មបរិស្ថាននៅក្នុងអនុស្សរណៈតស៊ូមតិនៅឆ្នាំ ២០០៧ ដែលបានចែងថា៖ "ផលប៉ះពាល់ដ៏ធំធេងនៃឧក្រិដ្ឋកម្មបរិស្ថាន បង្ហាញពីសារៈសំខាន់នៃការផ្តន្ទាទោសឲ្យសក្តិសមចំពោះឧក្រិដ្ឋកម្មបែបនេះ។ ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មបរិស្ថានប្រកបដោយប្រសិទ្ធភាព ការកាត់ទោសដែលរួមបញ្ចូលទោសជាប់ពន្ធនាគារនិងការផាកពិន័យជាប្រាក់ ត្រូវតែលើសពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលជនជាប់ចោទទទួលបានពីទង្វើមិនគោរពតាមច្បាប់របស់គេ។ ការកាត់ទោស ត្រូវតែមានកម្រិតខ្ពស់សមល្មម ដើម្បីយ៉ាងហោចណាស់អាចទូទាត់នឹងការចំណាយលើការកាត់បន្ថយការខូចខាតដែលគេបានបង្កឡើង"(INTERPOL 2007)។

បទឧក្រិដ្ឋកាកសំណល់ដែលជាប្រភេទមួយនៃឧក្រិដ្ឋកម្មបរិស្ថាន បង្ហាញពីបញ្ហាប្រឈមផ្នែកបរិស្ថាននិងផ្នែកច្បាប់ ស្របពេលដែលកំណើនពាណិជ្ជកម្មកាកសំណល់ស្របច្បាប់ ត្រូវបានឆ្លុះបញ្ចាំងដោយកំណើនពាណិជ្ជកម្មកាកសំណល់ខុសច្បាប់។ វិស័យកាកសំណល់ក្នុងសកលលោក មានទម្រង់ជាច្រើន។ ទម្រង់ទីមួយ ជាទម្រង់ឧស្សាហកម្មស្របច្បាប់ដែលមាននិន្នាការភាពចំពោះអាជីវកម្មនិងការការពារបរិស្ថាន ទម្រង់ទី២ ជាទម្រង់អាជីវកម្មក្រៅប្រព័ន្ធដែលមានសារៈសំខាន់សម្រាប់ការកែច្នៃហើយបង្កើតការងារផងដែរ ពេលខ្លះអាជីវកម្មប្រភេទនេះ មិនត្រូវបានគេធ្វើបទប្បញ្ញត្តិទេ វា នាំមកនូវហានិភ័យដល់សុខភាពនិងបង្កជាបញ្ហាប្រឈមក្នុងការត្រួតពិនិត្យសុវត្ថិភាពនិងការគ្រប់គ្រងគ្រប់ជ្រុងជ្រោយ និងទម្រង់ទីបី ជាទម្រង់នៃការជួញដូរសារធាតុគីមីនិងកាកសំណល់ដែលមានគ្រោះថ្នាក់ ធ្វើឡើងដោយអង្គការតាំងឧក្រិដ្ឋកម្ម។ (UNEP/INTERPOL p.62)។

ការចល័តកាកសំណល់និងសារធាតុគីមីឆ្លងដែនខុសច្បាប់ គឺជាក្តីបញ្ហាបរិស្ថានដែលកំពុងកើនឡើងនៅទូទាំងពិភពលោក។ កាកសំណល់គ្រោះថ្នាក់និងកាកសំណល់តាមផ្ទះជាង ២០០ លានតោនត្រូវបានបង្កើតឡើងនៅទូទាំងពិភពលោកជារៀងរាល់ឆ្នាំ ដែលក្នុងនោះយ៉ាងហោចណាស់ ៩.៣ លានតោន ធ្វើដំណើរឆ្លងកាត់ព្រំដែនប្រទេសនានាជារៀងរាល់ឆ្នាំ។ ការចំណាយខ្ពស់ក្នុងការលាងម្អាតនិងបោះចោលកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងៗទៀត រួមជាមួយភាពទន់ខ្សោយនៃច្បាប់បរិស្ថាន និងការអនុវត្តច្បាប់បរិស្ថាន កង្វះចំណេះដឹងអំពីបរិស្ថាន បានធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក្លាយជាគោលដៅនៃការដឹកជញ្ជូនសារធាតុគីមី និងកាកសំណល់ខុសច្បាប់ដែលបង្កគ្រោះថ្នាក់ដល់សុខភាពនិងបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ (UNEP 2015)។

ការជួញដូរកាកសំណល់ ភាគច្រើនមានប្រភពដើមនៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍ដែលរួមមានសហភាពអឺរ៉ុប អាមេរិកខាងជើង (អាមេរិកនិងកាណាដា) ជប៉ុន និងអូស្ត្រាលី ដែលជាទូទៅត្រូវបានគេស្គាល់ថាជាអ្នកនាំចេញកាកសំណល់ខុសច្បាប់។ ប្រទេសគោលដៅចម្បងសម្រាប់ការជួញដូរកាកសំណល់ខុសច្បាប់ គឺនៅអាស៊ី (ឥណ្ឌូនេស៊ី ឥណ្ឌា ម៉ាឡេស៊ី ប៉ាគីស្ថាន និងវៀតណាម) ។ ផ្លូវសម្រាប់ពាណិជ្ជកម្មកាកសំណល់ខុសច្បាប់អាស្រ័យលើប្រភេទនៃកាកសំណល់ដែលជាទូទៅជាកាកសំណល់អេឡិចត្រូនិចដែលត្រូវបានដឹកជញ្ជូនទៅកាន់អាស៊ីអាគ្នេយ៍ រីឯគ្រឿងបន្លាស់រថយន្តនិងយានជំនិះហួសសម័យ ត្រូវបានដឹកទៅកាន់ទ្វីបអឺរ៉ុបខាងកើតនិងអាហ្វ្រិក ហើយកាកសំណល់ផ្លាស្ទិច ត្រូវបានដឹកទៅកាន់ទ្វីបអាស៊ី (DOTCOM Waste Project, 2017a, UNEP 2019)។

កត្តាជំរុញនិងការលើកទឹកចិត្តឲ្យមានការធ្វើពាណិជ្ជកម្មកាកសំណល់ និងការបោះចោលកាកសំណល់និងសារធាតុគីមីដែលមានគ្រោះថ្នាក់ដោយខុសច្បាប់ រួមមានប្រាក់ចំណេញ ប្រព័ន្ធអនុវត្តច្បាប់មានភាពទន់ខ្សោយ ភាពស្មុគស្មាញនៃវិធាននានា និងតួអង្គផ្សេងៗដែលពាក់ព័ន្ធនឹងសារធាតុគីមីជាសកលនិងខ្សែសង្វាក់ពាណិជ្ជកម្មកាកសំណល់ (Basel 2017, p.10-11)។ ការធ្វើពាណិជ្ជកម្មបែបនេះ ភាគច្រើនជំរុញទឹកចិត្តដោយការផ្គត់ផ្គង់ទី១ ដោយសារអ្នកផលិតកាកសំណល់ចង់ចៀសវាងការចំណាយច្រើនលើការបោះចោលកាកសំណល់ និងទី ២ គឺដោយសារផលប្រាក់ចំណេញពីសំណាក់ឈ្មួញកណ្ដាលដែលដួញដូរកាកសំណល់និងជាអ្នកទទួលបានប្រាក់ពីអ្នកផលិតកាកសំណល់និងពីអ្នកទិញដែលចង់យកកាកសំណល់ទៅកែច្នៃឬជួសជុល ។ គេ បានលើកឡើងថាការកើនឡើងនៃការចំណាយលើការបោះចោលកាកសំណល់ដោយស្របច្បាប់និងដោយមានសុវត្ថិភាព បានចូលរួមចំណែកធ្វើឲ្យមានការបង្កើតជាពាណិជ្ជកម្មនាំចេញកាកសំណល់ទៅកាន់ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបំផុតនៅលើពិភពលោក ដោយគេ គេងប្រវ័ញ្ចលើចន្លោះប្រហោងឬភាពទន់ខ្សោយនៃក្របខ័ណ្ឌបទប្បញ្ញត្តិស្ដីពីពាណិជ្ជកម្មកាកសំណល់និងការបោះចោលកាកសំណល់។ ជាទូទៅគេ ជឿថាការនាំចូលកាកសំណល់ខុសច្បាប់ឆ្លងកាត់ព្រំដែនប្រទេសនានា មានលក្ខណៈងាយស្រួល ជាពិសេសប្រទេសដែលមានប្រព័ន្ធត្រួតពិនិត្យទន់ខ្សោយឬមិនមានប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ (UNEP 2018 Crimes)។

## ២. វិសាលភាពនៃគោលការណ៍ណែនាំនេះ

មន្ត្រីអនុវត្តច្បាប់ស្ដីពីបទឧក្រិដ្ឋកាកសំណល់ដែលរួមមានមន្ត្រីគយ ប៉ូលីស អធិការបរិស្ថាន និងព្រះរាជអាជ្ញា ដើរតួនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់និងត្រួតពិនិត្យលើពាណិជ្ជកម្មសារធាតុគីមីនិងកាកសំណល់ខុសច្បាប់ ដោយធានាឱ្យមានការអនុវត្តច្បាប់បរិស្ថានជាតិប្រកបដោយប្រសិទ្ធភាពនិងអនុលោមតាមការប្ដេជ្ញាថ្នាក់ជាតិចំពោះកិច្ចព្រមព្រៀងបរិស្ថានពហុភាគី។ អង្គការ UNEP បានបង្កើតសៀវភៅណែនាំមួយដើម្បីជួយដល់មន្ត្រីអនុវត្តច្បាប់ក្នុងការតាមរក ត្រួតពិនិត្យ និងកំណត់អត្តសញ្ញាណសារធាតុគីមីនិងកាកសំណល់ដែលត្រូវបានធ្វើបទប្បញ្ញត្តិដោយកិច្ចព្រមព្រៀងបរិស្ថានពហុភាគី និងដោយច្បាប់ជាតិ។ (UNEP 2015, p10)

គោលការណ៍ណែនាំនេះ មានគោលបំណងផ្ដល់ការណែនាំនិងព័ត៌មានជាក់ស្ដែងសម្រាប់អាជ្ញាធរដែលពាក់ព័ន្ធនឹងការកាត់ទោសសំណុំរឿងចរាចរណ៍កាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតដោយខុសច្បាប់។ ខណៈដែលវិសាលភាពនៃពាណិជ្ជកម្មកាកសំណល់ឆ្លងកាត់ព្រំដែនខុសច្បាប់ ផ្ដោតលើនៃគោលការណ៍ណែនាំនេះ វា ក៏មានគោលបំណងផ្ដល់នូវការណែនាំនានាក្នុងការកាត់ទោសបទឧក្រិដ្ឋកាកសំណល់ជាទូទៅផងដែរ។ ដោយហេតុថាអ្នកចាប់អារម្មណ៍សំខាន់ចំពោះការណែនាំនេះគឺជាព្រះរាជអាជ្ញានៃបទឧក្រិដ្ឋកាកសំណល់ គោលការណ៍ណែនាំនេះ ក៏គួរតែមានប្រយោជន៍សម្រាប់មន្ត្រីគយ មន្ត្រីស៊ើបអង្កេត និងក្រសួងពាក់ព័ន្ធដែលចូលរួមក្នុងការកាត់ទោសនានាទាក់ទងនឹងកាកសំណល់។

ដូចដែលបានរៀបរាប់ពីមុនៈ

> *"កម្មវត្ថុចុងក្រោយនៅពេលកាត់ទោសសំណុំរឿងចរាចរណ៍ខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងទៀត គឺដើម្បីការពារសហគមន៍និងបរិស្ថានពីផលវិបាកនានាដែលបង្កឡើងដោយការបោះចោលនិងការចល័តឆ្លងដែននូវកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ដទៃទៀតដែលមិនបានគ្រប់គ្រងត្រឹមត្រូវ ដោយផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មបែបនេះដើម្បីឲ្យមានការខ្លាចរអា។"* ( Basel 2012, p.7 )

គោលការណ៍ណែនាំនេះ មិនមានបំណងចម្លងឯកសារដែលមានស្រាប់ផ្សេងជាយថហេតុនោះឡើយ ទោះបីជាឯកសារនេះ ត្រូវបានគេរៀបរៀងឡើងជាឯកសារឯករាជ្យតែឯងក៏ដោយ។ អ្នកនិពន្ធ ក៏មានបំណងផ្សាភ្ជាប់ឯកសារនេះជាមួយឯកសារដែលមានស្រាប់និងឯកសារបណ្តុះបណ្តាលតាមអនឡាញនាពេលអនាគតផងដែរ។ ឯកសារយោង នឹងត្រូវបានរៀបចំឡើងដោយមានឯកសារផ្សេងៗទៀតដែលនឹងផ្តល់ជំនួយដល់កាត់ទោសបទឧក្រិដ្ឋកាកសំណល់និងឧក្រិដ្ឋកម្មបរិស្ថាននានា។ ជាពិសេសលេខាធិការដ្ឋាននៃសន្និបាតBasel បានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១២ នូវ "សៀវភៅណែនាំស្តីពីការកាត់ទោសចំពោះចរាចរណ៍ខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ( *Instruction manual on the prosecution of illegal traffic of hazardous wastes or other wastes*)" ដែលផ្តល់នូវការស្វែងយល់អំពីការអនុវត្តការកាត់ទោសសំណុំរឿងចរាចរណ៍ខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតក្នុងវិសាលភាពនៃសន្និបាតBasel។ គោលការណ៍ណែនាំនាពេលបច្ចុប្បន្ន បំពេញបន្ថែមនិងបញ្ចូលក្នុងសៀវភៅណែនាំរបស់លេខាធិការដ្ឋាន ដោយផ្តល់ព័ត៌មានបច្ចុប្បន្នភាពថ្មីៗ ព័ត៌មានជាក់លាក់ស្តីពីការអនុវត្តការកាត់ទោសនៅសហភាពអឺរ៉ុបនិងនៅអាស៊ីអាគ្នេយ៍ និងស្តីអំពីការស៊ើបអង្កេតនិងការប្រមូលភស្តុតាងផងដែរ។

សម្រាប់គោលបំណងនៃការណែនាំនេះ "ការអនុវត្តច្បាប់" ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

> *បណ្តុំនៃនីតិវិធីនិងវិធានការនានាដែលបានប្រើដោយរដ្ឋមួយ អាជ្ញាធរមានសមត្ថកិច្ច និងទីភ្នាក់ងាររដ្ឋនោះ ដើម្បីធានាថាស្ថាប័នឬបុគ្គលនានាដែលអាចនឹងខកខានមិនបានគោរពតាមច្បាប់ឬបទប្បញ្ញត្តិបរិស្ថាន អាចធ្វើឲ្យឬត្រឡប់មកអនុលោមតាមច្បាប់ និង/ឬទទួលការផ្តន្ទាទោសតាមវិធានការផ្នែករដ្ឋប្បវេណី រដ្ឋបាល ឬព្រហ្មទណ្ឌ។*

ផ្ទុយទៅវិញ "ការអនុលោមតាមច្បាប់" អាចត្រូវបានកំណត់និយមន័យថា៖

> *ស្ថានភាពនៃការអនុលោមតាមកាតព្វកិច្ចដែលបានកំណត់ដោយរដ្ឋមួយ អាជ្ញាធរមានសមត្ថកិច្ច និងភ្នាក់ងាររបស់រដ្ឋនោះ នៅក្នុងសហគមន៍ដែលត្រូវបានគេធ្វើនិយតកម្ម មិនថាដោយផ្ទាល់ឬតាមរយៈលក្ខខណ្ឌនិងតម្រូវការជាលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធអំណាចក្តី។* ( UNEP 2014 )

សេក្តីណែនាំនេះ មានប្រាំជំពូក។ បន្ទាប់ពីសេចក្តីផ្តើម ជំពូក២ ផ្តល់នូវទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌគតិយុត្តិ។ ជំពូក ៣ ពិភាក្សាអំពីទស្សនៈនានានៃគោលនយោបាយអនុវត្តច្បាប់បរិស្ថាននិងនីតិវិធីសម្រាប់បទល្មើស។ នីតិវិធីសម្រាប់បទល្មើស ត្រូវបានបែងចែកជានីតិវិធីរដ្ឋបាល នីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌ។ ជំពូកទី ៣ ផ្តោតលើការស៊ើបអង្កេតនិងការប្រមូលភស្តុតាង ហើយរួមមានព័ត៌មានអំពីការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ និង

បញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា។ ជំពូក ៤ ទាក់ទងនឹងការកំណត់ការទទួលខុសត្រូវមុខច្បាប់ចំពោះបទល្មើសកាកសំណល់។ ជំពូក ៥ ពិនិត្យមើលការកាត់ទោសនិងការរៀបចំរបាយការណ៍។ នៅចុងបញ្ចប់ នៅក្នុងផ្នែកឧបសម្ព័ន្ធ លោកអ្នកអាចរកឃើញនូវព័ត៌មានបន្ថែម អំពីយន្តការអន្តរជាតិនានា(ឧបសម្ព័ន្ធ ១) និយមន័យក្រោមសន្និបាត Basel(ឧបសម្ព័ន្ធ ២) ក្របខ័ណ្ឌគតិយុត្តស្តីអំពីកាកសំណល់អឺរ៉ុប(ឧបសម្ព័ន្ធ ៣) ច្បាប់ស្តីអំពីកាកសំណល់តាមប្រទេសនីមួយៗ(ឧបសម្ព័ន្ធ ៤) ករណីសិក្សា(ឧបសម្ព័ន្ធ ៥ ) និងការធ្វើសំណាកគំរូនិងការវិភាគសំណាកគំរូ(ឧបសម្ព័ន្ធ ៦)។

## ៣. ប្រភេទនៃឧក្រិដ្ឋកម្មបរិស្ថាន

បទឧក្រិដ្ឋកាកសំណល់ អាចបណ្តាលមកពីទង្វើឬការខកខាននានាដែលបង្កអន្តរាយដល់បរិស្ថាន ឬការគេចវេសមិនប្រើវិធានការណ៍ការពារ ហើយបទឧក្រិដ្ឋកាកសំណល់ មានច្រើនទម្រង់ដែលជាទូទៅធ្លាក់ចូលទៅក្នុងបទឧក្រិដ្ឋមួយឬច្រើនក្នុងចំណោមបទឧក្រិដ្ឋទាំង ៦ ប្រភេទ ដែលរួមមាន៖(Eunomia, ESEAT, 2017)

- កន្លែងចាក់ចោលកាកសំណល់ដោយខុសច្បាប់(ដែលប្រហែលជាដំណើរការក្នុងរយៈពេលខ្លី ឬយូរ)។
- ការដុតកាកសំណល់ដោយខុសច្បាប់
- ការចាក់ចោលកាកសំណល់ដោយខុសច្បាប់
- ការធ្វើចំណាត់ថ្នាក់ខុសនិងការក្លែងបន្លំ
- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើលក្ខខណ្ឌនៃលិខិតអនុញ្ញាត រួមមានការទុកកាកសំណល់ចោល និង
- ការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ (នាំចូល នាំចេញ និងឆ្លងកាត់)។

លើសពីនេះ វា អាចមានទំនាក់ទំនងគ្នាជាមួយប្រភេទបទឧក្រិដ្ឋផ្សេងទៀត ដូចជាអំពើពុករលួយ និងការលាងលុយកខ្វក់។

### កន្លែងចាក់កាកសំណល់ដោយខុសច្បាប់

កន្លែងដែលគ្រប់គ្រងកាកសំណល់ ដោយគ្មានលិខិតអនុញ្ញាតផ្នែកបរិស្ថានឬសិទ្ធិពិសេសដែលបានចុះបញ្ជី គឺជាកន្លែងខុសច្បាប់។ ប្រសិនបើមិនមានការត្រួតពិនិត្យចាំបាច់ណាមួយក្នុងការគ្រប់គ្រងកាកសំណល់ប្រកបដោយសុវត្ថិភាពនោះទេ កន្លែងទាំងនោះ មានអាចនឹងបង្កការខូចខាតដល់បរិស្ថាននិងសុខភាពមនុស្ស។ គិតជាគោល កន្លែងកាកសំណល់ខុសច្បាប់ ជាទូទៅទទួលកាកសំណល់សំណង់និងកាកសំណល់ពីការកំទេចអាគារនានា ប៉ុន្តែគេ ប្រហែលជាចាត់ចែងកាកសំណល់ជាច្រើនផ្សេងៗទៀត

ផងដែរ។ កន្លែងកាកសំណល់ អាចមានប្រភេទផ្សេងៗចាប់ពីកន្លែងចាក់កាកសំណល់ធំៗដែលលុបបំពេញដោយដី រហូតដល់កន្លែងផ្ទុកសំបកកង់នៅក្នុងឃ្លាំងឬកន្លែងទុករថយន្ត(Eunomia, 2017, p.7)។ កន្លែងកាកសំណល់ខុសច្បាប់ ច្រើនតែស្ថិតនៅកន្លែងដែលគេមើលមិនឃើញ ដែលធ្វើឱ្យគេលំបាកពិនិត្យរកឃើញ។ ការលំបាកនេះ កាន់មានលក្ខណៈធ្ងន់ធ្ងរជាមួយនឹងប្រជាជនដែលខ្វះការយល់ដឹងជាទូទៅអំពីបទប្បញ្ញត្តិកាកសំណល់។ មានមនុស្សតិចណាស់ដែលអាចបែងចែករវាងទីតាំងកាកសំណល់ស្របច្បាប់និងកន្លែងខុសច្បាប់។ ដូច្នេះ ជាធម្មតា អ្នកជំនាញផ្នែកកាកសំណល់ ទំនងជាអ្នករាយការណ៍តែមួយគត់អំពីកន្លែងកាកសំណល់ខុសច្បាប់។ ទោះយ៉ាងណាក៏ដោយ ក៏មានករណីសំខាន់ៗដែលប្រជាពលរដ្ឋឬសមាគមបរិស្ថាន បានរាយការណ៍អំពីកន្លែងកាកសំណល់ខុសច្បាប់។

## កន្លែងដុតកាកសំណល់ដោយខុសច្បាប់

ការដុតកាកសំណល់ដោយមិនមានការគ្រប់គ្រងដោយចេតនាឬដោយចៃដន្យក្តី គឺជាសកម្មភាពកាកសំណល់ខុសច្បាប់ដែលងាយឃើញបំផុត។ ការដុតបែបនេះ ច្រើនតែកើតឡើងនៅក្នុងកន្លែងដែលមិនមានអុកស៊ីសែនគ្រប់គ្រាន់ មានសីតុណ្ហភាពទាប ហើយមិនមានការត្រួតពិនិត្យឬគ្រប់គ្រងការបំភាយឧស្ម័នត្រឹមត្រូវ។ ការដុតកាកសំណល់ បង្កជាហានិភ័យខ្លាំងណាស់ចំពោះសុខភាពសាធារណៈនិងបរិស្ថាន។ ការដុតកាកសំណល់នៅទីវាលបើកចំហ ភាគច្រើនគឺជាទង្វើរំលោភលើលិខិតអនុញ្ញាតដែលផ្តល់ឲ្យកន្លែងដុតកាកសំណល់ទាំងនោះ ហើយការធ្វើបែបនេះដោយចេតនា អាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ជាតិ។ (Eunomia, 2017, p.10) ។

## ការចាក់ចោលកាកសំណល់ដោយខុសច្បាប់

ការចាក់ចោលកាកសំណល់ដោយខុសច្បាប់ គឺជាបទល្មើសដែលមានវិសាលភាពធំដែលតម្រូវឱ្យមានការបោះចោលដោយខុសច្បាប់នូវកាកសំណល់តាមផ្ទះសំបែង កាកសំណល់ឧស្សាហកម្ម កាកសំណល់ពាណិជ្ជកម្ម ឬកាកសំណល់ផ្សេងទៀតដែលគេគ្រប់គ្រងដោយគ្មានអាជ្ញាប័ណ្ណគ្រប់គ្រងកាកសំណល់។ ក្នុងករណីជាច្រើន វា គឺជារឿងឱកាសនិយមមួយ ជារឿងកើតឡើងតែម្តង ប្រព្រឹត្តដោយជនល្មើសដែលព្យាយាមចៀសវាងការចំណាយលើការសម្អាត ឬការបោះចោលកាកសំណល់។ ប៉ុន្តែជារួមសកម្មភាពបែបនេះ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

## ការធ្វើចំណាត់ថ្នាក់ខុសនិងការក្លែងបន្លំ

ការរក្សាកំណត់ត្រាបានត្រឹមត្រូវ មានលក្ខណៈចាំបាច់ណាស់នៅក្នុងប្រព័ន្ធគ្រប់គ្រងកាកសំណល់ ប៉ុន្តែគេ អាចទទួលបានផលចំណេញផ្នែកហិរញ្ញវត្ថុជាច្រើនក្នុងការក្លែងបន្លំឯកសារនិងកំណត់ត្រានានា។ ឧក្រិដ្ឋជនមួយចំនួន បានព្យាយាមបំភាន់កម្មវិធីទំនួលខុសត្រូវនានារបស់អ្នកផលិត ហើយទាមទារឲ្យមានការបង់ប្រាក់សម្រាប់ការកែច្នៃកាកសំណល់តាមការប្រឌិតរបស់គេ។ អ្នកផ្សេងទៀត បានព្យាយាម

អះអាងថាសារធាតុនោះ បានផុតកំណត់នៃលក្ខណៈជាកាកសំណល់ដែលតាមពិតទៅវា មិនទាន់ផុតកំណត់នៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ករណីនៃការធ្វើចំណាត់ថ្នាក់កាកសំណល់ ហាក់ដូចជារឿងដែលតែងតែកើតឡើង។ ការធ្វើចំណាត់ថ្នាក់ខុស គឺជាការប្រកាសខុសអំពីកាកសំណល់ តួយ៉ាងដូចជានៅពេលគេ ប្រកាសថាកាកសំណល់គ្រោះថ្នាក់ជា "កាកសំណល់ដែលគ្មានគ្រោះថ្នាក់" ជាដើម។ វា អាចកើតឡើងគ្រប់ពេលវេលានៅក្នុងខ្សែសង្វាក់គ្រប់គ្រងកាកសំណល់។ ជាធម្មតា វា កើតឡើងនៅពេលដែលស្ថាប័ន និង/ឬបុគ្គល (ទាំងដោយចៃដន្យឬដោយចេតនា) ធ្វើឱ្យមានការបែងចែកកាកសំណល់ខុសគ្នាចាប់តាំងពីចំណុចនៃផ្ទេរកាកសំណល់។ ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃការធ្វើចំណាត់ថ្នាក់កាកសំណល់ខុស អាចមានមានទ្រង់ទ្រាយធំខ្លាំង (Eunomia, 2017, p.11)។

## ការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់

ការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ អាចជាជម្រើសដ៏គួរឱ្យទាក់ទាញសម្រាប់ឧក្រិដ្ឋជនកាកសំណល់ ព្រោះការសម្អាតនិងការបោះចោលកាកសំណល់នៅក្នុងប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចហាក់មានតម្លៃថោកជាងមុន ដោយសារតែបទប្បញ្ញត្តិបរិស្ថាន មិនសូវមានលក្ខណៈតឹងរឹង។ បន្ថែមពីលើនេះ នៅពេលដែលកាកសំណល់ មិនត្រូវបានគ្រប់គ្រងឱ្យបានត្រឹមត្រូវនៅក្នុងប្រទេសដែលទទួលបានកាកសំណល់ វា អាចបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាននិងគ្រោះថ្នាក់ដល់សុខភាពមនុស្សយ៉ាងខ្លាំង (Eunomia, 2017, p.12)។ ការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ ត្រូវបានកំណត់និយមន័យជាអន្តរជាតិដោយសន្និបាត Basel ស្តីពីការគ្រប់គ្រងការដឹកជញ្ជូនឆ្លងព្រំដែននូវកាកសំណល់គ្រោះថ្នាក់និងការបោះចោលកាកសំណល់ទាំងនោះ ដែលមានខ្លឹមសារលម្អិតដូចខាងក្រោម៖

## ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើលក្ខខណ្ឌនៃលិខិតអនុញ្ញាតនិងលក្ខខណ្ឌលើកលើង

សកម្មភាពបទឧក្រិដ្ឋ មិនកំណត់ចំពោះតែអ្នកដែលធ្វើប្រតិបត្តិការក្រៅក្របខ័ណ្ឌច្បាប់ប៉ុណ្ណោះទេ។ វាក៏អាចត្រូវប្រព្រឹត្តដោយបុគ្គលឬស្ថាប័ននានាតាមរយៈការបំពានលើលិខិតអនុញ្ញាតផ្នែកបរិស្ថាន ឬការមិនគោរពតាមលក្ខខណ្ឌនៃករណីលើកលែងដែលបានចុះបញ្ជីផងដែរ ពេលខ្លះគេ ប្រព្រឹត្តដោយមិនគិតពីវិធានដែលបានចែងក្នុងលក្ខខណ្ឌទាំងនោះឡើយ។ ឧទាហរណ៍រួមមានការទទួលយកកាកសំណល់ដ៏ច្រើនលើសលុបដោយចេតនា ការទុកដាក់កាកសំណល់មិនសមរម្យ ឬការទទួលយកប្រភេទកាកសំណល់ខុស ។ ក្នុងករណីខ្លះការរំលោភបំពានបែបនេះ អាចបង្កហានិភ័យយ៉ាងខ្លាំងដល់សុខភាពមនុស្សនិងបរិស្ថាន។ តួយ៉ាងដូចជានៅពេលដែលកាកសំណល់ បង្កឲ្យជាគ្រោះថ្នាក់អគ្គីភ័យ ឬនៅពេលមានហានិភ័យនៃការដួលរលំកាកសំណល់ជាដើម (Eunomia, 2017, p.12) ។

## បទល្មើសពាក់ព័ន្ធ

បាតុភូតនៃការប្រមូលផ្តុំនៃបទឧក្រិដ្ឋ ឬបទឧក្រិដ្ឋពាក់ព័ន្ធ តែងតែកើតមាននៅក្នុងឧក្រិដ្ឋកម្មបរិស្ថាន។ វា សំដៅទៅលើចំនុចប្រសព្វរវាងបទឧក្រិដ្ឋបរិស្ថានជាមួយនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដូចជាអំពើពុករលួយនិងការលាងលុយកខ្វក់ជាដើម។

អំពើពុករលួយ មានលក្ខណគ្របដណ្តប់លើទង្វើផ្សេងៗ ដូចជាការសូកប៉ាន់ ការកិបកេង ការលាងលុយកខ្វក់ជាដើម (សូមមើលសន្និបាតរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ UN Convention Against Corruption) ហើយវាពាក់ព័ន្ធនឹងបុគ្គលជាច្រើន រួមមានមន្ត្រីព្រំដែន មន្ត្រីគយ និងប្រតិបត្តិករកំពង់ផែជាដើម (V.N. Palmeira et al., 2018 p. 53)។ ទាក់ទងនឹងការលាងលុយកខ្វក់ ឧក្រិដ្ឋកម្មបរិស្ថាន ត្រូវបានគេចាត់ទុកថាជាបទល្មើសពាក់ព័ន្ធមួយ ដូចដែលបានបញ្ជាក់នៅក្នុងអនុសាសន៍របស់កងកម្លាំងចម្រុះផ្នែកហិរញ្ញវត្ថុ (FATF) ហើយ គេណែនាំឱ្យផ្តោតលើទិដ្ឋភាពនានានៃការលាងលុយកខ្វក់របស់បទឧក្រិដ្ឋដែលមានអង្គការចាត់តាំង ជាយន្តការដើម្បីពង្រឹងការការបង្ក្រាបចំពោះឧក្រិដ្ឋម្មបរិស្ថាន ព្រោះ វា ជាបទឧក្រិដ្ឋដែលមានជំរុញដោយប្រាក់ចំណេញ (ENVICRIMENET, 2016, p 8. 9)។

## ៤. គោលការណ៍នៃច្បាប់បរិស្ថាន

មានគោលការណ៍ស្នូលមួយចំនួននៃច្បាប់បរិស្ថានដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋកាកសំណល់ផងដែរ។ គោលការណ៍ទាំងនេះ មានភាពពាក់ព័ន្ធនឹងបទឧក្រិដ្ឋកាកសំណល់ នៅពេលគេពិចារណាលើការអនុវត្តច្បាប់និងវិធានការអនុលោមតាមច្បាប់សម្រាប់បទឧក្រិដ្ឋកាកសំណល់។ គោលការណ៍ទាំងនេះ ក៏អាចពាក់ព័ន្ធផងដែរ នៅពេលគេពិចារណាអំពីជម្រើសនានានៃការផ្តន្ទាទោសចំពោះជនល្មើសបទឧក្រិដ្ឋកាកសំណល់។

### គោលការណ៍អ្នកបំពុលបរិស្ថានត្រូវទទួលខុសត្រូវចំពោះការចំណាយ

មធ្យោបាយដែលគេស្គាល់ច្បាស់បំផុតនៃមធ្យោបាយអន្តរជាតូបនីយកម្មនៃការចំណាយខាងក្រៅលើបរិស្ថាន គឺគោលការណ៍អ្នកបំពុលបរិស្ថានត្រូវទទួលខុសត្រូវចំពោះការចំណាយ។ ការចំណាយខាងក្រៅលើបរិស្ថាន ឬ "environmental externalities" សំដៅទៅលើទស្សនៈសេដ្ឋកិច្ចនៃផលប៉ះពាល់លើបរិស្ថានពីការផលិតនិងការប្រើប្រាស់នានាដែលមិនទាន់មានការប៉ះប៉ូវណាមួយនៅឡើយ ។ ផលប៉ះពាល់ទាំងនេះ ប៉ះពាល់ដល់ការចំណាយថ្លៃទឹកភ្លើង និងការចំណាយរបស់ក្រុមហ៊ុនដែលនៅក្រៅយន្តការទីផ្សារ។ ជាលទ្ធផលនៃផលអវិជ្ជមានការចំណាយលើផលិតកម្ម ទំនងជាមានកម្រិតទាបជាងការចំណាយលើសង្គម (OECD, 2003)។ យោងតាមគោលការណ៍ទាំង១៦ នៃសេចក្តីប្រកាស Rio (Rio Declaration)ស្តីអំពីបរិស្ថាននិងការអភិវឌ្ឍន៍ គោលការណ៍នេះ ចែងថាអ្នកបង្កការបំពុលបរិស្ថាន គួរតែទទួលខុសត្រូវចំពោះការចំណាយលើការជួសជុលបរិស្ថាន។ ដើម្បីបកស្រាយឱ្យបានកាន់តែទូលំទូលាយ វា មានន័យថាគោលការណ៍អ្នកបំពុលបរិស្ថានត្រូវទទួលខុសត្រូវចំពោះការចំណាយនេះ នឹងតម្រូវឱ្យអ្នកដែលបង្កឲ្យការបំពុលបរិស្ថាននិងកាកសំណល់ ត្រូវតែចំណាយលើការថែរក្សា

បរិស្ថាន ការចៀសវាង ឬការកាត់បន្ថយការបំពុល បរិស្ថាន។ គេ តម្រូវឱ្យអ្នកបំពុលបរិស្ថានទទួលខុសត្រូវចំពោះការចំណាយខាងក្រៅដែលកើតឡើងពីការបំពុលបរិស្ថាន។

រឿងនេះ អាចធ្វើទៅបាន ដោយអ្នកបំពុលបរិស្ថាន ធ្វើសម្អាតរាល់ការបំពុលបរិស្ថាន និងស្តារបរិស្ថានឱ្យនៅវិលត្រឡប់មកស្ថានភាពមុនពេលបំពុល តាមភាពពិតជាក់ស្តែង។ អ្នកបំពុលបរិស្ថាន គប្បីជួសជុលផងដែរចំពោះការខូចខាតនានាដែលបង្កឡើងដោយការប្រព្រឹត្តរបស់ខ្លួន ដូចជាការបាត់បង់ជីវិតនៃជីវចម្រុះ និងការខូចខាតដល់វចនាសម្ព័ន្ធនិងការបំពេញមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី។ ចំពោះបទឧក្រិដ្ឋបរិស្ថាន គេ ត្រូវតែរៀបចំឡើងនិងពង្រឹងនូវប្រព័ន្ធដែលថាអ្នកដែលបង្កអន្តរាយដល់បរិស្ថាន ត្រូវតែបង់ថ្លៃចំណាយទាក់ទងនឹងការសំអាតចំពោះការខូចខាតទាំងនោះ។ វា គឺជាបញ្ហាដែលត្រូវចោទសួរថាតើ គួរមានការផ្លាស់ប្តូរសមីការដើម្បីឲ្យការអនុលោមតាមច្បាប់ក្លាយជាជម្រើសដ៏ល្អបំផុតសម្រាប់ទាំងបុគ្គលនិងក្រុមហ៊ុនសាជីវកម្មនានា។

## គោលការណ៍ការពារប្រសើរជាងព្យាបាល

មិនមាននិយមន័យដែលគេទទួលយកជាសកលអំពីគោលការណ៍នេះទេ។ គោលការណ៍ ១៥ នៃសេចក្តីប្រកាស Rio (Rio Declaration) ចែងថា *"ដើម្បីការពារបរិស្ថាន គេ ត្រូវអនុវត្តវិធីសាស្ត្រការពារប្រសើរជាងព្យាបាលឲ្យបានយ៉ាងទូលំទូលាយដោយរដ្ឋនានា អាស្រ័យទៅតាមសមត្ថភាពរបស់ពួកគេ។ នៅករណីដែលមានការគំរាមកំហែងធ្វើឲ្យខូចខាតយ៉ាងធ្ងន់ធ្ងរឬបរិស្ថានមិនអាចវិលត្រឡប់មកស្ថានភាពដើមវិញ គេ មិនត្រូវយកកង្វះភាពប្រាកដប្រជាផ្នែកវិទ្យាសាសមកប្រើជាហេតុផលដោះសារចំពោះការពន្យារពេលក្នុងការចាត់វិធានចំណាយប្រកបដោយប្រសិទ្ធភាពដើម្បីទប់ស្កាត់ការសឹករិចរិលរបស់បរិស្ថានឡើយ"*។ គួរឲ្យកត់សម្គាល់ផងដែរថាគោលការណ៍ ១៥ ក៏បានចែងថា "រដ្ឋនានា ត្រូវតែអនុវត្តវិធីសាស្រ្តការពារប្រសើរជាងព្យាបាលនេះឲ្យបានទូលំទូលាយដោយអាស្រ័យទៅតាមសមត្ថភាពរបស់ពួកគេរៀងៗខ្លួន" ។ សន្និបាត Basel បានបញ្ចូលនូវវិធីសាស្រ្តការពារប្រសើរជាងព្យាបាលនេះ ដោយអនុញ្ញាតឱ្យរដ្ឋនានាបដិសេធមិនទទួលយកកាកសំណល់ និងដោយតម្រូវឱ្យរដ្ឋនានាដែលនាំចេញកាកសំណល់ បង្ហាញថាកាកសំណល់នឹងត្រូវគ្រប់គ្រងប្រកបដោយលក្ខណៈសុវត្ថិភាពចំពោះបរិស្ថានមុនពេលនាំចេញ។ បន្ទុកនេះ ត្រូវបានធ្លាក់ទៅលើអ្នកដែលគាំទ្រសកម្មភាពបែបនេះ ដើម្បីមិនត្រឹមតែបំពេញចិត្តរដ្ឋដែលនាំចូលកាកសំណល់ប៉ុណ្ណោះទេ គឺដើម្បីបំពេញចិត្តរដ្ឋដែលកាត់សំណល់ឆ្លងកាត់ផងដែរ ដោយធានាថាការចល័តកាកសំណល់បែបនេះ នឹងមិនបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថានឡើយ។

## គោលការណ៍អធិបតេយ្យភាពអចិន្ត្រៃលើធនធានធម្មជាតិ និងតួនាទីដែលមិនធ្វើឲ្យប៉ះពាល់បរិស្ថានឆ្លងដែន

នៅក្នុងបរិបទនៃការគ្រប់គ្រងកាកសំណល់ ការអនុវត្តគោលការណ៍នេះ មានន័យថានៅពេលដែលរដ្ឋមានសេរីភាពក្នុងការបង្កើតកាកសំណល់ ពួកគេចាំបាច់ត្រូវតែធានាថាការគ្រប់គ្រងនិងការបោះចោលកាកសំណល់ដែលពាក់ព័ន្ធ នឹងមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាននៃរដ្ឋផ្សេងទៀតឬតំបន់ដែលហួសដែនសមត្ថកិច្ចជាតិខ្លួនឡើយ។

## គោលការណ៍នៃការចាត់វិធានការទប់ស្កាត់

គោលការណ៍នេះ តម្រូវឲ្យរដ្ឋនានាបំពេញកាតព្វកិច្ចក្នុងការបង្ការមិនឲ្យមានការខូចខាតដល់បរិស្ថាន និងកាត់បន្ថយ កំណត់កម្រិត ឬគ្រប់គ្រងសកម្មភាពដែលអាចនឹងបង្កឬដែលមានហានិភ័យនាំឲ្យខូចខាតបរិស្ថាន។ កាតព្វកិច្ច មានទម្រង់ជាសារាចរដែលរួមបញ្ចូលនូវការអនុម័តនិងការអនុវត្តនូវវិធាននិងមធ្យោបាយនានាសមស្រប និងត្រួតពិនិត្យសកម្មភាពនានាដែលអនុវត្តដោយតួអង្គឯកជននិងរដ្ឋ។

## គោលការណ៍នៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ

គោលការណ៍នេះ មានប្រភពចេញពីយន្តការច្បាប់អន្តរជាតិផ្សេងៗនិងច្បាប់ដែលមានលក្ខណៈទន់ភ្លន់។ គោលការណ៍ទី១៤ នៃសេចក្ដីប្រកាស Rio ស្ដីពីបរិស្ថាននិងការអភិវឌ្ឍន៍(Rio Declaration on Environment and Development) (សេចក្ដីប្រកាស Rio) អំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព "ដើម្បីបញ្ឈប់ឬរារាំងការចល័តទីឬផ្ទេរសកម្មភាពឬសារជាតុណាមួយដែលបណ្ដាលឲ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរឬដែលគេរកឃើញថាបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សទៅឲ្យរដ្ឋដទៃទៀត"។ តម្រូវការនៃកិច្ចសហប្រតិបត្តិការនេះ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃសន្និបាត Basel ទាក់ទងទៅនឹង តួយ៉ាងដូចជា៖ ការជូនដំណឹងទៅលេខាធិការដ្ឋានអំពីនិយមន័យជាតិនៃកាកសំណល់គ្រោះថ្នាក់ ការជូនដំណឹងទៅភាគីផ្សេងទៀតអំពីការសម្រេចហាមឃាត់ការនាំចូល ការផ្លាស់ប្ដូរព័ត៌មានស្ដីពីចល័តកាកសំណល់ឆ្លងដែននិងផលប៉ះពាល់ជាក់ស្ដែងដែលអាចកើតមានលើសុខភាពមនុស្សនិងបរិស្ថាន ការចែករំលែកព័ត៌មានអំពីចល័តកាកសំណល់ឆ្លងដែនក្នុងគោលបំណងពង្រឹង គ្រប់គ្រងបរិស្ថាន និងទប់ស្កាត់ចរាចរណ៍កាកសំណល់ដោយខុសច្បាប់ និងការផ្លាស់ប្ដូរព័ត៌មានទៅឱ្យរដ្ឋដែលពាក់ព័ន្ធស្ដីពីវិធីសាស្ត្រផ្នែកបច្ចេកទេសនិងផ្នែកវិទ្យាសាស្ត្រ អំពីប្រភពប្រឹក្សាផ្ដល់យោបល់និងជំនាញនានា និងអំពីពីវត្តមាននិងសមត្ថភាពនៃកន្លែងសម្រាប់បោះចោលកាកសំណល់។

## គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព

គោលការណ៍ទូទៅដែលចែងថារដ្ឋនានាគួរធានាដល់ការអភិវឌ្ឍនិងការប្រើប្រាស់ធនធានរបស់ខ្លួនប្រកបដោយនិរន្តរភាព ត្រូវបានគេស្គាល់នៅក្នុងច្បាប់អន្តរជាតិចាប់តាំងពីពេលដែលមានការជំនំជំរះក្ដីដែនសមុទ្រនៅឆ្នាំ១៨៩៣ ( Bering Sea Fur Seals) មកម្ល៉េះ។ ទោះជាយ៉ាងណា គេ ឃើញថាពាក្យ"ការអភិវឌ្ឍប្រកបដោយចីរភាព" មានប្រភពនៅក្នុងរបាយការណ៍ Bruntland ឆ្នាំ១៩៨៧(1987 Bruntland Report)។ ប្រទេសជាច្រើន បញ្ចូលនិយមន័យនៃការអភិវឌ្ឍប្រកបដោយចីរភាពទៅក្នុងច្បាប់និងគោលនយោបាយជាតិរបស់ខ្លួន។ នៅក្នុងសំណុំរឿង Gabčikovo-Nagymaros តុលាការយុត្តិធម៌អន្តរជាតិ (ICJ) បានចែងថាបទដ្ឋានថ្មីៗរួមទាំងទស្សនៈនៃការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវយកមកពិចារណានិងផ្ដល់ទម្ងន់ដ៏សមរម្យទាំងនៅពេលគិតអំពីសកម្មភាពថ្មីៗនិងនៅពេលមានសកម្មភាពដែលបានចាប់ផ្ដើមនៅក្នុងអតីតកាលកំពុងបន្តកើតឡើង ។

# ជំពូក ១ ក្របខណ្ឌគតិយុត្តិ

## ១.១ យន្តការអន្តរជាតិ

នៅក្នុងផ្នែកនេះ សន្និបាតនិងសន្ធិសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មកាកសំណល់ ត្រូវបានយកមកពិភាក្សា។ សន្និបាត Basel ស្តីពីការគ្រប់គ្រងចល័តឆ្លងកាត់ព្រំដែននិងការបោះចោលនូវកាកសំណល់គ្រោះថ្នាក់ (Basel Convention) ដែលបានពិពណ៌នាខាងក្រោម គឺជាសន្ធិសញ្ញាអន្តរជាតិដ៏សំខាន់ដែលចែងអំពីការចល័តឆ្លងដែននូវកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងៗទៀត។ ធាតុផ្សំសំខាន់ៗនៅក្នុងសន្និបាត Basel រួមមានការចាត់ទុកចរាចរណ៍ខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងទៀតជាបទឧក្រិដ្ឋ តម្រូវការក្នុងការអនុវត្តនីតិវិធីបង្ហាញពីការយល់ព្រមដោយជូនដំណឹងជាមុនសម្រាប់ការចល័តឆ្លងដែននូវកាកសំណល់ដែលគ្រប់គ្រង ដោយសន្និបាត Basel សិទ្ធិរបស់ភាគីក្នុងការដាក់កម្រិត/ហាមឃាត់ចំពោះការនាំចូលនិងនាំចេញកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតសម្រាប់ការបោះចោល សិទ្ធិរបស់រដ្ឋភាគីនានាក្នុងការកំណត់នូវប្រភេទកាកសំណល់ផ្សេងៗបន្ថែមទៀតក្រៅពីប្រភេទនៃកាកសំណល់ដែលត្រូវបានគ្រប់គ្រងដោយសន្និបាតBaselថាមានគ្រោះថ្នាក់ក្រោមច្បាប់ជាតិរបស់ខ្លួន។ ទោះបីជាបទប្បញ្ញត្តិនៃសន្និបាត Basel ទាក់ទងនឹងនិយមន័យនិងការចាត់ចំណាត់ថ្នាក់កាកសំណល់ អាចមានលក្ខណៈបច្ចេកទេសខ្ពស់ក៏ដោយ ក៏នីតិវិធីរបស់វា មានលក្ខណៈច្បាស់លាស់បើនិយាយពីលិខិតបង្ហាញពីការយល់ព្រមដោយបានជូនដំណឹងជាមុន។

លើសពីនេះទៀត សន្និបាត Stockholm (Stockholm Convention) ស្តីពីសារធាតុបំពុលសរីរាង្គនៅឆ្នាំ២០០១ សន្និបាត Rotterdam (Rotterdam Convention) ស្តីពីនីតិវិធីនៃការបង្ហាញការយល់ព្រមដោយបានជូនដំណឹងជាមុនសម្រាប់សារធាតុគីមីគ្រោះថ្នាក់និងថ្នាំសំលាប់សត្វល្អិតមួយចំនួននៅក្នុងពាណិជ្ជកម្មអន្តរជាតិនៅឆ្នាំ១៩៨៨ សន្និបាត Minamata (Minamata Convention) ស្តីពីបារតឆ្នាំ២០១៧ និងពិធីសារ Montreal (Montreal Protocol) ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូននៅឆ្នាំ១៩៨៧ អាចនឹងពាក់ព័ន្ធជាមួយការចោទប្រកាន់ចំពោះប្រភេទកាកសំណល់ខុសច្បាប់មួយចំនួន។ ឯកសារណែនាំនិងយន្តការអនុលោមតាមច្បាប់មួយចំនួន ត្រូវបានបង្កើតឡើង ដែលមានដូចជា៖

- *សៀវភៅណែនាំស្តីអំពីការចោទប្រកាន់ចំពោះការចរាចរណ៍ដោយខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់ ឬកាកសំណល់ផ្សេងៗទៀតនៅឆ្នាំ ២០១២* (*Instruction manual on the prosecution of illegal traffic of hazardous wastes or other wastes* developed by the Basel Convention Secretariat)
- *កូនសៀវភៅសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីអំពីការគ្រប់គ្រងការដឹកជញ្ជូនសារធាតុគីមី និងកាកសំណល់ដោយខុសច្បាប់នៅឆ្នាំ២០១៥ - សម្រាប់មន្ត្រីអនុវត្តច្បាប់នៅអាស៊ី*ដែលរៀបរៀងដោយអង្គការ UNEP សម្រាប់បណ្តាញអង្គភាពអនុវត្តច្បាប់ក្នុងតំបន់ចំពោះសារធាតុគីមី និងកាកសំណល់។

- សៀវភៅណែនាំការបណ្តុះបណ្តាលមួយចំនួន( *training manuals*) ដើម្បីជួយមន្ត្រីគយ និងមន្ត្រីស៊ើបអង្កេត ដែលរៀបរៀងដោយលេខាធិការដ្ឋានរបស់សន្និបាត Basel។

សន្និបាតអន្តរជាតិទាំងនេះ តម្រូវឱ្យមានបំលែងទៅជាច្បាប់ជាតិ ហើយច្បាប់ជាតិ ជាច្បាប់ដែលគ្រប់គ្រងនិយមន័យនៃកាកសំណល់ បទល្មើសដែលអាចនឹងត្រូវបានគេចោទប្រកាន់ និងប្រភេទនៃនីតិវិធីនានា ដូចជានីតិវិធីផ្លូវរដ្ឋបាល រដ្ឋប្បវេណី ឬព្រហ្មទណ្ឌដែលអាចត្រូវបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច។ គេហទំព័ររបស់សន្និបាត Basel ( website ) ផ្តល់ភាពងាយស្រួលក្នុងការចូលមើលច្បាប់ស្តីពីកាកសំណល់ដែលពាក់ព័ន្ធនៅទូទាំងពិភពលោក។

## សន្និបាត Basel

ផ្នែកនេះ ពិភាក្សាអំពីសន្និបាត Basel និងលក្ខខណ្ឌច្បាប់ដែលចាំបាច់សម្រាប់ការចល័តកាកសំណល់គ្រោះថ្នាក់ និងកាកសំណល់ផ្សេងទៀតឆ្លងព្រំដែនដោយអនុលោមតាមសន្និបាតនេះ។

ការធ្វើវិសោធនកម្មមួយចំនួនលើសន្និបាតBaselដែលត្រូវបានអនុម័តដោយរដ្ឋភាគីនានា បានធ្វើឱ្យការគ្រប់គ្រងការចល័តឆ្លងដែននូវកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងទៀត កាន់តែមានប្រសិទ្ធិភាព។

នៅខែធ្នូឆ្នាំ ២០១៩ វិសោធនកម្មច្បាប់ Ban Amendment បានចូលជាធរមានក្រោយពីមានការផ្តល់សច្ចាប័នថ្មីធ្វើឡើងដោយប្រទេសCroatia។ វិសោធនកម្ម "Ban Amendment" ចែងពីបំរាមនានាដែលហាមឃាត់ដោយភាគីនីមួយៗ (នៅក្នុងឧបសម្ព័ន្ធVIIថ្មីដែលគេបានដាក់ស្នើ រួមមានភាគីនិងរដ្ឋដទៃទៀតដែលជាសមាជិករបស់អង្គការ OECD, គណៈកម្មការអឺរ៉ុប, Liechtenstein ដែលធ្វើការចល័តកាកសំណល់ឆ្លងដែនទៅកាន់រដ្ឋនានាដែលមិនរាប់បញ្ចូលក្នុងឧបសម្ព័ន្ធទី VII ចាស់) ដែលមានកាកសំណល់គ្រោះថ្នាក់ដែលមានចែងដោយសន្និបាតនេះដែលគេមានបំណងនាំយកទៅបោះចោលនៅគោលដៅចុងក្រោយ និងដែលធ្វើការដឹកជញ្ជូនឆ្លងដែនទៅកាន់រដ្ឋនានាដែលមិនមាននៅក្នុងឧបសម្ព័ន្ធVII នូវកាកសំណល់គ្រោះថ្នាក់ដែលមានចែងក្នុងកថាខណ្ឌ ១ (a) នៃមាត្រា១នៃសន្និបាតនេះ ក្នុងគោលបំណងយកទៅប្រើប្រាស់ ការកែច្នៃ ឬជួសជុលកាកសំណល់ឡើងវិញ។ ( Basel Convention, 2019 )

លើសពីនេះទៀតនៅឆ្នាំ ២០១៩ រដ្ឋភាគីនានា បានអនុម័តការធ្វើវិសោធនកម្មមួយដើម្បីបញ្ជាក់ពីវិសាលភាពនៃប្រភេទកាកសំណល់ប្លាស្ទិចក្នុងវិសាលភាពនៃសន្និបាតBasel ហើយត្រូវអនុវត្តតាមនីតិវិធីត្រួតពិនិត្យរបស់សន្និបាតនេះ។

ប្រអប់ខាងក្រោម បង្ហាញពីនិយមន័យនៃកាកសំណល់នៅក្នុងសន្និបាត Basel។ ដែនយុត្តាធិការជាតិនីមួយៗតម្រូវឱ្យអនុវត្តតាមសន្និបាតនេះដោយស្របតាមច្បាប់ជាតិរបស់ខ្លួន។ វា មានសំខាន់ណាស់ដែលព្រះរាជអាជ្ញា និងមន្ត្រីស៊ើបអង្កេត ត្រូវដឹងអំពីនិយមន័យជាតិជាក់លាក់នីមួយ។

### *តើកាកសំណល់ គឺជាអ្វី? និយមន័យកាកសំណល់ក្រោមសន្និបាត Basel*

សន្និបាតនេះ ឲ្យនិយមន័យ "កាកសំណល់"ថាជាសារធាតុឬវត្ថុដែលគេបោះចោល ឬគេមានបំណងបោះចោល ឬ តម្រូវឲ្យបោះចោលដោយបទប្បញ្ញត្តិនៃច្បាប់ជាតិ (មាត្រា ២ កថាខណ្ឌ ១)។ បទប្បញ្ញត្តិនេះ អនុវត្តចំពោះអ្វីដែលគេស្គាល់ថាជាកាកសំណល់ "គ្រោះថ្នាក់" និង "ផ្សេងទៀត" ។ អ្វីដែលកំណត់ដោយសន្និបាតនេះថាជា**កាកសំណល់គ្រោះថ្នាក់**ស្របតាមនិយមន័យខាងលើ ត្រូវបានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១ នៃសន្និបាតនេះ ដែលចែងថា៖

(a) កាកសំណល់ដែលស្ថិតនៅក្នុងប្រភេទណាមួយដែលមាននៅក្នុងឧបសម្ព័ន្ធ I នៃសន្និបាតនេះ លើកលែងតែកាកសំណល់នោះ មិនមានលក្ខណៈណាមួយដែលមាននៅក្នុងឧបសម្ព័ន្ធ III ។ និង

(b) កាកសំណល់ដែលមិនមានចែងក្នុងកថាខណ្ឌ (a) ប៉ុន្តែត្រូវបានកំណត់ថាជាឬត្រូវបានចាត់ទុកថាជាកាកសំណល់គ្រោះថ្នាក់ ដោយច្បាប់ជាតិរបស់រដ្ឋភាគីនាំចេញ នាំចូល ឬកាកសំណល់ឆ្លងកាត់។

ឧបសម្ព័ន្ធទី VIII នៃសន្និបាត Basel (បញ្ជី A ) ពិពណ៌នាអំពីកាកសំណល់ដែលមានគ្រោះថ្នាក់។

កថាខណ្ឌ ១ (b) នៃមាត្រា ១ នៃសន្និបាតនេះ គឺជាឧទាហរណ៍មួយទៀតនៃសិទ្ធិដែលបានផ្តល់ឱ្យរដ្ឋភាគីមួយក្នុងការពង្រីកវិសាលភាពនៃការអនុវត្តតាមសន្និបាតនេះចំពោះកាកសំណល់ដែលត្រូវបានកំណត់ថា "មានគ្រោះថ្នាក់" ក្រោមច្បាប់ជាតិរបស់ខ្លួន។ ដូចក្នុងករណីដែលមានការរឹតត្បិតលើការនាំចូល លក្ខណៈជាក់លាក់ក្នុងប្រទេសនីមួយៗទាំងនោះ ចាំបាច់ត្រូវជម្រាបជូនដល់គ្រប់ភាគីទាំងអស់តាមរយៈលេខាធិការដ្ឋានរបស់សន្និបាត ដោយស្របតាមមាត្រា៣នៃសន្និបាតនេះ ហើយគួរតែត្រូវបានផ្តល់ដំណឹងជូនអាជ្ញាធរពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិជាពិសេសស្ថានប័នអនុវត្តច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ច ព្រោះវា ពិតជាប៉ះពាល់ដល់វិសាលភាពនៃការអនុវត្តតាមកាតព្វកិច្ចនៃសន្និបាតនេះ។

បញ្ជីនិយមន័យថ្នាក់ជាតិនៃកាកសំណល់គ្រោះថ្នាក់ដែលបានជូនដំណឹងតាមរយៈលេខាធិការដ្ឋានរបស់សន្និបាតនេះ មាននៅក្នុងប្រព័ន្ធអនឡាញ។

ប្រភេទទី២នៃកាកសំណល់ដែលបានចែងដោយសន្និបាតនេះ គឺ "កាកសំណល់ផ្សេងៗទៀត" ត្រូវបានកំណត់និយមន័យនៅក្នុងឧបសម្ព័ន្ធ២នៃសន្និបាតនេះ ហើយរាប់បញ្ចូលទាំងកាកសំណល់និងកំទេចកំទីកើតឡើងពីការដុតកាកសំណល់នៅតាមផ្ទះផងដែរ។

ឧបសម្ព័ន្ធ IX (បញ្ជី B) រួមបញ្ចូលកាកសំណល់ដែលនឹងមិនត្រូវបានគេកំណត់ថាមិនមែនជាកាកសំណល់ដែលបានចែងដោយមាត្រា១(a)នៃសន្និបាត Basel លើកលែងតែ កាកសំណល់នោះ មានផ្ទុកសារធាតុដែលមានចែងក្នុងឧបសម្ព័ន្ធ ១ ដែលពេលខ្លះធ្វើឲ្យវាមានលក្ខណៈដែលបានចែងក្នុងឧបសម្ព័ន្ធ III ។

**កាកសំណល់ដែលមិនមានចែងដោយសន្និបាតនេះ**

មាត្រា ១ ក៏ចែងផងដែរថា កាកសំណល់ខាងក្រោម មិនត្រូវបានចែងក្នុងសន្និបាតនេះទេះ

(a) កាកសំណល់ដែលមានសារធាតុវិទ្យុសកម្ម គឺត្រូវតែស្ថិតនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្សេងទៀត ដែលរួមយន្តការអន្តរជាតិដែលអនុវត្តជាពិសេសចំពោះសារធាតុវិទ្យុសកម្ម។

(b) កាកសំណល់ ដែលកើតចេញពីប្រតិបត្តិការប្រក្រតីរបស់កប៉ាល់ សារធាតុដែលបញ្ចេញដោយកប៉ាល់មានចែងដោយយន្តការអន្តរជាតិមួយផ្សេងទៀត។

ឧបសម្ព័ន្ធនៅក្នុងសន្និបាត Basel

- ឧបសម្ព័ន្ធ I រួមបញ្ចូលប្រភេទកាកសំណល់ដែលគេត្រូវតែគ្រប់គ្រង។
- ឧបសម្ព័ន្ធ II គឺជាប្រភេទនៃកាកសំណល់ដែលត្រូវការការពិចារណាជាពិសេស។
- ឧបសម្ព័ន្ធ III រួមមានបញ្ជីនៃលក្ខណៈគ្រោះថ្នាក់ ដូចជាសារធាតុផ្ទុះ ងាយរលួយពុល ឬ ដែលងាយឆេះ។
- ឧបសម្ព័ន្ធ IV និយាយអំពីប្រតិបត្តិការបោះចោលកាកសំណល់។
- ឧបសម្ព័ន្ធ V រួមបញ្ចូលព័ត៌មានដែលត្រូវផ្តល់ជូននៅក្នុងសេចក្តីជូនដំណឹង (ផ្នែក A) និងឯកសារអំពីការចល័តកាកសំណល់ (ផ្នែក B) ។ ឧបសម្ព័ន្ធ VI និយាយអំពីការកាត់ក្តី ហើយឧបសម្ព័ន្ធVII នៅមិនទាន់ចូលជាធរមាននៅឡើយទេ។
- នៅក្នុងឧបសម្ព័ន្ធ VII ភាគីនានា នឹងត្រូវបានដាក់ចូលនៅក្នុងបញ្ជីដែលទទួលបានការយល់ព្រមក្នុងការហាមឃាត់រាល់ការចល័តឆ្លងកាត់ព្រំដែននូវកាកសំណល់គ្រោះថ្នាក់ដែលត្រូវបានរៀបចំដឹកទៅបោះចោលនៅគោលដៅចុងក្រោយចេញពីបណ្តារដ្ឋជាសមាជិកOECD ទៅរដ្ឋមិនមែនជាសមាជិករបស់ OECD (ក្រោមវិសោធនកម្ម Ban Amendment) ។
- ឧបសម្ព័ន្ធ VIII (បញ្ជី A) រួមបញ្ចូលកាកសំណល់ដែលមានលក្ខណៈគ្រោះថ្នាក់ដូចមានចែងក្នុងមាត្រា ១ កថាខណ្ឌ ១ (a) ។
- ឧបសម្ព័ន្ធ IX (បញ្ជី B) រួមបញ្ចូលកាកសំណល់ដែលមិនត្រូវបានកំណត់ថាជាកាកសំណល់ដោយបានចែងក្នុងមាត្រា ១ (a) នៃសន្និបាត Basel លើកលែងតែ កាកសំណល់នោះ មានផ្ទុកសារធាតុដែលបានចែងក្នុងឧបសម្ព័ន្ធ ១ ដែលពេលខ្លះធ្វើឲ្យវាមានលក្ខណៈដែលបានចែងក្នុងឧបសម្ព័ន្ធ III ។

ប្រភព៖

Secretariat of the Basel Convention and UNEP (2012). The Basel Convention: Instruction Manual on the Prosecution of Illegal Traffic of Hazardous Wastes or Other Wastes

| | |
|---|---|
| UN Environment, The Basel Convention, 2018. http://www.basel.int/Portals/4/download.aspx?d=UNEP-CHW-IMPL-CONVTEXT.English.pdf | |
| | |

សន្និសិទនៃរដ្ឋភាគីនានានៃសន្និបាតBasel បានបង្កើតគោលការណ៍ណែនាំផ្នែកបច្ចេកទេស(Technical guidelines)ជាច្រើនជាពិសេសគោលការណ៍ណែនាំផ្នែកបច្ចេកទេសស្តីពីការកាកសំណល់អេឡិចត្រូនិច (Technical guidelines on e-waste) ក៏ដូចជាសទ្ទានុក្រមនៃពាក្យគន្លឹះ(Glossary of terms) ដើម្បីបញ្ជាក់ពីពាក្យនានាដែលគេបានប្រើនៅក្នុងសន្និបាតនេះ។

## ១.២ ការយល់ព្រមដោយបានជូនដំណឹងជាមុនក្រោមសន្និបាត Basel

ប្រសិនបើមិនមានការយល់ព្រមដែលបានជូនដំណឹងជាមុនពីប្រទេសនាំចូលកាកសំណល់និងប្រទេសដែលកាកសំណល់ឆ្លងកាត់ទេ ការនាំចេញកាកសំណល់ មិនគួរត្រូវបានអនុញ្ញាតទេ ដោយយោងតាមសន្និបាត Basel ។ ដូចដែលបានពិពណ៌នានៅខាងក្រោម កាកសំណល់ទាំងអស់ដែលបានចែងនៅក្នុងសន្និបាត Basel គួរតែភ្ជាប់មកជាមួយឯកសារនៃការចល័តកាកសំណល់ដោយមាននូវលិខិតបង្ហាញពីការយល់ព្រមដើម្បីដឹកកាកសំណល់បែបនេះឆ្លងព្រំដែនបាន ហើយកាកសំណល់នោះ ត្រូវតែមានពិពណ៌នានៅក្នុងឯកសារដែលភ្ជាប់ជាមួយកុងតឺន័រ។ ការខកខានមិនបានអនុលោមតាមតម្រូវការនេះ មានន័យថាកាកសំណល់នោះ នឹងស្ថិតនៅក្រោមនិយមន័យនៃ "ចរាចរណ៍កាកសំណល់ខុសច្បាប់" (សូមមើលខាងក្រោម) ។

សន្និបាត Basel មានចែងអំពីនីតិវិធីនៃការបង្ហាញពីការយល់ព្រមដែលបានជូនដំណឹងជាមុន(PIC)យ៉ាងលម្អិតដោយមានលក្ខខណ្ឌតឹងរឹងសម្រាប់ដឹកកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងៗទៀតឆ្លងព្រំដែន។ នីតិវិធីនេះ បង្កើតជាបេះដូងនៃប្រព័ន្ធត្រួតពិនិត្យកាកសំណល់របស់សន្និបាត Basel ហើយផ្អែកលើដំណាក់កាលសំខាន់ៗចំនួន ៤

(១) ការជូនដំណឹង
(២) ការយល់ព្រម និងការចេញឯកសារដឹកកាកសំណល់
(៣) ការដឹកកាកសំណល់ឆ្លងព្រំដែន និង
(៤) ការបញ្ជាក់ពីការបោះចោលកាកសំណល់

រឿងសំខាន់ដែលត្រូវចងចាំគឺថា នីតិវិធី PIC ត្រូវកើតឡើងមុនពេលកាកសំណល់ ត្រូវបានដឹកជញ្ជូន។ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូលកាកសំណល់ ត្រូវតែផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរអំពីការដឹក

ជញ្ជូនកាកសំណល់មុនពេលនាំចេញ។ របៀបដែលបទប្បញ្ញត្តិទាំងនេះត្រូវបានអនុវត្ត នឹងត្រូវបានកំណត់ដោយច្បាប់ជាតិនៃប្រទេសនាំចូល។




**រូបភាព១ នីតិវិធីបង្ហាញពីការយល់ព្រមដោយបានជូនដំណឹងជាមុន** ([UNEP, 2015](UNEP, 2015))

ចំណាំ៖ លេខ និងទិសដៅព្រួញ បង្ហាញអំពីលំដាប់នៃជំហានសមស្របដើម្បីអនុវត្តតាម

## ១.៣ និយមន័យនៃការចរាចរណ៍កាកសំណល់ដោយខុសច្បាប់

**<u>និយមន័យរបស់សន្ធិបាតនៃ"ការចរាចរណ៍កាកសំណល់ដោយខុសច្បាប់"៖</u>**

សម្រាប់គោលបំណងនៃសន្និបាតនេះ ជាការដឹកកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតណាមួយឆ្លងដែន៖

(a) ដោយគ្មានការជូនដំណឹង ដល់រដ្ឋទាំងអស់ដែលពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិនៃសន្និបាតនេះ។ ឬ

(b) ដោយគ្មានការយល់ព្រមពីរដ្ឋណាមួយដែលពាក់ព័ន្ធដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្និបាតនេះ។ ឬ

(c) ដោយមានការយល់ព្រមពីរដ្ឋពាក់ព័ន្ធ តាមរយៈការបោកប្រាស់ ការបង្ហាញព័ត៌មានមិនពិត ឬការក្លែងបន្លំ។ ឬ

(d) ដែលមិនស្របតាមលក្ខណៈរបស់សារជាតុភ្ជាប់ជាមួយឯកសារនានា

(e) ដែលនាំឱ្យមានការបោះចោលកាកដោយចេតនា (ឧទាហរណ៍ការចាក់ចោលកាកសំណល់) នូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតដោយបំពានលើសន្និបាតនេះនិងគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ នឹងត្រូវចាត់ទុកថាជាចរាចរណ៍កាកសំណល់ខុសច្បាប់។

កថាខណ្ឌរង (a) - (d) ចែងអំពីលក្ខខណ្ឌដែលបង្កឲ្យមានការរំលោភលើនីតិវិធីនៃការជូនដំណឹង ខណៈដែលកថាខណ្ឌរង (e) ចែងអំពីលក្ខខណ្ឌដែលបង្កឲ្យមានការរំលោភលើបទដ្ឋានដែលគេរំពឹងឲ្យអនុវត្តតាម អំពីការបោះចោលកាកសំណល់និងលក្ខខណ្ឌនៃការគ្រប់គ្រងបរិស្ថាន។

BASEL (2012)

សន្និសីទរបស់ភាគីនៃសន្និបាតនេះ បានបង្កើតគោលការណ៍ណែនាំ(Guidance)ដោយមានគោលបំណងដើម្បីសម្រេចកម្មវត្ថុនៃការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងនឹងចរាចរណ៍កាកសំណល់ដោយខុសច្បាប់។

## ១.៤ នីតិវិធីបញ្ជូនកាកសំណល់ត្រឡប់ទៅវិញ

ក្នុងករណីមានចរាចរណ៍កាកសំណល់ដោយខុសច្បាប់ បទប្បញ្ញត្តិនៃសន្និបាត Basel តម្រូវឱ្យរដ្ឋនាំចេញធានាថាកាកសំណល់ដែលមានបញ្ហាត្រូវបានបញ្ជូនត្រឡប់ទៅវិញដោយអ្នកនាំចេញឬអ្នកផលិតកាកសំណល់ ឬបើចាំបាច់ត្រូវបញ្ជូនត្រឡប់ទៅវិញដោយខ្លួនឯងផ្ទាល់ទៅឲ្យរដ្ឋនាំចេញក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលទទួលបានព័ត៌មានអំពីចរាចរណ៍កាកសំណល់ខុសច្បាប់ ឬក្នុងរយៈពេលផ្សេងទៀតតាមដែលរដ្ឋពាក់ព័ន្ធ អាចយល់ព្រម ប្រសិនបើប្រតិបត្តិការនៃចរាចរណ៍កាកសំណល់ដោយខុសច្បាប់គឺជាលទ្ធផលនៃការប្រព្រឹត្តខុសច្បាប់របស់អ្នកនាំចេញឬអ្នកផលិតកាកសំណល់។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធកន្លងមក បង្ហាញថាផលវិបាកអាចកើតមាន តួយ៉ាងដូចជាការកំណត់រកម្ចាស់នៃកាកសំណល់ជាដើម។

ប្រសិនបើមានវិវាទរវាងភាគីពាក់ព័ន្ធថាតើអ្នកណាជាម្ចាស់ស្របច្បាប់នៃកាកសំណល់ ពេលវេលាដែលត្រូវដោះស្រាយវិវាទនោះ អាចមានរយៈពេលយូរ ដូច្នេះវា ធ្វើឲ្យមានការពន្យាពេលការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញតាមតម្រូវការដែលមានចែងក្នុងសន្និបាត Basel ។

ច្បាប់ជាតិនៃប្រទេសមួយចំនួន តម្រូវឱ្យមានការចោទប្រកាន់ប្រកបដោយជោគជ័យ មុនពេលចាត់វិធានការចំពោះការនាំចូលកាកសំណល់ដោយខុសច្បាប់ម្តងទៀត។ ក្នុងករណីបែបនេះ ប្រសិនបើក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ មិនយល់ព្រមដោយស្ម័គ្រចិត្តក្នុងការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញនោះទេ ពេលវេលាដែលត្រូវដោះស្រាយបញ្ហាចរាចរណ៍កាកសំណល់ដោយខុសច្បាប់ ទំនងជាអូសបន្លាយរយៈពេលយូរ។ ដោយសារតែមានផលលំបាកទាំងនេះ នៅពេលដែលការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ ត្រូវគេចាប់បាន ប្រទេសនាំចូលមានកាតព្វកិច្ចក្នុងការចាត់វិធានការសម្រាប់ការរៀបចំការបញ្ជូនកាកសំណល់ទៅប្រទេសនាំចេញវិញ។ ដើម្បីជួយសម្រួលដល់ការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញអោយបានឆាប់

របស់ស្របតាមលក្ខខណ្ឌនៃសន្និបាតBasel កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលដល់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនាំចូលនិងរដ្ឋពាក់ព័ន្ធដទៃទៀត គួរតែជាអាទិភាព។

## ១.៥ ក្របខណ្ឌច្បាប់ជាតិ

នៅពេលគេនិយាយអំពីការកាត់ទោសនៅក្នុងតុលាការជាតិ គេយកក្របខណ្ឌច្បាប់ជាតិក្នុងការត្រួសត្រាយរកវិធីសាស្ត្រដែលត្រូវអនុវត្តដោយព្រះរាជអាជ្ញានិងទីភ្នាក់ងារផ្សេងទៀត។ នៅអឺរ៉ុប មានក្របខណ្ឌច្បាប់ទូលំទូលាយដែលរួមមានសារាចរនិងបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបក៏ដូចជាច្បាប់និងក្របខ័ណ្ឌជាតិនានាផងដែរ (សូមមើលឧបសម្ព័ន្ធ ៣) នៅអាស៊ី ក្របខ័ណ្ឌច្បាប់ជាតិ ផ្តល់នូវមូលដ្ឋានសម្រាប់ការស៊ើបអង្កេតនិងការកំណត់អត្តសញ្ញាណនៃបទល្មើស (សូមមើលឧបសម្ព័ន្ធ ៤) ។ មិនមានក្របខ័ណ្ឌច្បាប់របស់អាស៊ានស្រដៀងនឹងសហភាពអឺរ៉ុបទេ ដូច្នេះអ្នកស៊ើបអង្កេតនិងព្រះរាជអាជ្ញា ចាំបាច់ត្រូវពឹងផ្អែកលើនិយមន័យជាតិនៃ"កាកសំណល់"និងក្របខ័ណ្ឌជាតិនានាដើម្បីហាមឃាត់ឬដាក់កម្រិតលើការដឹកជញ្ជូន ការស្តុកទុក ការគ្រប់គ្រង និងចុងក្រោយការបោះចោលកាកសំណល់និងផលិតផលកាកសំណល់។

# ជំពូក ២ ការចោទប្រកាន់ និងគោលនយោបាយក្នុងការអនុវត្តច្បាប់

## ២.១ គោលនយោបាយក្នុងការអនុវត្តច្បាប់បរិស្ថាន

ក្របខ័ណ្ឌគតិយុត្តិសម្រាប់បទឧក្រិដ្ឋកាកសំណល់ អាចត្រូវបានគេអនុវត្តតាមវិធីផ្សេងៗ ដូចជាតាមរយៈនីតិវិធីរដ្ឋបាល រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ។ អាចមានជម្រើសជាច្រើន អាស្រ័យលើលក្ខណៈនិងភាពធ្ងន់ធ្ងរនៃការរំលោភច្បាប់។ លើសពីនេះទៀត ដែនយុត្តាធិការផ្សេងគ្នា អនុវត្តដោយស្របតាមច្បាប់ ប្រព័ន្ធច្បាប់ ការអនុវត្ត និងនីតិវិធីរបស់ដែនយុត្តាធិការរៀងៗខ្លួន(UNEP "Instruction manual", 2012, p.26)។[1] ដោយមិនរាប់បញ្ចូលអង្គភាពមួយចំនួនដែលទទួលខុសត្រូវក្នុងការរៀបចំសំណុំរឿង (ឧទាហរណ៍ដូចជា ប៉ូលីស ភ្នាក់ងារជំនាញ ព្រះរាជអាជ្ញា) គេ តម្រូវឲ្យមានសកម្មភាពស្រដៀងគ្នានេះ ដើម្បីប្រមូល វិភាគ និងបង្ហាញភស្តុតាងដែលមានគុណភាព និងជាតុផ្សំគ្រប់គ្រាន់ដើម្បីកាត់ទោសសំណុំរឿងមួយ។

វា ជារឿងមានប្រយោជន៍ដែលទីភ្នាក់ងារអនុវត្តច្បាប់ត្រូវបង្កើតគោលនយោបាយដ៏ទូលំទូលាយមួយដែលនឹងជួយដល់ការចោទប្រកាន់និងដល់ទីភ្នាក់ងារស៊ើបអង្កេតផ្សេងទៀតក្នុងការកំណត់ថាតើអ្នកណាដែលគួរត្រូវបានកាត់ទោសនិងពីបទអ្វី។ ការពិគ្រោះយោបល់រវាងភ្នាក់ងារពាក់ព័ន្ធទាំងអស់ មានសារៈសំខាន់ក្នុងការបង្កើនយុទ្ធសាស្ត្រអនុលោមតាមច្បាប់ឱ្យបានច្រើនបំផុតសម្រាប់បទឧក្រិដ្ឋកកាកសំណល់។

គោលនយោបាយអនុវត្តន៍និងអនុលោមតាមច្បាប់បរិស្ថាន គប្បីសង្ខេបអំពីវិធីសាស្ត្រទូទៅរបស់ទីភ្នាក់ងារក្នុងការអនុវត្តន៍និងការអនុលោមតាមច្បាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មកាកសំណល់។ សេចក្តីសង្ខេប គប្បីរួមបញ្ចូលសេចក្តីលម្អិតនៃច្បាប់ជាតិពាក់ព័ន្ធ និងរៀបរាប់យ៉ាងលម្អិតអំពីតួនាទីនិងទំនួលខុសត្រូវរបស់ភ្នាក់ងារអេយ្យការនិងទីភ្នាក់ងារស៊ើបអង្កេតផ្សេងៗទៀត។ វា នឹងក្លាយជាយន្តការមួយដ៏មានប្រសិទ្ធិភាពដើម្បីដឹកនាំសេចក្តីសម្រេចរបស់ទីភ្នាក់ងារអេយ្យការដើម្បីធានាថាវិធានការនិងសកម្មភាពអនុលោមតាមច្បាប់របស់ខ្លួន មានភាពត្រឹមត្រូវ យុត្តិធម៌ និងគួរឱ្យទុកចិត្ត។

ជាមួយគ្នានេះផងដែរ នៅក្នុងយុត្តាធិការជាច្រើន ភ្នាក់ងារបរិស្ថាននិងអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ មានទំនួលខុសត្រូវក្នុងការធ្វើនិយតកម្មលើសកម្មភាពផ្សេងៗគ្នានិងក្នុងការត្រួតពិនិត្យចំពោះការអនុលោមតាមច្បាប់ និងយន្តការច្បាប់នានាដែលគ្រប់គ្រងការបំភាយឧស្ម័ន សំឡេង កាកសំណល់ គុណភាពទឹក ព្រៃឈើ កន្លែងដែលមានការបំពុលបរិស្ថាន ទំនិញគ្រោះថ្នាក់ សារធាតុគ្រោះថ្នាក់និងថ្នាំសម្លាប់សត្វល្អិត។ ដោយសារមុខងារដ៏ធំ

[1] ការកំណត់អត្តសញ្ញាណកាកសំណល់គ្រោះថ្នាក់នៅក្នុងប្រទេសមួយ អាចនឹងមិនចាំបាច់ត្រូវតែផ្តល់នូវមូលដ្ឋានសម្រាប់ការអនុវត្តនៅក្នុងប្រទេសមួយទៀតឡើយ។ ទោះបើជានៅពេលដែលមានកិច្ចព្រមព្រៀងទូទៅក៏ដោយ ក៏សិទ្ធិរបស់ភាគីនានាក្នុងការកំណត់កាកសំណល់ដែលមិនស្ថិតក្នុងសន្ធិបាត Basel ថាជាកាកសំណល់គ្រោះ ដោយយោងតាមច្បាប់ជាតិ អាចនឹងធ្វើឲ្យការចោទប្រកាន់មានលក្ខណៈលំបាក។ រឿងនេះ បង្ហាញអំពីសារៈសំខាន់នៃនីតិវិធីនៃការបង្ហាញការយល់ព្រមនិងការជូនដំណឹងរបស់សន្និបាត Basel ។

ទូលាយទាំងនេះហើយ ទើប វា ជារឿងសំខាន់ណាស់ដែលអាជ្ញាធរមានសមត្ថកិច្ចទាំងនេះ ត្រូវអនុវត្តសិទ្ធិអំណាចពិសេសនិងការសម្រេចចិត្តរបស់ខ្លួន ប្រកបដោយយុត្តិធម៌និងគួរអោយទុកចិត្ត។ គោលការណ៍ខាងក្រោម អាចយកមកប្រើធ្វើជាមគ្គុទេសក៍សម្រាប់ធ្វើសេចក្ដីសម្រេចលើសកម្មភាពអនុវត្តច្បាប់បាន ដូចតទៅៈ

- វិធានការអនុវត្តច្បាប់ នឹងមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការល្មើសច្បាប់។
- សេចក្ដីសម្រេចអំពីសកម្មភាពអនុវត្តច្បាប់ នឹងមិនមានភាពលំអៀង ដោយផ្អែកលើភស្តុតាងដែលមាន និងកម្មវត្ថុជាយុទ្ធសាស្ត្ររបស់អាជ្ញាធរអនុវត្តច្បាប់។

គោលនយោបាយអនុលោមតាមច្បាប់ដ៏ល្អ អាចធានាបានថាព្រះរាជអាជ្ញានិងអាជ្ញាធរមានសមត្ថកិច្ច បានបំពេញតាមសេចក្ដីរំពឹងទុករបស់សហគមន៍និងតុលាការដែលថាព្រះរាជអាជ្ញា នឹងធ្វើតាមរបៀបមួយដែលបង្ហាញពីគោលការណ៍យុត្តិធម៌ ហើយដែលថាអំណាចរបស់ព្រះរាជអាជ្ញា នឹងគេត្រូវបានប្រើប្រាស់ដោយតម្កល់ផលប្រយោជន៍សាធារណៈជាធំ។

វិធានការច្បាប់រឹងមាំនិងសមស្រប គប្បីៈ

- មានលក្ខណៈឆ្លើយតប និងមានប្រសិទ្ធភាព
- មានគោលដៅ និងកម្មវត្ថុច្បាស់លាស់
- សមរម្យ
- មានលក្ខណៈតឹងរឹង ប៉ុន្តែយុត្តិធម៌
- ផ្ដល់ដំណឹងជាមុន
- មានលក្ខណៈត្រឹមត្រូវ
- មានតម្លាភាព
- មានក្រមសីលធម៌ និងគណនេយ្យភាព
- មានកិច្ចសហការល្អ

នៅក្នុងដែនយុត្តាធិការមួយចំនួន គោលនយោបាយអនុលោមតាមច្បាប់សម្រាប់បទឧក្រិដ្ឋបរិស្ថាន មានកម្មវត្ថុច្បាស់លាស់ ដើម្បីៈ

- ណែនាំអាជ្ញាធរក្នុងការអនុវត្តនូវទំនួលខុសត្រូវក្នុងការអនុវត្តច្បាប់និងការចោទប្រកាន់។
- ជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីវិធីដែលនាយកដ្ឋាន អនុវត្តនូវទំនួលខុសត្រូវលើការអនុវត្តច្បាប់របស់ខ្លួន រួមទាំងការអនុវត្តតាមឆន្ទានុសិទ្ធិដើម្បីចោទប្រកាន់ផងដែរ។
- ពន្យល់ពីរបៀបដែលត្រូវចោទប្រកាន់ចុងចោទដោយសមរម្យ និងកំណត់វិធានការនានាចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការរំលោភបំពានច្បាប់។

- គួសបញ្ជាក់ពីវិធានការអនុវត្តច្បាប់ដែលមានលក្ខណៈបើកចំហដល់នាយកដ្ឋាន ដើម្បីបន្តការងារ
- ជម្រុញឲ្យមានវប្បធម៌ចាត់វិធានការដែលមានលក្ខណៈវិជ្ជមាន មានគណនេយ្យភាព មានការពិគ្រោះយោបល់ និងមានកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋាន
- ពង្រឹងវិធានការអនុវត្តច្បាប់ដែលមានលក្ខណៈត្រឹមត្រូវ មានសមាហរណកម្ម និងមានការសម្របសម្រួល។

## ២.២ នីតិវិធីសម្រាប់បទល្មើស

នីតិវិធីសម្រាប់បទល្មើស នឹងត្រូវបានចែងដោយច្បាប់ជាតិទាក់ទងនឹងឧក្រិដ្ឋកម្មកាកសំណល់និងច្បាប់នីតិវិធីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌថ្នាក់ជាតិ។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ជំនួយទូទៅមួយចំនួនក្នុងរបៀបមួយសម្រាប់ដំណើរការនៃការចោទប្រកាន់ឧក្រិដ្ឋកម្មកាកសំណល់ និងជាពិសេសការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។

មាននីតិវិធីបីប្រភេទដែលគេអាចអនុវត្តបាន គឺនីតិវិធីស៊ីវិល ព្រហ្មទណ្ឌ និងរដ្ឋបាល។ ទោះបីជានិយមន័យ អាចមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយក៏ដោយ ជាទូទៅច្បាប់ព្រហ្មទណ្ឌ ដោះស្រាយចំពោះបទឧក្រិដ្ឋ និងការកាត់ទោសបទឧក្រិដ្ឋ ហើយបទល្មើស មានច្រើនប្រភេទ ចាប់ពីការល្មើសច្បាប់តូចតាចដូចជាការមិនឈប់នៅពេលមានភ្លើងស្តុបពណ៌ក្រហមរហូតដល់ឃាតកម្មនិងការជួញដូរគ្រឿងញៀន។ ច្បាប់រដ្ឋប្បវេណីគឺជាច្បាប់ដែលចែងទាក់ទងនឹងបុគ្គលឯកជន ឬស្ថាប័ននានា។ ច្បាប់រដ្ឋបាល គឺជាច្បាប់ដែលទាក់ទងនឹងវិធានឬបទប្បញ្ញត្តិនានាដែលបានបង្កើតនិងអនុវត្តដោយភ្នាក់ងាររដ្ឋាភិបាល រីឯច្បាប់រដ្ឋបាល បង្កើតបទប្បញ្ញត្តិរវាងរដ្ឋាភិបាលនិងពលរដ្ឋ (government, 2019)។ ស្របជាមួយនឹងច្បាប់កាកសំណល់ មានច្បាប់បីប្រភេទដែលអាចយកមកអនុវត្តបាន ដោយយោងតាមច្បាប់ជាតិ។

<table>
<tr><td colspan="5">មធ្យោបាយរដ្ឋបាល</td></tr>
<tr><td>ការដកហូតអាជ្ញាបណ្ណ</td><td>លិខិតព្រមាន</td><td>ការផាកពិន័យជាប្រាក់</td><td>ការបញ្ជាឲ្យលាងសម្អាត</td><td>បទប្បញ្ញត្តិបញ្ជាឲ្យបញ្ជូនត្រឡប់ទៅវិញ</td></tr>
<tr><td colspan="5">នីតិវិធីរដ្ឋប្បវេណី</td></tr>
<tr><td colspan="2">ការផាកពិន័យជាប្រាក់</td><td colspan="3">ការចាត់វិធានការអនុវត្តច្បាប់</td></tr>
</table>

| នីតិវិធីព្រហ្មទណ្ឌ | | |
|---|---|---|
| ការផាកពិន័យ | ការដាក់ពន្ធនាគារ | ការបញ្ជាឲ្យផ្តល់ជាសំណង |

**តារាង ១ ទិដ្ឋភាពទូទៅនៃមធ្យោបាយ រដ្ឋបាល រដ្ឋប្បវេណី និង ព្រហ្មទណ្ឌ**




**រូបភាពទី ២៖ គ្រោងនៃវិធីសាស្រ្តអនុវត្តច្បាប់ដែលអាចមាន**

## នីតិវិធីព្រហ្មទណ្ឌ

នៅក្រោមច្បាប់ជាតិ គេ អាចសម្រេចថាតើគេ គប្បីដោះស្រាយសំណុំរឿងណាមួយតាមនីតិវិធីរដ្ឋប្បវេណី តាមមធ្យោបាយរដ្ឋបាល ឬក៏គេ ត្រូវចោទប្រកាន់បទព្រហ្មទណ្ឌចំពោះសំណុំរឿងទាំងនោះ។ ដើម្បីធ្វើសេចក្តីសម្រេចនេះបាន អាជ្ញាធរអាចថ្លឹងថ្លែងអំពីទំហំនៃការខូចខាត ទៅនឹងទំហំនៃពិរុទ្ធភាពនៃការប្រព្រឹត្តនោះ និងឱកាសសមរម្យក្នុងការទទួលបានជោគជ័យចំពោះការចោទប្រកាន់។ ក្នុងករណីអន្តរជាតិ គេក៏អាចពិចារណាថាតើដែនយុត្តាធិការណាមួយដែលមានឱកាសល្អបំផុតដែលអាចឆ្លោះទៅដល់ការផ្តន្ទាទោសបាន។ ( Basel Convention and UNEP, 2012 )។

លក្ខណៈវិនិច្ឆ័យមួយដែលគេអាចនឹងប្រើក្នុងការជ្រើសរើសនីតិវិធីណាមួយ គឺការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទល្មើស។ ក្នុងករណីនៃបទល្មើសកាកសំណល់ បទល្មើសទាក់ទងនឹងឯកសារ អាចទំនងជាមានផលប៉ះពាល់តិចតួចឬមធ្យម។ ទោះយ៉ាងណាក៏ដោយ គេ ក៏ពិចារណាផងដែរថាតើបទល្មើសឯកសារ ត្រូវបានធ្វើឡើងដោយមានចេតនាឬមានគោលបំណងជាក់លាក់ឬទេ ហើយប្រសិនបើគេ មិនទាន់បានកំណត់រកឃើញបទល្មើសនោះនៅឡើយទេ គេ ត្រូវពិចារណាថាតើកាកសំណល់ខុសច្បាប់នោះ ត្រូវបានគេបោះចោលនៅក្នុងកន្លែងគ្រប់គ្រងកាកសំណល់ដែលគេអនុញ្ញាត ឬថាតើវា ត្រូវបានគេចាក់ចោលដោយខុសច្បាប់ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថានបន្ថែមទៀតឬទេ។ (សូមមើលតារាង ១ ខាងលើ)។ លក្ខណៈវិនិច្ឆ័យទី២ អាចជាការប្រព្រឹត្តទូទៅរបស់ជនល្មើស ហើយលក្ខណៈវិនិច្ឆ័យមួយទៀត អាចជាការកំណត់នូវពិរុទ្ធភាពរបស់ជនល្មើស។

| កម្រិតនៃភាពធ្ងន់ធ្ងរ | មានផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ធ្ងន់ធ្ងរ | មានផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ច្រើន | មានផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់មធ្យម | មានផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់តិចតួច | ផលប៉ះពាល់ ឬហានិភ័យនៃផលប៉ះពាល់ទាប |
|---|---|---|---|---|---|
| | • មានផលប៉ះពាល់ជាអចិន្ត្រៃយ៍ឬមានសក្តានុពលនៃផលប៉ះពាលជាអចិន្ត្រៃយ៍រយៈពេលយូរ<br><br>• មានផលប៉ះពាល់ឬអាចមានផលប៉ះពាល់ជាទ្រង់ទ្រាយធំ ឬក្នុងកម្រិតធ្ងន់ធ្ងរខ្លាំង<br><br>• បង្កជាកង្វល់ដល់សាធារណៈក្នុងទ្រង់ទ្រាយធំកម្រិតខ្ពស់ឬមានផលប៉ះពាល់ដល់សុវត្ថិភាពសាធារណៈអំពីឧប្បត្តិហេតុនោះ<br><br>• ប្រសិនបើបទល្មើស មានលក្ខណៈជាបទល្មើសរដ្ឋប្បវេណី វា ធ្វើឲ្យកម្ម | • អាចមានផលប៉ះពាល់ពីកម្រិតមធ្យមរហូតដល់រយៈពេលយូរអង្វែង ឬអាចមានផលប៉ះពាល់<br><br>• មានផលប៉ះពាល់ឬអាចមានផលប៉ះពាល់ពីកម្រិតមធ្យមរហូតដល់កម្រិតធ្ងន់ធ្ងរខ្លាំង<br><br>• បង្កជាកង្វល់សាធារណៈកម្រិតខ្ពស់ឬមានផលប៉ះពាល់ដល់សុវត្ថិភាពសាធារណៈកម្រិតខ្ពស់<br><br>• ប្រសិនបើបទល្មើស មានលក្ខណៈជាបទល្មើសរដ្ឋប្បវេណី វា ធ្វើឲ្យកម្មវិធីច្បាប់ចុះខ្សោយ | • មានផលប៉ះពាល់កម្រិតបណ្តោះអាសន្ន រហូតដល់កម្រិតរយៈពេលមធ្យម ឬអាចមានផលប៉ះពាល់<br><br>• មានផលប៉ះពាល់ឬអាចមានផលប៉ះពាល់ពីកម្រិតក្នុងតំបន់រហូតដល់កម្រិតមធ្យម ឬពីកម្រិតទាបរហូតដល់មធ្យម<br><br>• បង្កជាកង្វល់សាធារណៈកម្រិតមធ្យម ឬមានផលប៉ះពាល់សុវត្ថិភាពសាធារណៈកម្រិតមធ្យម<br><br>• ប្រសិនបើបទល្មើសមានលក្ខណៈ | • មានផលប៉ះពាល់រយៈពេលខ្លី ឬអាចមានផលប៉ះពាល់<br><br>• មានផលប៉ះពាល់ឬអាចមានផលប៉ះពាល់កម្រិតក្នុងតំបន់ ឬក្នុងកម្រិតទាប<br><br>• បង្កជាកង្វល់ដល់សាធារណៈជនក្នុងកម្រិតទាប ឬមានផលប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ<br><br>• ប្រសិនបើបទល្មើសមានលក្ខណៈជាបទល្មើសរដ្ឋប្បវេណី វា មិនមានផលប៉ះពាល់លើកម្ម | • មិនមានផលប៉ះពាល់ ឬអាចមានផលប៉ះពាល់<br><br>• មិនមានកង្វល់ដល់សាធារណៈឬមានផលប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ<br><br>• ប្រសិនមានបទល្មើសដែលមានលក្ខណៈជាបទរដ្ឋប្បវេណី វា អាចមិនត្រូវបានគេទប់ស្កាត់ |

| | | | | | |
|---|---|---|---|---|---|
| | វិធីច្បាប់ចុះខ្សោយ ឬប្រសិនបើជនល្មើស ផ្តល់ព័ត៌មានខុសឬក្លែងក្លាយ | ឬប្រសិនបើជនល្មើសលាក់បាំងព័ត៌មាន ឬគេចវេស មិនទទួលខុសត្រូវមុនច្បាប់ក្នុងការបង់ថ្លៃ ឬមិនបានចាត់វិធានការដើម្បីបង្កាមិនឲ្យមានបទល្មើស | ជាបទល្មើសរដ្ឋប្បវេណី វា ប៉ះពាល់កម្រិតមធ្យមដល់កម្មវិធីច្បាប់ឬប្រសិន បើជនល្មើសខកខានដោយធ្វេសប្រហែសក្នុងការអនុលោមតាមលក្ខខណ្ឌនៃនីតិវិធីរដ្ឋបាល | វិធីច្បាប់ឬប្រសិនបើមិនមានចេតនា | |

**តារាង ២៖ លក្ខខណ្ឌត្រូវពិចារណាក្នុងការកំណត់កម្រិតធ្ងន់ធ្ងរនៃបទល្មើស**

## នីតិវិធីរដ្ឋបាល

ដោយជាទូទៅនិងភាគច្រើនត្រូវបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច ការផ្តន្ទាទោសផ្នែករដ្ឋបាល អាចត្រូវបានគេអនុវត្តចំពោះសំណុំរឿងដែលមានប្រតិបត្តិករ ក្រុមហ៊ុន ឬបុគ្គលដែលពាក់ព័ន្ធក្នុងដឹកកាកសំណល់ឆ្លងដែន មានចន្លោះប្រហោងក្នុងការអនុវត្តតាមនីតិវិធីនៃការជូនដំណឹង និងការដឹកជញ្ជូនកាកសំណល់ដាក់លាក់។ មានការអន្តរាគមន៍ជាច្រើនដែលគេអាចនឹងប្រើ ក្នុងនោះរួមមានសេចក្តីជូនដំណឹងនានាដើម្បីឲ្យចាត់វិធានការ (ឬបញ្ឈប់)និងផាកពិន័យដោយមិនចាំបាច់ពឹងផ្អែកលើតុលាការ និងដោយសមាមាត្រទៅនឹងទំហំនៃបទមជ្ឈិម (ក្រោមហេតុផលផ្សេងៗ ក្នុងនោះរួមមានបរិមាណនៃកាកសំណល់គ្រោះថ្នាក់និងកង្វះនៃការពិពណ៌នាត្រឹមត្រូវអំពីកាកសំណល់)។ ការពិន័យទោស ត្រូវតែសមាមាត្រទៅនឹងទំហំនៃបទមជ្ឈិម ក្រោមហេតុផលផ្សេងៗ ដែលក្នុងនោះរួមមានបរិមាណនៃកាកសំណល់គ្រោះថ្នាក់ ការខ្វះការពិពណ៌នាត្រឹមត្រូវ (Basel Convention and UNEP, 2012)។

ដោយហេតុដូច្នោះហើយ វត្តមាននៃប្រព័ន្ធដាក់ទណ្ឌកម្មផ្នែករដ្ឋបាល មានសារៈសំខាន់ណាស់។ គេ អាចប្រើទណ្ឌកម្មផ្នែករដ្ឋបាល ក្នុងសំណុំរឿងនានាដែលអាចនឹងត្រូវបានប្រានចោលដោយមិនមានសំណងផ្លូវការណាមួយសោះ។ នីតិវិធីនៃការដាក់ពិន័យផ្នែករដ្ឋបាលនិងការប្រើអាជ្ញាធរមានសមត្ថកិច្ច មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ គេ អនុវត្តដូចគ្នាចំពោះសំណុំរឿងដែលពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែនៅក្នុងប្រព័ន្ធច្បាប់ភាគច្រើន កម្រិតលក្ខខណ្ឌនៃភស្តុតាងធ្វើឲ្យតម្លៃនៃការផាកពិន័យផ្នែករដ្ឋបាលទាបជាងនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ការផាកពិន័យផ្នែករដ្ឋបាល អាចត្រូវបានណែនាំឲ្យប្រើសម្រាប់បទល្មើសតូចតាច ប៉ុន្តែការផាកពិន័យនេះ ជាទូទៅដើរតួជាមធ្យោបាយដ៏មានសុពលភាព ។

វា ជារឿងសំខាន់ណាស់ដែលគេ ត្រូវចៀសវាងស្ថានភាពដែលត្រូវដោះស្រាយឧក្រិដ្ឋកម្មបរិស្ថានធ្ងន់ធ្ងរតាមរយៈការពិន័យផ្នែករដ្ឋបាលដែលមានតម្លៃទាប។ មានវិធីសាស្ត្រផ្សេងៗដើម្បីចៀសវាងបញ្ហាបែបនេះ។ ម៉្យាងវិញ គឺត្រូវបញ្ជាក់នៅក្នុងច្បាប់ថាតើគេ អាចធ្វើការផាកពិន័យផ្នែករដ្ឋបាលចំពោះបទល្មើសប្រភេទណា។ លទ្ធភាពមួយទៀត គឺសម្រាប់គោលនយោបាយអនុលោមតាមច្បាប់របស់ទីភ្នាក់ងារមានសមត្ថកិច្ចក្នុងការផ្តល់តួនាទីសំខាន់ឲ្យព្រះរាជអាជ្ញា ដើម្បីកំណត់ថាតើត្រូវប្រើជម្រើសនៃនីតិវិធីមួយណា។ បន្ទាប់មក ព្រះរាជអាជ្ញាជាអ្នកសម្រេចថាតើនឹងត្រូវកាត់ទោសសំណុំរឿងជាក់លាក់ណាមួយក្នុងតុលាការព្រហ្មទណ្ឌឬត្រូវបញ្ជូនទៅទីភ្នាក់ងាររដ្ឋបាលក្នុងគោលបំណងធ្វើការដាក់ពិន័យផ្នែករដ្ឋបាល។

### នីតិវិធីរដ្ឋប្បវេណី

វិធានការរដ្ឋប្បវេណី អាចត្រូវបានអនុវត្តសម្រាប់ការរំលោភបំពានណាមួយទំនងជាមានលក្ខណៈសមរម្យសម្រាប់អង្គជំនុំជម្រះក្តីព្រហ្មទណ្ឌ ។ ភាពបត់បែននៃវិធានការរដ្ឋប្បវេណី អាចជួយពង្រឹងការអនុលោមតាមបទប្បញ្ញត្តិដោយមិនពាក់ព័ន្ធនឹងលក្ខខណ្ឌផ្នែកច្បាប់។ ការផាកពិន័យ អាចប្រព្រឹត្តទៅបានលឿនជាងមុន ហើយអាចនឹងមានលក្ខណៈយុត្តិធម៌ និងការចំណាយមានប្រសិទ្ធភាពជាង។ ថាតើត្រូវអនុវត្តវិធានការរដ្ឋប្បវេណីឬទេ អាស្រ័យលើកម្មវត្ថុ និងប្រសិនបើវា អាចដើរតួជាវិធានការបញ្ឈប់បទល្មើសដ៏សមរម្យ( Basel Convention and UNEP, 2012 )។ ក៏អាចមានលទ្ធភាពនៃការអនុវត្តវិធានការផ្តល់ជាសំណងដូចដែលបានចែងក្នុងមាត្រា ១២ នៃសន្និបាតនេះដែរតាមរយៈច្បាប់ជាតិ ( ពិធីសារស្តីពីទំនួលខុសត្រូវមុខច្បាប់និងសំណងចំពោះការខូចខាតដែលបណ្តាលមកពីការដឹកកាកសំណល់គ្រោះថ្នាក់ឆ្លងកាត់ព្រំដែននិងការបោះចោលកាកសំណល់ មិនទាន់បានចូលជាធរមាននៅឡើយទេ ) ។

## ២.៥ ជម្រើសនៃនីតិវិធីនានា

ជម្រើសនៃនីតិវិធី អាចទទួលឥទ្ធិពលពីកត្តាជាច្រើន ក្នុងនោះរួមមានកម្រិតធ្ងន់ធ្ងរនៃបទល្មើសនិងភស្តុតាងដែលអាចរកបានដើម្បីបង្ហាញអំពីការប្រព្រឹត្តបទល្មើស។ នៅក្នុងដែនយុត្តាធិការខ្លះ សេចក្តីសម្រេចក្នុងការចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌជាទូទៅ ត្រូវបានធ្វើឡើងដោយអគ្គនាយករងនៃទីភ្នាក់ងារបរិស្ថាន។ នៅក្នុងដែនយុត្តាធិការផ្សេងទៀត សេចក្តីសម្រេចនេះ អាចត្រូវបានធ្វើឡើងដោយការិយាល័យព្រះរាជអាជ្ញា។ នៅក្នុងដែនយុត្តាធិការផ្សេងទៀត ទីបំផុតគេ ចាំបាច់ត្រូវតែធ្វើការកាត់ទោសផ្នែកព្រហ្មទណ្ឌ ឬដោយគ្មានកម្រិតណាមួយនៃសេចក្តីសម្រេច។

រឿងដែលត្រូវពិចារណាចំនួនពីរសម្រាប់ការចាប់ផ្តើមនីតិវិធីព្រហ្មទណ្ឌ គឺ៖

- ថាតើភស្តុតាងដែលមានផ្តល់នូវលទ្ធភាពសមហេតុផលដើម្បីធ្វើការផ្តន្ទាទោសប្រកបដោយជោគជ័យឬទេ និង
- ប្រសិនបើដូច្នោះមែន ថាតើវា តម្កល់ផលប្រយោជន៍សាធារណៈក្នុងការអនុវត្តធន្ទានុសិទ្ធដើម្បីធ្វើការចោទប្រកាន់ដែរឬទេ។

ការកំណត់អំពីលទ្ធភាពនៃការចោទប្រកាន់ដែលបានស្នើប្រកបដោយជោគជ័យ នឹងពិចារណាថាតើ៖

- ភស្តុតាងដែលមាន អាចបង្ហាញពីធាតុផ្សំនីមួយៗនៃបទល្មើសលើសវិមតិសង្ស័យដែរឬទេ។
- ការទទួលយកភស្តុតាងក្នុងតុលាការ
- សុច្ចរិតភាពនៃសាក្សីដែលមាន
- វត្តមានឬភាពរឹងមាំនៃភស្តុតាងរបស់អ្នកជំនាញដែលតម្រូវឲ្យបង្ហាញថាមានបទល្មើសកើតឡើង
- ការដោះសារនានាដោយបើកចំហរបស់ជនជាប់ចោទ

ផលប្រយោជន៍សាធារណៈ អាចរាប់បញ្ចូលហេតុផលជាច្រើន ប៉ុន្តែក្នុងសំណុំរឿងនៃឧក្រិដ្ឋកម្មកាកសំណល់ហេតុផលសំខាន់មួយ គឺភាពធ្ងន់ធ្ងរនៃបទល្មើស ដែលរួមមានផលប៉ះពាល់ដែលកើតឡើងឬផលប៉ះពាល់ដែលអាចនឹងកើតឡើងដែលបណ្តាលមកពីបទល្មើសដែលស្ថិតក្រោមការចោទប្រកាន់។ ឧក្រិដ្ឋកម្មកាកសំណល់តាមធម្មជាតិរបស់វា អាចជះឥទ្ធិពលអវិជ្ជមានយូរអង្វែងទៅលើបរិស្ថាននិងសុខភាពមនុស្ស។

# ជំពូក ៣ ការស៊ើបអង្កេត និងការប្រមូលភស្តុតាង

## ៣.១ ការស៊ើបអង្កេត

ជំហានដំបូងនៃការស៊ើបអង្កេត គឺត្រូវកំណត់ថាតើមានការរំលោភបំពានច្បាប់ដែរឬទេ។ នៅក្នុងបរិបទនៃការដឹកជញ្ជូនកាកសំណល់ វា ច្រើនតែកើតឡើងនៅចំណុចនៃការនាំចេញឬនាំចូល។ នៅក្នុងដែនយុត្តាធិការភាគច្រើន ការដឹកជញ្ជូនកាកសំណល់នឹងតម្រូវឱ្យមានការយល់ព្រមនិងការអនុញ្ញាតសម្រាប់ប្រភេទនិងចំណាត់ថ្នាក់ជាក់លាក់នៃកាកសំណល់ដែលគេនឹងគ្រប់គ្រង កែច្នៃ ឬបោះចោល។

បទល្មើសឯកសារ ទំនងជាប្រភេទនៃបទល្មើសដែលងាយសម្គាល់បំផុត។ នៅក្នុងបទល្មើសទាំងនេះ ឧក្រិដ្ឋជនកំពុងចៀសវាងមិនប្រើមធ្យោបាយនានាដែលមានគោលបំណងការពារបរិស្ថាន។ វា គឺជាបទល្មើសដែលបង្កឡើងដោយមានការធ្វេសប្រហែសឬដោយមានចេតនាក្លែងបន្លំ ឬបោកបញ្ឆោត ក្នុងការពិពណ៌នាអំពីភាគីពាក់ព័ន្ធនឹងប្រតិបត្តិការកាកសំណល់ ការពិពណ៌នាអំពីកាកសំណល់ឬបរិមាណនៃកាកសំណល់ ឬសិទ្ធិអំណាចស្របច្បាប់របស់កន្លែងគ្រប់គ្រងកាកសំណល់។ ចំពោះបញ្ហាទាំងអស់នេះ នៅក្នុងបទប្បញ្ញត្តិក្រោមសន្ធិបាត Basel គេ តម្រូវឱ្យបង្ហាញលិខិតនៃការយល់ព្រមដោយបានជូនដំណឹងជាមុន ហើយប្រសិនបើ មានកំហុស ឬមានការក្លែងបន្លំព័ត៌មានមែន ទង្វើទាំងនេះ នឹងបង្កើតឱ្យមានបទល្មើស ដោយយោងតាមច្បាប់ជាតិ។

ការដឹកជញ្ជូននិងការគ្រប់គ្រងកាកសំណល់[2] ត្រូវមានលិខិតអនុញ្ញាតនិងការយល់ព្រមត្រឹមត្រូវតាមច្បាប់។ ទាំងនេះ ក៏អាចនឹងបង្កឲ្យមានបទល្មើសឯកសារផងដែរ ប៉ុន្តែក៏អាចបង្កើតឱ្យមានបទល្មើសកើតឡើងជាក់ស្តែងនៅពេលដែលអ្នកដឹកជញ្ជូនឬអ្នកគ្រប់គ្រងកាកសំណល់មិនមានសិទ្ធិអំណាចស្របច្បាប់ក្នុងការដឹកជញ្ជូនឬគ្រប់គ្រងកាកសំណល់នោះ។ ភាគីពាក់ព័ន្ធក្នុងរឿងនេះ ក៏អាចជាផ្នែកមួយនៃក្រុមឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងផងដែរ។ រឿងនេះ ផ្តល់នូវឱកាសសម្រាប់អនុវត្តមធ្យោបាយនៃការស៊ើបអង្កេតឲ្យល្អប្រសើរឡើង ហើយ វា ក៏មានន័យថាបទល្មើស អាចនឹងមានលក្ខណៈធ្ងន់ធ្ងរជាងមុនផងដែរ។

ប្រភេទចុងក្រោយនៃបទល្មើសពាក់ព័ន្ធ គឺបទល្មើសដែលបង្កអន្តរាយដល់បរិស្ថាន។ បទល្មើសទាំងនេះ អាចបណ្តាលមកពីសកម្មភាពដែលអនុញ្ញាតដោយច្បាប់និងស្របច្បាប់ ប៉ុន្តែដោយសារតែឧប្បត្តិហេតុនានា ការធ្វេសប្រហែសឬទង្វើដោយចេតនា ដែលអាចធ្វើឱ្យមានការក្រពប់ឬបោះចោលកាកសំណល់ដែលអាចបង្កការខូចខាតដល់បរិស្ថាន។ ព្រឹត្តិការណ៍ទាំងនេះ តែងតែត្រូវបានចែងនៅក្រោមច្បាប់ជាតិ ប្រសិនបើព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងទឹកដីរបស់ជាតិឬដែនយុត្តាធិការរបស់ប្រទេសដែលទទួលកាកសំណល់។ ប្រសិនបើមានគ្រោះថ្នាក់ដល់បរិស្ថានកើតឡើងនៅឯនាយសមុទ្រ វាអាចស្ថិតនៅក្រោមច្បាប់អន្តរជាតិនានាដែលពាក់ព័ន្ធ។

[2] អាចនឹងរួមបញ្ចូល ការរក្សាទុក ការសម្អាត ឬការបោះចោលកាកសំណល់ផងដែរ

ទាក់ទងនឹងបទល្មើសនៃដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ សូចនាករដំបូងនៃបទល្មើស ទំនងជារកឃើញនៅពេលដែលមន្ត្រីគយឬភ្នាក់ងារត្រួតពិនិត្យព្រំដែនផ្សេងទៀតពិនិត្យមើលឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយទំនិញកាកសំណល់។ កិច្ចសហការជិតស្និទ្ធរវាងមន្ត្រីគយនិងមន្ត្រីស៊ើបអង្កេតនិងមន្ត្រីអយ្យការដទៃទៀត មានលក្ខណៈចាំបាច់ណាស់ដើម្បីកំណត់អំពីលទ្ធភាពនិងភាពធ្ងន់ធ្ងរនៃបទល្មើសដែលអាចកើតមាន។

នៅពេលគេដឹងច្បាស់ថាឯកសារមានឬទំនងជាមានកំហុស ហើយថាត្រូវតែមានការស៊ើបអង្កេតបន្ថែមទៀត មន្ត្រីគយ គប្បីជូនដំណឹងដល់ក្រសួងពាក់ព័ន្ធនិងអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ដើម្បីកំណត់វិធានការជាបន្តបន្ទាប់ក្នុងការស៊ើបអង្កេត។

អ្វីដែលសំខាន់នោះ គឺមន្ត្រីជំនាញអាចចូលមើលទិន្នន័យមួយចំនួនទាក់ទងនឹងការដឹកទំនិញនោះ ហើយក៏អាចពិនិត្យមើលវត្ថុដែលមាននៅក្នុងទូរកុងតឺន័រដើម្បីកំណត់វិធានការបន្ទាប់។

ការដឹកកាកសំណល់ដោយខុសច្បាប់ ជារឿយៗអាចត្រូវបានរកឃើញដោយការពិនិត្យឡើងវិញនូវព័ត៌មានដែលមាននៅក្នុងបញ្ជីនៃការដឹកជញ្ជូន។ ព័ត៌មានដែលទទួលបានពីទីភ្នាក់ងារដៃគូ ក៏មានប្រយោជន៍ផងដែរក្នុងការកសាងសាវតានៃការដឹកជញ្ជូន ដើម្បីកំណត់មុខសញ្ញាជួញដូរកាកសំណល់ខុសច្បាប់។ ជាឧទាហរណ៍ ក្រុមហ៊ុនដែលជាប់ទាក់ទងក្នុងការដឹកជញ្ជូនខុសច្បាប់ឬមានបញ្ហា ត្រូវបានគេកំណត់គោលដៅដើម្បីធ្វើការត្រួតពិនិត្យដូចជាការដឹកជញ្ជូនដែលមានទម្រង់តាមការពិពណ៌នាខាងលើ។ ជារឿយៗការដឹកជញ្ជូនបែបនេះក៏ដូចជាការដឹកទំនិញដែលមានសាវតាដូចដែលបានរៀបរាប់ខាងលើផងដែរ ត្រូវបានគេដាក់មុខសញ្ញាដើម្បីធ្វើអធិការកិច្ច ។ ជាទូទៅ ការដឹកជញ្ជូនបែបនេះ ត្រូវបានរកឃើញដោយមានកិច្ចសហការជាមួយអាជ្ញាធរត្រួតពិនិត្យក្រៅប្រទេស និងត្រូវបានត្រួតពិនិត្យបន្ថែមប្រកបដោយប្រសិទ្ធភាពដោយការធ្វើអធិការកិច្ចដោយជាទូទៅមិនចំពោះ។

ទំនាក់ទំនងរវាងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ប្រទេសនាំចូល និងប្រទេសដែលកាកសំណល់ឆ្លងកាត់ មានភាពចាំបាច់ណាស់ ហើយអាចជួយក្នុងការស្វែងរក ទប់ស្កាត់ និងត្រួតពិនិត្យចរាចរណ៍កាកសំណល់គ្រោះថ្នាក់ដោយខុសច្បាប់ ។ ការប្រាស្រ័យទាក់ទងគ្នាជាផ្លូវការនិងក្រៅផ្លូវការ អាចត្រូវបានប្រើ ហើយក្នុងនោះរួមមានសារអ៊ីម៉ែលដែលជួយសម្រួលឲ្យការទាក់ទងគ្នាបានយ៉ាងឆាប់រហ័សផងដែរ។ អង្គការគយពិភពលោកបានផ្តួចផ្តើមបង្កើតបណ្តាញមួយដែលមានឈ្មោះថាបណ្តាញអនុវត្តច្បាប់គយ(CEN)នៅខែកក្កដាឆ្នាំ២០០០។ គោលបំណងនៃបណ្តាញនេះ គឺដើម្បីផ្សាភ្ជាប់រដ្ឋបាលគយទាំងអស់ក្នុងគោលបំណងអនុវត្តច្បាប់និងផ្តល់ឱ្យពួកគាត់នូវប្រព័ន្ធទិន្នន័យរួមនិងប្រព័ន្ធយោងមួយ។ រាល់រដ្ឋបាលគយជាតិ គួរតែបានភ្ជាប់ជាមួយបណ្តាញ CEN តាមរយៈមន្ត្រីទំនាក់ទំនងថ្នាក់ជាតិ។ តាមរយៈការប្រើប្រាស់បណ្តាញ CEN រដ្ឋបាលគយថ្នាក់ជាតិ អាចមានលទ្ធភាពចូលក្នុងប្រព័ន្ធទិន្នន័យភ្លាមៗដែលមាននូវរាល់ករណីទាំងអស់នៃចរាចរណ៍ខុសច្បាប់នៃកាកសំណល់គ្រោះថ្នាក់។

ប្រភពមួយទៀតនៃព័ត៌មានចារកម្មនិងព័ត៌មានដែលមានប្រយោជន៍នានាអំពីសំណុំរឿងពីមុនៗទាក់ទងនឹង ចរាចរណ៍ខុសច្បាប់នៃកាកសំណល់គ្រោះថ្នាក់និងវិធីសាស្រ្តរបស់ប្រតិបត្តិការខុសច្បាប់ គេ អាចទទួលបានពី អង្គការ Interpol តាមរយៈការិយាល័យកណ្តាលថ្នាក់ជាតិ។

ជារឿយៗការស៊ើបអង្កេត នឹងត្រូវធ្វើឡើងដោយចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័នអនុវត្តច្បាប់ និងភ្នាក់ងារគយនៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។ ការធ្វើដូចនេះ អាចដោះស្រាយបញ្ហាជាក់ស្តែងទាំងក្នុងស្រុកនិងអន្តរជាតិ។ នៅពេលដែលទំនិញ ត្រូវបានដឹកទៅកាន់ប្រទេសដែលនៅឆ្ងាយ អាជ្ញាធរមានសមត្ថកិច្ចឬអង្គភាពស៊ើបអង្កេតផ្សេងទៀត អាចត្រូវការភស្តុតាងពីអាជ្ញាធរនៅក្នុងប្រទេសគោលដៅ។ លើសពីនេះទៀត វា ជារឿងចាំបាច់ក្នុងការទទួលបានភស្តុតាងពីស្ថាប័នទាំងនេះ ក្នុងនោះមានដូចជាសេចក្តីថ្លែងរបស់សាក្សី រូបថតឬវីដេអូ ការធ្វើសំណាកគំរូ (ដើម្បីបង្ហាញពីលក្ខណៈគ្រោះថ្នាក់នៃកាកសំណល់) និងការធ្វើតេស្ត (ដើម្បីបង្ហាញថាវត្ថុជាក់លាក់ដូចជាទូរទឹកកកឬទូរទស្សន៍ ខូចពិតមែន) ដែលទាំងនេះអាចបង្កើនការចំណាយពេលវេលា ថវិការ និងភាពស្មុគស្មាញក្នុងការរៀបចំសំណុំរឿង។

ក្នុងករណីខ្លះ ការត្រួតពិនិត្យការដឹកជញ្ជូនខុសច្បាប់ដែលគួរឲ្យសង្ស័យនៅពេលមកដល់កន្លែងរបស់អ្នកនាំចូលកាកសំណល់ មានភាពងាយស្រួលជាងនៅកំពង់ផែឬច្រកព្រំដែន។ ក្នុងករណីនេះ មន្ត្រីអធិការកិច្ចអាចចង់ត្រួតពិនិត្យឧបករណ៍និងដំណើរការនៅកន្លែងរបស់អ្នកនាំចូលកាកសំណល់ផ្ទាល់តែម្តង ដើម្បីវាយតម្លៃថាតើវាត្រឹមត្រូវស្របតាមប្រតិបត្តិការនៃការកែច្នៃនិង/ឬការបោះចោលកាកសំណល់ដែលបានចែងនៅក្នុងអាជ្ញាប័ណ្ណ/លិខិតរបស់ពួកគេដែរឬទេ។ លក្ខខណ្ឌសម្រាប់ទំនិញមិនជាប់ពន្ធ អាចត្រូវបានបង្កើតឡើង ដូច្នេះនៅតាមព្រំដែន មន្ត្រីអធិការកិច្ចផ្នែកបរិស្ថាន អាចផ្ទៀងផ្ទាត់ឯកសារដែលទាក់ទងនឹងកាកសំណល់គ្រោះថ្នាក់បាន (Conference of the Parties "Guidance Elements for Detection, Prevention and Control of Illegal Traffic in Hazardous Wastes, p.17)។

ការដឹកកាកសំណល់ដោយខុសច្បាប់ អាចត្រូវបានរកឃើញ៖

- ក្នុងអំឡុងពេលត្រួតពិនិត្យការដឹកជញ្ជូន (អធិការកិច្ចនៅកំពង់ផែឬតាមផ្លូវ)
- ក្នុងអំឡុងពេលត្រួតពិនិត្យឯកសាររបស់អ្នកផលិតកាកសំណល់។
- ក្នុងកំឡុងពេលត្រួតពិនិត្យកន្លែងកែច្នៃកាកសំណល់។
- ក្នុងកំឡុងពេលធ្វើអធិការកិច្ចកន្លែងស្តុកទំនិញ/កន្លែងចតនាវា។
- នៅក្នុងបរិបទដែលមានគ្រោះថ្នាក់ឬបញ្ហានៅទីតាំងផ្ទាល់
- ផ្អែកលើមូលដ្ឋានរបាយការណ៍គេបញ្ជូនមកកាន់អាជ្ញាធរឬប៉ូលីស(IMPEL, 2008)។

យុទ្ធសាស្រ្តក្នុងការស៊ើបអង្កេត (Dotcom Waste Toolkit, 2017) ចំពោះបទឧក្រិដ្ឋពាក់ព័ន្ធ មានដូចតទៅ៖

- ការកំណត់ប្រភេទកាកសំណល់ (ការធ្វើចំណាត់ថ្នាក់)
- កំណត់បរិមាណនៃកាកសំណល់
- កំណត់ពីលទ្ធភាពនៃការស្វែងរកឃើញ (ភាគីដែលទទួលខុសត្រូវ ប្រភព និងគោលដៅនៃកាកសំណល់)
- កំណត់នូវផលចំណេញឬប្រាក់សន្សំបានពីការចំណាយដោយខុសច្បាប់
- កំណត់នូវការខូចខាតដល់បរិស្ថាន ប្រសិនបើមានសេចក្តីជូនដំណឹងណាមួយ

## ៣.២ ការប្រមូលភស្តុតាង

គេត្រូវចងចាំជានិច្ចថានីតិវិធីត្រឹមត្រូវសម្រាប់ការប្រមូលភស្តុតាង ការប្រមូលឯកសារ និងការសម្ភាសសាក្សី មានសារៈសំខាន់ណាស់ ប្រសិនបើគេចង់ការទទួលបានជោគជ័យក្នុងការកាត់ទោសដែលនឹងធ្វើឡើងក្រោមដែនយុត្តាធិការពាក់ព័ន្ធ។ ការប្រមូលភស្តុតាង ត្រូវតែស្របតាមច្បាប់ជាតិ ហើយព្រះរាជអាជ្ញា មានតួនាទីសំខាន់ក្នុងការជួយមន្ត្រីគយនិងអាជ្ញាធរស៊ើបអង្កេតដទៃទៀតដោយផ្តល់ការណែនាំស្តីពីការចាត់ចែងនិងការប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធនឹងបទល្មើស។

ការប្រមូលភស្តុតាងនិងការស៊ើបអង្កេតសម្រាប់បទល្មើសព្រហ្មទណ្ឌ អាចចំណាយពេលវេលាឬចំណាយថវិកាច្រើន។ វា ជារឿងសំខាន់ណាស់ដែលព្រះរាជអាជ្ញា មន្ត្រីគយ និងអាជ្ញាធរពាក់ព័ន្ធធ្វើការរួមគ្នាដើម្បីធ្វើការកំណត់ឱ្យបានឆាប់នូវប្រភេទនិងភាពធ្ងន់ធ្ងរនៃបទល្មើស។ ភស្តុតាង អាចរាប់ចាប់ពីការបង្ហាញពីគ្រោះថ្នាក់ដល់បរិស្ថានរហូតដល់ការបង្ហាញថាការដឹកជញ្ជូនត្រូវនោះ ត្រូវបានគេធ្វើចំណាត់ថ្នាក់ខុស (ដូចជាករណីផ្សេងៗនៃការចៀសវាងមិនប្រើវិធានការការពារបរិស្ថាន អាចបណ្តាលឲ្យមានអន្តរាយដល់បរិស្ថាន ប៉ុន្តែអន្តរាយនោះ មិនទាន់កើតឡើងជាក់ស្តែងនៅឡើយ) ។ ព្រះរាជអាជ្ញា គប្បីស្គាល់នូវគោលនយោបាយអនុលោមតាមច្បាប់សម្រាប់ឧក្រិដ្ឋកម្មបរិស្ថាន ដើម្បីអនុវត្តនីតិវិធីមិនមែនព្រហ្មទណ្ឌបានសមរម្យ ប្រសិនបើបទល្មើសនោះ មិនមានភាពធ្ងន់ធ្ងរដែលបង្កផលប៉ះពាល់តិចតួចដល់បរិស្ថាន ឬប្រសិនបើមានដំណោះស្រាយផ្នែករដ្ឋបានសមរម្យណាមួយ។

### ការប្រមូលឯកសារ

នៅពេល មានលទ្ធភាពនៃការរំលោភបំពានច្បាប់ គេ នឹងចាប់ផ្តើមអនុវត្តនីតិវិធីអធិការកិច្ចដោយការប្រមូលឯកសារទាំងអស់ដែលទាក់ទងនឹងការដឹកជញ្ជូនឬការផលិតកាកសំណល់ ឯកសារដែលទាក់ទងនឹងផែនការនាំចេញ/នាំចូលកាកសំណល់ ឯកសារដែលទាក់ទងនឹងសកម្មភាពកែច្នៃកាកសំណល់និងកន្លែងបោះចោលកាកសំណល់ និងឯកសារផ្សេងទៀតដែលអាចជាមានសារៈប្រយោជន៍ (ដូចជាកំណត់ត្រាព័ត៌មានអំពីអ្នកនាំចេញ

កាកសំណល់ ក្រុមហ៊ុនដឹកជញ្ជូន អ្នកនាំចូលកាកសំណល់ ។ល។)។ ឯកសារទាំងនេះភាគច្រើន ទទួលបានពីអាជ្ញាធរគយ ហើយអាចត្រូវបានប្រមូលនិងត្រួតពិនិត្យដោយស្របច្បាប់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ជំហានខាងក្រោមមានចែងនៅក្នុងសៀវភៅណែនាំរបស់អង្គការ INTERPOL ស្តីអំពីការស៊ើបអង្កេតឧក្រិដ្ឋកម្មបំពុលបរិស្ថានចុះនៅឆ្នាំ២០១៤ (ភាគ ១ និងភាគទី ២) ដើម្បីប្រមូលឯកសារក្នុងករណីមានការសង្ស័យថាមានបទល្មើសឬក្នុងករណីមានបទល្មើសដែលបានចែងក្នុងនោះ៖

- ផ្តួចផ្តើមការត្រួតពិនិត្យផ្នែករដ្ឋបាលឬត្រួតពិនិត្យសារាចរនានាដែលអនុញ្ញាតដោយច្បាប់ក្នុងស្រុកចំពោះការរក្សាទុក បោះចោល ឬនាំចេញកាកសំណល់ឱ្យបានត្រឹមត្រូវ។
- បង្កើតការត្រួតពិនិត្យឯកសារឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ក្នុងរយៈពេល ២៤ ម៉ោង) ដើម្បីកំណត់ថាតើសំណុំរឿងនោះពាក់ព័ន្ធតែក្រុមហ៊ុនក្នុងស្រុកដែលបានផ្ញើឬទទួលកាកសំណល់ឬទេ ឬកំណត់ថាតើសំណុំរឿងនោះ ពាក់ព័ន្ធនឹងក្រុមហ៊ុនបរទេសឬទេ ហើយថាតើត្រូវត្រួតពិនិត្យនៅបរទេសបន្ថែមដោយមានជំនួយពីរដ្ឋាភិបាលបរទេសនិង/ឬអង្គការអន្តរជាតិដូចជា INTERPOL ដែរឬទេ ។
- វាយតម្លៃលើច្បាប់ក្នុងតំបន់ដែលអាចយកមកអនុវត្តបានសម្រាប់ជម្រើសផ្លូវច្បាប់ណាមួយ(ដូចជាការចោទប្រកាន់)ឬការពិន័យឬវិធានការផ្នែករដ្ឋបាលដូចជាបទបញ្ជាឬការផាកពិន័យផ្នែករដ្ឋប្បវេណី។

## អធិការកិច្ចដោយភ្នែកផ្ទាល់ និងការធ្វើសំណាកគំរូ

បន្ទាប់ពីប្រមូលនិងត្រួតពិនិត្យឯកសារហើយ ចាំបាច់ត្រូវធ្វើអធិការកិច្ចដោយភ្នែកផ្ទាល់លើកាកសំណល់ឬទូកុងតឺន័រកាកសំណល់។ បុគ្គលដែលចុះធ្វើអធិការកិច្ច គួរតែមានការប្រុងប្រយ័ត្នត្រឹមត្រូវ ហើយការធ្វើអធិការកិច្ច គួរតែធ្វើឡើងដោយមន្ត្រីអធិការកិច្ចដែលទទួលបានការអនុញ្ញាត។ ជាឧទាហរណ៍ គេ គប្បីពាក់ស្បែកជើងបិទជិតជាមួយមួកដែក នៅកន្លែងដាក់ទំនិញ។ គេ ត្រូវប្រុងប្រយ័ត្ន នៅពេលបើកទូកុងតឺន័រ ក្នុងករណីដែលគេ ប្រហែលជាបានផ្លាស់ប្តូរទំនិញនៅកន្លែងផ្ទេរទំនិញ។ គប្បីពាក់ឧបករណ៍ការពារដំណកដង្ហើមនិងស្រោមដៃ ប្រសិនបើមានហានិភ័យនៃការប៉ះពាល់ល្អងធូលីដែលមានគ្រោះថ្នាក់។

ក្នុងករណីខ្លះ នៅពេលត្រួតពិនិត្យមើលបានគ្រប់គ្រាន់ហើយ គេ ចាំបាច់ត្រូវធ្វើសំណាកគំរូដើម្បីកំណត់លក្ខណៈគ្រោះថ្នាក់នៃកាកសំណល់។ ការធ្វើសំណាកគំរូ គួរតែត្រូវបានធ្វើឡើងស្របតាមការណែនាំពាក់ព័ន្ធដែលផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចនិងស្របតាមលក្ខខណ្ឌផ្តល់ដោយអាជ្ញាធរទទួលបន្ទុកចោទប្រកាន់។ ឧទាហរណ៍ស្តីពីការយកគំរូ ត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធនានាស្តីពី*ធាតុផ្សំនៃសេចក្តីណែនាំសម្រាប់ការស្វែងរក ការទប់ស្កាត់ និងការត្រួតពិនិត្យលើចរាចរណ៍ខុសច្បាប់នូវកាកសំណល់គ្រោះថ្នាក់* (COP Basel 6th Meeting)។ ដូចគ្នានឹងអធិការកិច្ចដោយភ្នែកផ្ទាល់ដែរ គេ ត្រូវមានការប្រុងប្រយ័ត្នឲ្យបានគ្រប់គ្រាន់អំពីបញ្ហាសុវត្ថិភាពគ្រប់ពេលវេលា ហើយសំណាកគំរូ គប្បីតែត្រូវបានធ្វើឡើងដោយអាជ្ញាធរដែលទទួលបានការអនុញ្ញាតតែប៉ុណ្ណោះ។

ជំហានខាងក្រោម ត្រូវបានពិពណ៌នានៅក្នុងសៀវភៅណែនាំអំពីការស៊ើបអង្កេតកោសល្យវិច្ច័យចំពោះឧក្រិដ្ឋកម្មបំពុលបរិស្ថានរបស់អង្គការINTERPOL ចុះនៅឆ្នាំ ២០១៤ (ភាគ ១ និងភាគ ២) ដើម្បីប្រមូលភស្តុតាងនៅនឹងកន្លែងជាពិសេសទាក់ទងនឹងការចោលកាកសំណល់ដែលមានគ្រោះថ្នាក់៖

- ត្រូវប្រមូលភស្តុតាងឲ្យបានសមស្របដើម្បីវាយតម្លៃអំពីការរំលោភបំពានច្បាប់និង/ឬការផ្ទុក ការរក្សាទុក និងការសម្អាតកាកសំណល់។ ត្រូវស្វែងរកកំណត់ត្រាពាក់ព័ន្ធនឹងកាកសំណល់ និងត្រូវកំណត់ប្រភេទកាកសំណល់។
- ត្រូវកំណត់ប្រភេទឧបករណ៍យកសំណាកគំរូនិងប្រដាប់ដាក់សំណាកគំរូ ដែលត្រូវមាន។
- ត្រូវណែនាំបុគ្គលដែលត្រូវធ្វើសំណាកគំរូ(អ្នកអន្តរាគមនចំពោះសារធាតុគ្រោះថ្នាក់)អំពីវិធីនិងកន្លែងដែលត្រូវយកសំណាកគំរូ។
- ត្រូវប្រមូលសំណាកគំរូ។
- បញ្ជូនសំណាកគំរូ (កាកសំណល់ ដី ទឹក។ ល។ )ដើម្បីធ្វើការវិភាគដាក់លាក់ថាតើគេស្គាល់សមាសធាតុនៃកាកសំណល់នោះឬទេ។
- ត្រូវដាក់សញ្ញា GPS និងថតរូបកន្លែងកើតហេតុនិងភស្តុតាងនីមួយៗដែលភ្ជាប់មកជាមួយទូរកុងតឺន័រដែលការធ្វើដូចនេះ អាចជួយកំណត់អត្តសញ្ញាណប្រភពកាកសំណល់ឬម្ចាស់កាកសំណល់នាពេលបច្ចុប្បន្នឬអតីតកាល (សម្រាប់ព័ត៌មានបន្ថែម សូមមើលសិក្ខាសាលាអនឡាញDOTCOM Waste ស្តីអំពីការប្រើបច្ចេកវិទ្យាចាប់រលកសញ្ញាពីចម្ងាយក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មកាកសំណល់ខុសច្បាប់) ។
- ត្រូវប្រមូលភស្តុតាងជាឯកសារនិងក្រដាសដែលអាចត្រូវបានបន្សល់ទុកនៅកន្លែងកើតហេតុដែលវាអាចបញ្ជាក់ពីសារជាតុនានានៃកាកសំណល់ឬអំពីម្ចាស់កម្មសិទ្ធិនៃកាកសំណល់។
- ត្រូវស្វែរកឯកសារច្បាប់ថតចម្លងនៃកំណត់ត្រាប្រតិបត្តិការរោងចក្រ។

ទំនួលខុសត្រូវចំពោះការចំណាយលើការស៊ើបអង្កេតនិងការកាត់ទោសបទឧក្រិដ្ឋបរិស្ថាន ដែលរួមមានការចំណាយលើការធ្វើតេស្តនិងការវិភាគផ្នែកវិទ្យាសាស្ត្រ គឺអាស្រ័យលើដែនយុត្តាធិការជាតិនីមួយៗ។ ខណៈពេលដែលនៅក្នុងប្រទេសមួយចំនួន ការចំណាយទាំងនេះ គឺជាបន្ទុករបស់ភាគីដែលល្មើសច្បាប់ ហើយនៅក្នុងប្រទេសផ្សេងទៀត ការចំណាយទាំងនេះ គឺជាបន្ទុករបស់អាជ្ញាធរជាតិ។

ក្នុងករណីទាំងអស់នៃការធ្វើអធិការកិច្ច ប្រសិនបើមានសញ្ញាណនៃបទល្មើសដែលអាចកើតឡើង អ្នកស៊ើបអង្កេត គប្បីចងចាំថាគោលបំណងនៃការធ្វើអធិការកិច្ច គឺដើម្បីប្រមូលភស្តុតាងដើម្បីកំណត់ថាតើមានការរំលោភបំពានលើច្បាប់ឬទេ។ នៅក្នុងយុត្តាធិការជាច្រើន តុលាការ នឹងទទួលកាត់ទោសសំណុំរឿងតែក្នុងករណីដែលជាភស្តុតាងដែលគេបានប្រមូលស្របតាមវិធាននៃភស្តុតាងតែប៉ុណ្ណោះ។ ភស្តុតាងពីអ្នកស៊ើបអង្កេត ត្រូវតែមានលក្ខណៈពេញលេញតាមដែលអាចធ្វើបាន។ ការប្រើប្រាស់ទូរស័ព្ទដើម្បីយកភស្តុតាងនិងដើម្បីថតរាល់ការ

សន្ធនា អាចមានប្រយោជន៍ខ្លាំងណាស់សម្រាប់ព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីដែលការថត(សម្លេងឬវីដេអូ) និងការថតរូបនោះ ត្រូវបានធ្វើឡើងដោយស្របតាមច្បាប់ផងដែរ។

## ៣.៣ ការការពារភស្តុតាង

ភស្តុតាងដែលរួមទាំងឯកសារអំពីកាកសំណល់និងកំណត់ត្រាសំណាកគំរូ ត្រូវតែបានការពារក្នុងកំឡុងពេលជំនុំជម្រះក្តីព្រហ្មទណ្ឌ។ នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចនិងព្រះរាជអាជ្ញា សម្រេចថាសំណុំរឿង ត្រឹមត្រូវតាមលក្ខខណ្ឌនៃកម្រិតតេស្តដែលអាចចាប់ផ្តើមវិធានការរដ្ឋប្បវេណីឬព្រហ្មទណ្ឌហើយ គេ ចាំបាច់ត្រូវតែរក្សាភស្តុតាង ទុក។

ប្រសិនបើកាកសំណល់ (ជាពិសេសវត្ថុធាតុដើមដែលអាចកែច្នៃឡើងវិញបានហើយដែលមានតម្លៃផ្នែកសេដ្ឋកិច្ច) នៅតែជាកម្មសិទ្ធិស្របច្បាប់របស់ក្រុមហ៊ុននាំចេញឬនាំចូលកាកសំណល់ ប៉ុន្តែប្រសិនបើក្រុមហ៊ុននោះបដិសេធមិនអនុវត្តតាមការស្នើសុំឱ្យប្រគល់កាកសំណល់មកវិញទេ អាជ្ញាធររដ្ឋាភិបាល អាចប្រឈមនឹងការលំបាកក្នុងការរឹបអូសកាកសំណល់នោះ។ ការលំបាកដែលរដ្ឋាភិបាលជួបប្រទះក្នុងការរឹបអូសនិងចល័តកាកសំណល់ ត្រូវបានដោះស្រាយតាមរយៈបទប្បញ្ញត្តិនានានៅក្នុងច្បាប់ជាតិ។ វា ជារឿងចាំបាច់ក្នុងការស្វែងរកសុំដីកាពីតុលាការដើម្បីបញ្ជាក់ថាអ្នកណាជាអ្នកទទួលខុសត្រូវចំពោះកាកសំណល់ក្នុងអំឡុងពេលដំណើរការជំនុំជម្រះក្តី។

វាជាការសំខាន់ណាស់ដែលវត្ថុធាតុនៃកាកសំណល់ទាំងនោះ ត្រូវបានរក្សាទុកដោយសុវត្ថិភាពក្នុងអំឡុងពេលនៃការស៊ើបអង្កេតលើចរាចរណ៍កាកសំណល់ដោយខុសច្បាប់។ ជាពិសេស គេ ត្រូវតែពិចារណាចំពោះការការពារសុខភាពមនុស្សនិងការការពារបរិស្ថាន ការការពារខ្សែសង្វាក់នៃការរក្សាទុកភស្តុតាង និង ការចៀសវាងពីការទាមទារណាមួយរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការបំផ្លាញវត្ថុធាតុនៃកាកសំណល់របស់ពួកគេ។

វា ក៏សំខាន់ផងដែរនៅពេលធ្វើសំណាកគំរូ។ វត្ថុធាតុនៃកាកសំណល់ ប្រហែលជាត្រូវតែរក្សាទុកដាច់ដោយឡែកពីកាកសំណល់ផ្សេងទៀត។ ការយកសំណាកគំរូពីផ្នែកផ្សេងៗគ្នានៃទូរកុងតឺន័រ អាចនឹងផ្តល់លទ្ធផលខុសគ្នាដោយសារតែការលាយឡំនិងល្បាយមិនស្មើគ្នានៃវត្ថុនានានៅក្នុងកាកសំណល់។

ប្រសិនបើសំណាកគំរូ ត្រូវបានប្រើដើម្បីធ្វើជាមូលដ្ឋាននៃការស្វែងរកអង្គហេតុអំពីសមាសធាតុនៃកាកសំណល់ ឬការបំពុលនៃកាកសំណល់ សំណាកគំរូនោះ គួរតែត្រូវបានការពារនិងរក្សាទុកប្រកបដោយសុវត្ថិភាព។

## ៣.៤ ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ

ការអនុវត្តន៍បច្ចេកទេសស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុនៅក្នុងសំណុំរឿងឧក្រិដ្ឋកម្មបរិស្ថាននិងកាកសំណល់ អាចមានភាពចាំបាច់ដើម្បីបង្កើតយុទ្ធសាស្ត្រស៊ើបអង្កេតប្រកបដោយជោគជ័យ។[3] ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុអាចមានកម្មវត្ថុពីរ គឺដើម្បីបង្ហាញថាមានបទឧក្រិដ្ឋឬទេ និង/ឬដើម្បីវាយតម្លៃនិងស្វែងរកផលនៃបទឧក្រិដ្ឋ។

អង្គការអន្តរជាតិនានាដូចជា អង្គការ Europol អាចជួយក្នុងសំណុំរឿងឧក្រិដ្ឋកម្មបរិស្ថានឆ្លងដែនទូទៅ ហើយជាពិសេសទាក់ទងនឹងព័ត៌មានចារកម្មហិរញ្ញវត្ថុ ការវិភាគ និងជំហាននៃការស៊ើបអង្កេត ក្នុងចំណោមជំនួយដទៃទៀត តាមរយៈការផ្ទៀងផ្ទាត់នៅក្នុងប្រព័ន្ធទិន្នន័យ ការវិភាគលើប្រតិបត្តិការហិរញ្ញវត្ថុដែលគួរឱ្យសង្ស័យ ការរៀបចំប្រតិបត្តិការឆ្លងកាត់ព្រំដែន ការប្រើប្រាស់ដំណោះស្រាយផ្នែកបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតដូចជាឧបករណ៍ទាញយកកោសល្យវិច្ច័យជាសកល (Universal Forensic Extraction Device) និងការិយាល័យចល័តរបស់អង្គការ Europol (Europol Mobile Office) ។ ល។

ជំហានពាក់ព័ន្ធមួយចំនួននៅក្នុងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ មានដូចតទៅ៖

- ការវិភាគអំពីការទូទាត់ប្រាក់ជាក់លាក់ណាមួយ
- ការវិភាគអំពីចំណូល និងចំណាយ (វិធីសាស្ត្របង្ហាញប្រាក់ចំណូលខុសច្បាប់ដោយប្រយោល)
- ការវិភាគអំពីប្រតិបត្តិការហិរញ្ញវត្ថុក្លែងបន្លំ
- ការវិភាគផ្តោតលើ ការស្វែងរកទ្រព្យសកម្ម
- ការវិភាគអំពីភាពខុសគ្នារវាងការចំណាយលើការគ្រប់គ្រងកាកសំណល់ដែលបានប្រកាស និងការចំណាយលើការគ្រប់គ្រងកាកសំណល់តាមបទដ្ឋាន
- ការវាយតម្លៃហានិភ័យ

## ៣.៥ បញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា

វា មានសារៈសំខាន់ដែលអ្នកស៊ើបអង្កេត ត្រូវបង្កើតយុទ្ធសាស្ត្រសមស្របនានាដើម្បីកំណត់ស្វែងរកភស្តុតាងឌីជីថលនិងដើម្បីរក្សាទុកនិងបកស្រាយភស្តុតាងទាំងនោះ។ ដោយមិនគិតពីទំហំឬភាពស្មុគស្មាញ អ្នកស៊ើបអង្កេតគប្បីពិចារណាចំពោះដំណាក់កាលបឋមចំនួនប្រាំ។

- ការទាញយកទិន្នន័យ និងការឆែកឆេរ និងការរឹបអូសនៅកន្លែងកើតហេតុ
- ការធ្វើតេស្តទិន្និន័យ
- ការបើកស្រាយទិន្នន័យ

[3] សិក្ខាសាលាតាមអនឡាញរៀបចំជាពិសេសអំពីប្រធានបទនេះដោយអង្គការ CEPOL, https://www.cepol.europa.eu/education-training/what-we-teach/webinars/webinar-302019-financial-investigations-environmental និងកាកសំណល់ DOTCOM Waste, https://dotcomproject.eu/pro-active-financial-investigation/

- ការរៀបចំរបាយការណ៍ទិន្នន័យ
- ការសម្ភាសសាក្សី និងជនសង្ស័យ

ការប្រមូលទិន្នន័យឌីជីថល គប្បីត្រូវបានពិចារណានៅក្នុងក្របខ័ណ្ឌទូលំទូលាយនៃអនុវត្តន៍ល្អៗនៃការធ្វើកោសល្យវិច្ច័យបែបឌីជីថលនិងខ្សែសង្វាក់នៃការរក្សាទុកភស្តុតាង ដើម្បីសម្រួលដល់កិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេតនិងព្រះរាជអាជ្ញាក្នុងការធានាឱ្យមានវត្តមាននៃភាពជាក់ស្តែងនៃខ្សែសង្វាក់នៃការអនុវត្តច្បាប់។ ក្នុងន័យនេះ បច្ចេកវិទ្យា ក៏អាចដើរតួយ៉ាងសំខាន់ក្នុងការធានាឲ្យមានខ្សែសង្វាក់នៃការរក្សាទុកនូវភស្តុតាងជាក់ស្តែង - ចេញពីការប្រមូលនិងការប្រើប្រាស់ភស្តុតាងជាក់ស្តែង(ដូចដែលគេបានរកឃើញនៅក្នុងគម្រោងរបស់សហភាពអឺរ៉ុបដែលទាក់ទងនឹងការជួញដូរខុសច្បាប់ដទៃទៀត)។[4]

## ការវាយតម្លៃអំពីការខូចខាតចំពោះបរិស្ថាន

ក្នុងករណីនៃការដឹកជញ្ជូននិងការគ្រប់គ្រងកាកសំណល់ដោយខុសច្បាប់ដែលធ្វើឱ្យអន្តរាយដល់បរិស្ថាន ការវាយតម្លៃអំពីការខូចខាតឬគ្រោះថ្នាក់ចំពោះបរិស្ថាន អាចជាជំហានដ៏សំខាន់មួយនៃការស៊ើបអង្កេតនិងការកាត់ទោស។ ការវាស់ស្ទង់និងវាយតម្លៃអំពីផលប៉ះពាល់លើបរិស្ថាននិងសុខភាពមនុស្សនិងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃការមិនអនុលោមតាមច្បាប់ អាចជួយកំណត់កម្រិតនៃការពិន័យនិងវិធានការផ្នែកហិរញ្ញវត្ថុសមស្របដើម្បីស្តារឡើងវិញនូវការខូចខាតដែលបានបង្កឡើង។ ការដោះស្រាយចំពោះផលប៉ះពាល់នៃមហន្តរាយបរិស្ថាន អាចតម្រូវឱ្យមានការវាយតម្លៃមួយចំនួនធ្វើឡើងដោយអ្នកជំនាញ ប្រសិនបើវា មានគ្រោះមហន្តរាយជាក់ស្តែងឬប្រសិនបើវា អាចនឹងមានគ្រោះមហន្តរាយដល់បរិស្ថាន។

គម្រោង WasteForce project បានបង្កើតវិធីសាស្ត្រមួយដើម្បីវាស់វែងការខូចខាតចំពោះបរិស្ថាននិងការខូចខាតផ្នែកសេដ្ឋកិច្ចនៃការដឹកជញ្ជូនកាកសំណលដោយខុសច្បាប់ (*Methodology to measure environmental and economic damage of illegal waste transports*.)។ វិធីសាស្ត្រនេះ ពិពណ៌នាអំពីការចាត់វិធានការផ្នែកបរិស្ថានចំពោះការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ និងជួយក្នុងការគណនាការចំណាយនានាដែលកើតឡើងដោយសារការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ ដោយប្រើការវាស់វែងដូចខាងក្រោម៖

- កំណត់ស្វែងរកថាតើកាកសំណល់ អាចនឹងមានលក្ខណៈគ្រោះថ្នាក់ឬទេ
- ការធ្វើចំណាត់ថ្នាក់គ្រោះថ្នាក់
- វង្វាយតម្លៃអំពីការប៉ះពាល់
- ការធ្វើចំណាត់ថ្នាក់ហានិភ័យ
- វង្វាយតម្លៃអំពីហានិភ័យ

[4] សម្រាប់ឧទាហរណ៍សូមចូលមើលគម្រោង ANITA, www.anita-project.eu

- វាយតម្លៃអំពីផលប៉ះពាល់ចំពោះវដ្តជីវិត

បញ្ជីនៃប្រភេទនៃផលប៉ះពាល់និងគន្លងនៃការខូចខាត ត្រូវបានកំណត់នៅក្នុងវិធីសាស្ត្រនេះ។ ការវាស់វែងទាំងនេះ ដែលរួមជាមួយតម្លៃផ្នែកបរិស្ថាននិងកត្តាថ្លឹងថ្លែងនានា នាំឱ្យមានការគណនាជាប្រាក់អំពីផលប៉ះពាល់នៃការខូចខាតចំពោះបរិស្ថានដែលគេបានបង្កឡើង។ ជាលទ្ធផល គុណតម្លៃផ្នែកសេដ្ឋកិច្ចទាំងនេះ អាចត្រូវបានប្រើដើម្បីគណនារកការផាកពិន័យនិងចំនួនទឹកប្រាក់សម្រាប់ការខូចខាតផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។

# ជំពូក ៤ ទំនួលខុសត្រូវចំពោះមុខច្បាប់

## ៤.១ ការកំណត់រកអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មកាកសំណល់

សេចក្តីសម្រេចដំបូងគេបង្អស់មួយដែលត្រូវតែធ្វើ គឺគេ ត្រូវកំណត់ថាតើត្រូវតែកាត់ទោសអ្នកណា ក្រោមក្របខ័ណ្ឌច្បាប់ជាតិ។ ចាំបាច់ត្រូវកំណត់ស្វែររកភាគីដែលពាក់ព័ន្ធដែលទទួលខុសត្រូវពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការបោះចោលកាកសំណល់ដោយខុសច្បាប់។

ចំពោះឧក្រិដ្ឋកម្មកាកសំណល់ភាគច្រើន ទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ឆ្លងកាត់ព្រំដែនអន្តរជាតិ សុទ្ធតែអាចជាមុខសញ្ញានៃការកាត់ទោស។ អ្នកណាម្នាក់ដែលចូលរួមក្នុងដឹកកាកសំណល់ឆ្លងដែនដោយខុសច្បាប់ អាចនឹងត្រូវបានកាត់ទោស ដែលអ្នកទាំងនោះ រួមមាន៖

- អ្នកផលិតកាកសំណល់
- អ្នកនាំចេញកាកសំណល់
- អ្នកនាំចូលកាកសំណល់
- ក្រុមហ៊ុនដឹកជញ្ជូន
- បុគ្គលដែលបំពេញឯកសារក្រដាស់ស្នាម (អ្នកដឹកជញ្ជូន ឈ្មួញកណ្តាល អ្នកសម្របសម្រួលដល់ការដឹកជញ្ជូនកាកសំណល់)
- អ្នកបោះចោលកាកសំណល់

នៅក្រោមសន្និបាត Basel គេ មិនបានបញ្ជាក់ថាអ្នកណានឹងត្រូវចំណាយលើថ្លៃបញ្ជូនកាកសំណល់ត្រឡប់ទៅវិញទេ (នីតិវិធីបញ្ជូនកាកសំណល់ត្រឡប់ទៅវិញ) ខណៈមាត្រា ២៥ នៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់របស់សហភាពអឺរ៉ុប បានចែងថា "វា គួរតែជាកាតព្វកិច្ចរបស់បុគ្គលទាំងឡាយណាដែលទង្វើរបស់ពួកគេ គឺជាបុព្វហេតុធ្វើឲ្យមានការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។ ពួកគេ ត្រូវយកកាកសំណល់ដែលពាក់ព័ន្ធត្រឡប់ទៅវិញ ឬត្រូវតែបង្កើតការរៀបចំណាមួយផ្សេងទៀតសម្រាប់ការជួសជុលឬការបោះចោលកាកសំណល់នោះ។ ប្រសិនបើគេ ខកខានមិនបានធ្វើដូច្នោះ អាជ្ញាធរមានសមត្ថកិច្ចក្នុងការបញ្ជូនទំនិញនៅប្រទេសគោលដៅ គប្បីតែធ្វើអន្តរាគមន៍ខ្លួនឯង តាមការគួរ។[5]

[5] ក្នុងវិសាលភាព និងការបកស្រាយនៃមាត្រា ២៥ នៃបទប្បញ្ញត្តិស្តីអំពីការដឹកជញ្ជូនកាកសំណល់ សូមើល "សំណួរដែលគេតែងតែសួរ (FAQs) អំពីបទប្បញ្ញត្តិ (EC) ១០១៣/២០០៦ អំពីការដឹកជញ្ជូនកាកសំណល់", ទំព័រ41-42 នៅក្នុងគេហទំព័រ៖ https://ec.europa.eu/environment/waste/shipments/pdf/faq.pdf

តាមរយៈការធ្វើឱ្យបទល្មើសកាកសំណល់ក្លាយជាបទល្មើសព្រហ្មទណ្ឌ រដ្ឋាភិបាលជាតិ កំពុងព្យាយាមធ្វើឲ្យទាំងជនល្មើសនិងអ្នកដទៃទៀតដែលមានទង្វើស្រដៀងគ្នានេះ មានការខ្លាចរអា។ បញ្ហាមួយចំនួន នឹងពឹងផ្អែកទៅលើច្បាប់ជាតិជាក់លាក់ដែលមានស្រេចនៅក្នុងប្រទេសដែលរៀបចំការកាត់ទោស បញ្ហាទាំងនោះមានដូចជាៈ

- បទល្មើសនិងការផាកពិន័យដែលអនុវត្តចំពោះតួអង្គផ្សេងៗដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។
- អំណាចរបស់ព្រះរាជអាជ្ញានិងដែនយុត្តាធិការរបស់តុលាការក្នុងករណីមានតួអង្គដែលមានលក្ខណៈជារូបវន្តបុគ្គលឬនីតិបុគ្គលដែលនៅក្រៅប្រទេស។
- មិនថាការជួយ ឬការជំរុញ ឬការប៉ុនប៉ង ឬការឃុបឃិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទេ វា សុទ្ធតែនាំឱ្យមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌទាំងអស់ ដូចដែលមានចែងនៅក្នុងច្បាប់ថ្នាក់ជាតិឬថ្នាក់តំបន់ (ជាឧទាហរណ៍ សូមមើលសារាចរឧក្រិដ្ឋកម្មបរិស្ថានរបស់សហភាពអឺរ៉ុប)។
- ថាតើចេតនានៃការប្រព្រឹត្តបទឧក្រិដ្ឋ (ជាតុផ្សំអត្តនោម័ត) គឺជាធាតុផ្សំចាំបាច់ឬមិនមែន (ទំនួលខុសត្រូវចំពោះមុខច្បាប់តឹងរឹង) និងក្នុងកម្រិតណាមួយ (ដោយដឹងឬចេតនា) ដូចមានចែងនៅក្នុងច្បាប់ជាតិឬច្បាប់តំបន់។ (Basel Convention and UNEP, 2012)។
- ថាតើនីតិបុគ្គល អាចត្រូវតែទទួលខុសត្រូវឬមិនទទួលខុសត្រូវចំពោះមុខច្បាប់។

### ៤.១.១ ទំនួលខុសត្រូវមុខច្បាប់របស់ក្រុមហ៊ុនសាជីវកម្ម នាយក និងបុគ្គលនានា

នៅប្រទេសមួយចំនួន ក្រុមហ៊ុនសាជីវកម្មក៏ដូចជាបុគ្គលនានា អាចនឹងត្រូវទទួលខុសត្រូវចំពោះអំពើល្មើសនឹងច្បាប់កាកសំណល់។ ជាទូទៅ ព្រះរាជអាជ្ញា ដោយមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរស៊ើបអង្កេតឬភ្នាក់ងារពាក់ព័ន្ធចាំបាច់ ត្រូវតែពិចារណាថាតើនីតិវិធីព្រហ្មទណ្ឌឬរដ្ឋប្បវេណីគប្បីយកមកអនុវត្តចំពោះនីតិបុគ្គល (អាជីវកម្មឬក្រុមហ៊ុនសាជីវកម្ម) បុគ្គលណាមួយ ឬទាំងពីរ។ ច្បាប់បរិស្ថាន ភាគច្រើនផ្តល់បទប្បញ្ញត្តិចែងអំពី ទំនួលខុសត្រូវរបស់ក្រុមហ៊ុនសាជីវកម្ម ឬនីតិបុគ្គល។

នៅពេលដែលគេ ចង់ធ្វើការចោទប្រកាន់ក្រុមហ៊ុនសាជីវកម្មចំពោះបទល្មើសដែលពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័ត ច្បាប់បរិស្ថាន ភាគច្រើនចែងថា ចេតនារបស់ក្រុមហ៊ុនសាជីវកម្មមួយ អាចត្រូវបានបង្កើតឡើង ដោយមានអំណះអំណាងដែលថាមន្ត្រី និយោជិក ឬមន្ត្រីភ្នាក់ងារដែលធ្វើសកម្មភាពក្នុងវិសាលភាពនៃការងាររបស់ពួកគេ មានចេតនាបែបនោះ។ ជាទូទៅ ការចោទប្រកាន់នេះ អាចត្រូវបានបដិសេធដោយគេបង្ហាញថាក្រុមហ៊ុនសាជីវកម្មនោះ បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់។

វា ក៏ជារឿងសំខាន់ផងដែរក្នុងការយល់ដឹងអំពីអ្វីដែលអាចជាទំនួលខុសត្រូវចំពោះមុខច្បាប់សម្រាប់នាយកនៃនីតិបុគ្គលនៃបទល្មើសបរិស្ថាន។ ក្នុងសំណុំរឿងជាច្រើន ការចោទប្រកាន់ចំពោះមន្ត្រីក្រុមហ៊ុនសាជីវកម្មដែល

មានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បង្កនូវឧបសគ្គច្រើនជាងការអនុវត្តតាមផ្នែករដ្ឋបាលឬរដ្ឋប្បវេណីទៅទៀត។ (INTERPOL "Advocacy Memorandum", 2007, p. 5)។

លក្ខន្តិកៈច្បាប់ជាតិ ក៏អាចនឹងដាក់កម្រិតឬកំណត់តើគេត្រូវចោទប្រកាន់ស្ថាប័ននោះពីបទអ្វី។ ចំពោះបទល្មើស នៅក្នុងដែនសមត្ថកិច្ចមួយចំនួន គេ អាចអនុវត្តដោយផ្ទាល់ចំពោះក្រុមហ៊ុន - ជាឧទាហរណ៍ដូចជា បទល្មើស ទាក់ទងនឹងការរំលោភលើលក្ខខណ្ឌនៃអាជ្ញាប័ណ្ណដែលបានផ្តល់ឲ្យក្រុមហ៊ុន។ នៅក្នុងស្ថានភាពផ្សេងទៀត វា អាចជាទង្វើឬការធ្វេសប្រហែសរបស់និយោជិកណាម្នាក់ ដែលអាចបង្កឲ្យមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ បញ្ហានេះ ចោទជាសំណួរដ៏សំខាន់អំពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ក្រុមហ៊ុនសាជីវកម្ម ហើយក្នុងកាលៈទេសៈណាដែលក្រុមហ៊ុន អាចត្រូវទទួលខុសត្រូវចំពោះទង្វើរបស់និយោជិករបស់ខ្លួនឬក៏និយោជិកក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ក្រុមហ៊ុនសាជីវកម្មទៅវិញ។

ជាទូទៅ សកម្មភាពរបស់និយោជិក នឹងបណ្តាលឱ្យក្រុមហ៊ុនមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើ គេដឹងច្បាស់ថាការអនុវត្តច្បាប់លក្ខន្តិកៈដែលពាក់ព័ន្ធ នឹងទទួលបរាជ័យ ប្រសិនបើក្រុមហ៊ុន មិនអាចត្រូវបានចោទប្រកាន់ចំពោះទង្វើរបស់និយោជិករបស់ខ្លួន(Bell 2008, p.283)។ ក្នុងស្ថានភាពបែបនេះ គេ ចាំបាច់ចោទប្រកាន់ទាំងបុគ្គលនិងក្រុមហ៊ុនសាជីវកម្ម។ ផ្ទុយទៅវិញ នាយកឬអ្នកគ្រប់គ្រង ប្រហែលជាមិនទទួលខុសត្រូវ ប្រសិនបើ គេ អាចបង្ហាញថាសកម្មភាពរបស់គេ មិនសមនឹងត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទល្មើសរបស់ក្រុមហ៊ុនឡើយ។ ជាឧទាហរណ៍ នាយកផ្នែកហិរញ្ញវត្ថុ ដែលធ្វើការនៅការិយាល័យកណ្តាលរបស់ក្រុមហ៊ុន ឆ្ងាយចម្ងាយ២០គីឡូម៉ែតពីក្រុមហ៊ុន គាត់ទទួលខុសត្រូវចំពោះសេចក្តីសម្រេចនានាដែលមានវិសាលភាពក្រៅពីផ្នែកប្រតិបត្តិការ ដែលទំនងជាមិនត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃគំនិតគ្រប់គ្រងក្រុមហ៊ុនទេ។ វា ខុសគ្នា បើប្រៀបធៀបទៅនឹងអ្នកគ្រប់គ្រងកន្លែងកើតហេតុឬនាយកផ្នែកប្រតិបត្តិការ ក្នុងករណីដែលគេ មិនអាចបង្ហាញថានាយកផ្នែកហិរញ្ញវត្ថុរូបនោះ បានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចជាពិសេសដែលទាក់ទងនឹងអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាជីវកម្មដែលជាប់ចោទ។

នៅពេលពិចារណាថាតើត្រូវចោទប្រកាន់ទាំងក្រុមហ៊ុនសាជីវកម្មនិងទាំងបុគ្គលនានារបស់ក្រុមហ៊ុន ព្រះរាជអាជ្ញា អាចពិចារណាអំពីមុខតំណែងរបស់បុគ្គលម្នាក់ៗនៅក្នុងក្រុមហ៊ុន នៅពេលដែលមានបទល្មើសកើតឡើង (ឧទាហរណ៍ដូចជាករណីនាយកផ្នែកហិរញ្ញវត្ថុខាងលើ) ។

រឿងដែលត្រូវពិចារណាថាតើត្រូវចោទប្រកាន់អ្នកណា អាស្រ័យលើច្បាប់ជាតិ៖

- មុខតំណែងរបស់បុគ្គលនោះនៅក្នុងក្រុមហ៊ុននិងតួនាទីរបស់បុគ្គលនោះក្នុងការប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ ថាតើគេ ជាមេដឹកនាំឬអ្នករៀបចំ ឬអ្នកចូលរួមក្នុងបទឧក្រិដ្ឋមែនឬទេ។
- ចំណេះដឹងអំពីភាពមិនស្របច្បាប់នៃការប្រព្រឹត្តបទល្មើស និងអំពីលទ្ធភាពនៃការខូចខាត គ្រោះថ្នាក់ ឬផលវិបាកដែលបណ្តាលមកពីបទល្មើស (មិនអនុវត្តនៅក្នុងគ្រប់ដែនយុត្តាធិការទាំងអស់ទេ)
- ការប្រព្រឹត្តរបស់ពួកគេ មុនពេលមានការរំលោភបំពានច្បាប់ តួយ៉ាងដូចជាប្រវត្តិរបស់ពួកគេមុនមានការប្រព្រឹត្តិបទល្មើស វិធានការអនុវត្តច្បាប់ផ្នែករដ្ឋបាលនិងរដ្ឋប្បវេណីចំពោះការបំពានច្បាប់ដូចគ្នាឬស្រដៀងគ្នាពីមុនៗ។

- ការប្រព្រឹត្តរបស់ពួកគេបន្ទាប់ពីមានការរំលោភបំពានច្បាប់ តួយ៉ាងដូចជាការលាក់បាំងចំពោះការបំពានច្បាប់ដោយចេតនា មិនថាការបំពានច្បាប់នោះ គឺជាសកម្មភាពដែលកំពុងបន្តកើតឡើង ឬជាសកម្មភាពមួយដាច់ដោយឡែកក្តី); និង
- ទង្វើរបស់ពួកគេបន្ទាប់មានការរំលោភបំពានច្បាប់ តួយ៉ាងដូចជាការសហការចូលរួមរបស់គេក្នុងកិច្ចសម្ភាសន៍ដោយគេ បានសារភាពនូវទង្វើរបស់ខ្លួនទាំងស្រុង និងដោយស្មោះត្រង់។

លើសពីនេះ នៅពេលសម្រេចថាត្រូវចោទប្រកាន់ពីបទអ្វី ថាតើមានកាលៈទេសៈនិងអង្គហេតុជាក់លាក់អ្វីខ្លះនៃសំណុំរឿងដែលក្នុងនោះរួមទាំងធម្មជាតិនៃគ្រោះថ្នាក់ដែលបង្កដោយបទល្មើស ហើយដែលត្រូវបានពិនិត្យដោយធ្វើការពិចារណាចំពោះការចោទប្រកាន់ដែលពាក់ព័ន្ធផ្សេងទៀត ដូចជា ការបោកប្រាស់ ការលួច ការរំលោភបំពាន ការធ្វើឱ្យមានការខូចខាតនានាផ្នែកព្រហ្មទណ្ឌ ការក្លែងបន្លំកំណត់ត្រាឬការឃុបឃិត ឬសូម្បីតែអំពើឃាតកម្មក្នុងកាលៈទេសៈដ៏កម្របំផុត អំពើឃាតកម្មប្រព្រឹត្តដោយក្រុមហ៊ុនសាជីវកម្ម អាចមានឥទ្ធិពលខ្លាំងលើសំណុំរឿងក្តី ព្រោះវា បង្ហាញឲ្យកាន់តែច្បាស់អំពីកាលៈទេសៈនៃបទល្មើសជាជាងការដឹកជញ្ជូនដោយខុសច្បាប់តែមួយមុខ។

ច្បាប់ជាតិ ជាច្បាប់ដែលគេ នឹងយកមកប្រើដើម្បីកំណត់ថាតើបុគ្គលពាក់ព័ន្ធទាំងនោះ នឹងមានទំនួលខុសត្រូវក្នុងកម្រិតណា។ នៅត្រឹមចំណុចមួយចំនួននៃនីតិវិធីអនុវត្តច្បាប់ អ្នកស៊ើបអង្កេតនិងព្រះរាជអាជ្ញា ក៏នឹងត្រូវពិចារណាផងដែរថាតើក្រុមហ៊ុននោះ ជាផ្នែកមួយនៃការផ្សំគំនិតផ្នែកព្រហ្មទណ្ឌ ឬជាផ្នែកមួយនៃអង្គការចាត់តាំងឧក្រិដ្ឋកម្មដែរឬទេ។ ដោយពង្រីកទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះមនុស្សជាច្រើន ច្បាប់ បានបង្កើនការយល់ដឹងនិងទំនួលខុសត្រូវកាន់តែច្រើនចំពោះកាតព្វកិច្ចផ្នែកច្បាប់នៅក្នុងរចនាសម្ព័ន្ធក្រុមហ៊ុននិងនៅក្នុងសហគមន៍ទាំងមូល។ ស្ថានភាពនេះ អាចកើតឡើងនៅពេលដែលមនុស្សមួយចំនួន អាចនឹងទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើស ហើយដូច្នេះនាំឲ្យមានទំនួលខុសត្រូវចំពោះវិធានការអនុវត្តច្បាប់។

នៅក្នុងដែនយុត្តាធិការជាច្រើន ការជួយ ឬការជំរុញ ការប៉ុនប៉ង ឬការឃុបឃិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ក៏អាចបើកឱកាសឲ្យមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ។ ថាតើចេតនាប្រព្រឹត្តបទឧក្រិដ្ឋ (ធាតុផ្សំអត្តនោម័ត) គឺជាធាតុផ្សំចាំបាច់ឬមិនមែន (ទំនួលខុសត្រូវចំពោះមុខច្បាប់តឹងរឹង) និងក្នុងកម្រិតណាមួយ (ដោយដឹងឬដោយចេតនា) គឺជាបញ្ហាដែលមានបញ្ចូលក្នុងក្របខណ្ឌច្បាប់ជាតិផងដែរ។

ក្នុងការកំណត់ថាអ្នកណាជាអ្នកទទួលខុសត្រូវចំពោះបទល្មើសណាមួយ អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ នឹងធ្វើការពិចារណាដូចខាងក្រោម៖

- តើអ្នកណាជាអ្នកទទួលខុសត្រូវចម្បងចំពោះបទល្មើស មានន័យថា៖
    - i. តើអ្នកណាជាអ្នកប្រព្រឹត្តទង្វើនោះ?
    - ii. តើអ្នកណាជាអ្នកបង្កើតចេតនានោះ (ប្រសិនពាក់ព័ន្ធ)

iii. តើអ្នកណាជាអ្នកបង្កើតកាលៈទេសៈចាំបាច់ដែលនាំឲ្យមានបទល្មើសដែលគេចោទប្រកាន់?
iv. តើអ្នកណាជាអ្នកទទួលផលប្រយោជន៍ពីបទល្មើស?
- តើអ្នកប្រព្រឹត្តបទល្មើសម្នាក់ៗ មានតួនាទីអ្វីខ្លះ? (ប្រសិនបើមានជនល្មើសច្រើនជាងម្នាក់)

នៅពេលណាដែលគេ កំណត់ថាតើបុគ្គលណាដែលត្រូវទទួលខុសត្រូវចំពោះបទល្មើសហើយ វាទំនងជានឹងមានការតភ្ជាប់ទៅនឹងនីតិបុគ្គល (ដូចជាអាជីវកម្មឬក្រុមហ៊ុនសាជីវកម្ម)។ នីតិបុគ្គលនេះ ប្រហែលជាបានចុះបញ្ជីនៅក្នុងប្រទេសដែលបទល្មើសបានកើតឡើង ឬវាអាចជានីតិបុគ្គលបរទេសដែលបានដាក់បញ្ចូលនៅក្នុងប្រទេសនាំចេញកាកសំណល់ ឬអាចជាប្រទេសមួយដែលមិនមានជាប់ទាក់ទងនឹងទីតាំងជាក់ស្តែងនៃកាកសំណល់ក៏អាចថាបាន។ ថាតើការចោទប្រកាន់ត្រូវបានធ្វើឡើងចំពោះនីតិបុគ្គលនោះឬទេ នឹងអាស្រ័យលើច្បាប់ជាតិនិងបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងច្បាប់ស្តីពីកាកសំណល់ឬច្បាប់ព្រហ្មទណ្ឌ។

ក្នុងករណីជាច្រើន វា ជាទំនួលខុសត្រូវរបស់បុគ្គលណាមួយដែលបានបំពានច្បាប់កាកសំណល់ ប៉ុន្តែបុគ្គលនោះក៏អាចជានាយកនៃនីតិបុគ្គលដែលជាប់ទាក់ទងនឹងបទល្មើសផងដែរ។ ច្បាប់ព្រហ្មទណ្ឌមួយចំនួន បានចែងយ៉ាងច្បាស់អំពីដែនកំណត់នៃទំនួលខុសត្រូវរបស់នាយកនិងអ្នកកាន់ការិយាល័យផ្សេងៗទៀត។ វា ក៏អាចផងដែរថានីតិវិធីសម្រាប់បទល្មើស អាចត្រូវបានធ្វើឡើងទល់ទប់នឹងបុគ្គលនានាដែលទទួលខុសត្រូវច្រើនបំផុតចំពោះបទល្មើស។

ប៉ុន្តែបញ្ហាមួយសម្រាប់ធ្វើការពិចារណា គឺថានរណា ប្រហែលជានឹងត្រូវបានគេបញ្ជាឲ្យបង់ថ្លៃផាកពិន័យដែលពាក់ព័ន្ធ ប្រសិនបើជាប់ទោស ឬនីតិបុគ្គលណាដែលទំនងជាអាចនឹងផ្តល់សំណងសមរម្យក្នុងសំណុំរឿងដែលពាក់ព័ន្ធនោះ។

បុគ្គលម្នាក់ៗ ប្រហែលជាអាចនឹងត្រូវបង់ថ្លៃផាកពិន័យ ឬក៏ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ខណៈដែលនីតិបុគ្គល ប្រហែលជាអាចមានលទ្ធភាពបង់ប្រាក់ពិន័យ ផ្តល់សំណងសម្រាប់ការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញ ឬសម្រាប់ការបោះចោលកាកសំណល់ ឬសម្អាតកាកសំណល់ឲ្យបានសមរម្យ។ នីតិបុគ្គល មិនអាចត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារនោះទេ ប៉ុន្តែវា អាចនឹងត្រូវបានព្យួរពីសកម្មភាពឬត្រូវព្យួរអាជ្ញាប័ណ្ណរបស់ខ្លួនក្នុងការងារទាក់ទងនឹងកាកសំណល់។ សម្រាប់នីតិបុគ្គល ការផាកពិន័យបន្ទាប់ពីមានការផ្តន្ទាទោស អាចនាំឱ្យមានផលវិបាកផ្នែកហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់។

មន្ត្រីស៊ើបអង្កេតនិងព្រះរាជអាជ្ញា គប្បីផងដែរពិចារណាពីសមត្ថភាពរបស់នីតិបុគ្គលក្នុងការបង់ប្រាក់ពិន័យ ឬក្នុងការផ្តល់ជាសំណង។ លើសពីនេះ អ្នកស៊ើបអង្កេត ក៏គប្បីពិចារណាផងដែរលើការចេញលិខិតបញ្ជាទុកជាមុនដើម្បីធានាថានីតិបុគ្គល (មុខសញ្ញានៃការកាត់ទោស) មិនបោះបង់ចោលទ្រព្យសម្បត្តិនានាដើម្បីធ្វើឲ្យប៉ះពាល់ដល់ការផាកពិន័យផ្នែកហិរញ្ញវត្ថុណាមួយឡើយ។

ដែនយុត្តាធិការមួយចំនួន ផ្តល់នូវយន្តការដាក់លាក់សម្រាប់នីតិបុគ្គលនិងបុគ្គលដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើស ដើម្បីរឹបអូស "ផលនានាដែលទទួលបានពីបទឧក្រិដ្ឋ" ។

នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តដោយនិយោជិត មន្ត្រីភ្នាក់ងារ ឬមន្ត្រីរបស់ក្រុមហ៊ុនសាជីវកម្មដែលកំពុងបម្រើការក្នុងក្រុមហ៊ុននោះ នីតិវិធី ជាធម្មតានឹងត្រូវធ្វើឡើងទល់ទប់នឹងក្រុមហ៊ុនសាជីវកម្ម។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើបទល្មើស បានកើតឡើងដោយសារតែនិយោជិត មន្ត្រីភ្នាក់ងារ ឬមន្ត្រីណាម្នាក់របស់ក្រុមហ៊ុនដែលបានប្រព្រឹត្តបទល្មើសដោយចេតនាផ្ទាល់ខ្លួនក្រៅពីវិសាលភាពនៃការងារឬសិទ្ធិអំណាចរបស់ពួកគេក្នុងក្រុមហ៊ុន នីតិវិធី អាចត្រូវបានបង្កើតឡើងទល់ទប់នឹងនិយោជិត មន្ត្រីភ្នាក់ងារ ឬមន្ត្រីម្នាក់នោះរបស់ក្រុមហ៊ុនហើយគេ នឹងមិនចោទប្រកាន់លើក្រុមហ៊ុនសាជីវកម្មឡើយ។ កត្តាមួយទៀតដែលនឹងត្រូវពិចារណាផងដែរ គឺវត្តមាននិងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលនិងកម្មវិធីអនុលោមតាមច្បាប់ណាមួយរបស់សាជីវកម្ម។

នៅក្រោមច្បាប់កាកសំណល់ កាតព្វកិច្ចរបស់និយោជិកទាំងអស់ មិនអាចត្រូវបានបដិសេធដោយអះអាងថាមានការណែនាំពីនិយោជក់របស់ខ្លួនឡើយ - វា មិនមែនជាការដោះសារសម្រាប់និយោជិកណាម្នាក់ណាដែលអះអាងថាខ្លួនគ្រាន់តែធ្វើតាមការណែនាំពីអ្នកគ្រប់គ្រងណាម្នាក់របស់ខ្លួននោះទេ បើទោះបីជាការធ្វើដូចនេះ អាចជាការពិចារណាមួយនិងជាកត្តាមួយក្នុងការកាត់បន្ថយបន្ថយទោស ឬកាត់បន្ថយនូវជម្រើសនៃវិធានការអនុវត្តច្បាប់ដែលសមស្របណាមួយក៏ដោយ។ គោលការណ៍នេះ ត្រូវបានអនុវត្តស្មើៗគ្នាចំពោះអ្នកម៉ៅការការងារផងដែរ។

គោលការណ៍ណែនាំមួយក្នុងការសម្រេចថាតើត្រូវបន្តការងាររបស់និយោជិកឬអ្នកម៉ៅការឬទេ គឺស្ថិតនៅលើកម្រិតនៃពិរុទ្ធភាពឬទំនួលខុសត្រូវរបស់ពួកគេ។

| ផលប៉ះពាល់ | ពិរុទ្ធភាពកម្រិតធ្ងន់ធ្ងរ | ពិរុទ្ធភាពកម្រិតមធ្យម | ពិរុទ្ធភាពកម្រិតទាប |
|---|---|---|---|
| | • ទង្វើដោយចេតនាឬដោយឆន្ទៈ<br>• មានការមិនអនុលោមតាមច្បាប់ឬការផ្តន្ទាទោសពីមុនៗពាក់ព័ន្ធនឹងបទប្បញ្ញត្តិច្បាប់ដូចគ្នាឬស្រដៀងគ្នា | • ទង្វើដោយធ្វេសប្រហែស<br>• មានការមិនអនុលោមតាមច្បាប់ស្រដៀងគ្នានេះដាច់ដោយឡែក<br>• មានការមិនអនុលោមតាមច្បាប់ក្នុងកម្រិតរយៈពេលមធ្យម<br>• មានបំណងដាក់ស្តែងក្នុងការបញ្ឈប់ការខូច | • ទង្វើដោយអចេតនា<br>• មិនការមិនអនុលោមតាមច្បាប់ស្រដៀងគ្នានេះដាច់ដោយឡែក<br>• មានការមិនអនុលោមតាមច្បាប់ក្នុងកម្រិតរយៈពេលខ្លី |

| | | | |
|---|---|---|---|
| | • មានការមិនអនុលោមតាមច្បាប់ក្នុងកម្រិតរយៈពេលយូរ<br>• មិនមានបំណងសម្អាតបរិស្ថាន ឬមិនបានចាត់វិធានការបញ្ឈប់ការខូចខាតដល់បរិស្ថាន<br>• ចង់បានផលចំណេញឬទទួលបានផលចំណេញច្រើនពីការមិនអនុលោមតាមច្បាប់<br>• រួមមានទង្វើខុសច្បាប់ធ្ងន់ធ្ងរ<br>• ខកខានមិនបានជូនដំណឹងដល់នាយកដ្ឋានប្រកបដោយប្រសិទ្ធភាព ឬខកខានមិនបានជូនដំណឹងស្របតាមពេលវេលាសមរម្យ<br>• មានការព្រងើយកន្តើយមិនអនុវត្តតាមបញ្ជា បំរាម ឬវិធានការផ្នែករដ្ឋបាលច្បាប់លាស់(ពីនិយោជិក អ្នកប្រឹក្សាយោបល់ នាយកដ្ឋាន ឬមន្ត្រីរដ្ឋាភិបាល) ដោយចេតនា ដែលទាំងនេះអាចនឹងទប់ស្កាត់ឬកាត់បន្ថយផលប៉ះពាល់បាន<br>• ផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ មាន | ខាតដល់បរិស្ថានប្រកបដោយប្រសិទ្ធភាពទាំងស្រុង ឬដោយផ្នែក<br>• មានបំណងជូនដំណឹងដល់នាយកដ្ឋានអំពីឧប្បត្តិហេតុនៅក្នុងរយៈពេលមួយសមហេតុសមផល<br>• ប្រហែលជាទទួលផលចំណេញពីការមិនអនុលោមតាមច្បាប់<br>• បានដឹងអំពីហានិភ័យនៃផលប៉ះពាល់ ឬផលប៉ះពាល់នោះអាចព្យាករណ៍បាន<br>• ផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ ប្រហែលជាអាចត្រូវបានទប់ស្កាត់បានដោយប្រើបទដ្ឋានឧស្សាហកម្មដែលគេទទួលស្គាល់ | • បញ្ឈប់ការធ្វើឲ្យខូចខាតដល់បរិស្ថានប្រកបដោយប្រសិទ្ធភាព<br>• បានជូនដំណឹងដល់នាយកដ្ឋានអំពីឧប្បត្តិហេតុនៅក្នុងរយៈពេលសមហេតុសមផល<br>• មិនទទួលបានផលចំណេញពីការមិនអនុលោមតាមច្បាប់<br>• ផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ មិនអាចព្យាករណ៍បាន<br>• ផលប៉ះពាល់ឬហានិភ័យនៃផលប៉ះពាល់ មិនអាចទប់ស្កាត់ដោយប្រើបទដ្ឋានខ្ពស់នៃប្រតិបត្តិការបានទេ (វាមានទំហំធំជាងបទដ្ឋានឧស្សាហកម្មដែលគេទទួលស្គាល់) |

| | | | |
|---|---|---|---|
| | លក្ខណៈច្បាស់ ហើយ/ឬ អាចបង្ហាបានដោយការអនុវត្តឬធ្វើតាមបទដ្ឋានឧស្សាហកម្មដែលគេទទួលស្គាល់ | | |

**តារាង២៖ លក្ខខណ្ឌដែលអាចមាន ដើម្បីពិចារណាអំពីកម្រិតនៃពិរុទ្ធភាពរបស់ជនល្មើស**

កត្តាដែលត្រូវពិចារណាក្នុងការកំណត់អំពីកម្រិតនៃពិរុទ្ធភាព រួមមាន៖

- តើនិយោជិក ឬអ្នកម៉ៅការការងារ បានដឹងឬគួរតែបានដឹងហើយថាសកម្មភាពនោះ ទំនងជាខុសច្បាប់ឬមិនត្រឹមត្រូវ ឬទេ
- អតីតភាពការងាររបស់និយោជិក និងវិសាលភាពនៃតួនាទីរបស់ពួកគេ
- ដោយបានដឹងអំពីអតីតភាពការងារនិងតួនាទីការងាររបស់និយោជិកនោះហើយ ត្រូវដឹងថាតើនិយោគជិកឬអ្នកម៉ៅការការងារនោះ បានចាត់វិធានការណាមួយសមរម្យដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់និយោជក់ឬបុគ្គលពាក់ព័ន្ធនានាផ្សេងទៀតលើភាពមិនត្រឹមត្រូវនៃការអនុវត្តបែបនោះ ឬទេ
- ថាតើនិយោជិកឬអ្នកម៉ៅការការងារ បានចាត់វិធានការសមរម្យដើម្បីកាត់បន្ថយឬទប់ស្កាត់ផលប៉ះពាល់ទាំងនោះឬទេ

ប្រសិនបើច្បាប់ជាតិស្ដីពីកាកសំណល់ មានបទប្បញ្ញត្តិដែលចែងពីទំនួលខុសត្រូវចំពោះបទល្មើសដែលបានប្រព្រឹត្តដោយចាប់ពីក្រុមហ៊ុនសាជីវកម្ម រហូតទៅដល់មន្ត្រីប្រតិបត្តិរបស់ក្រុមហ៊ុន ព្រះរាជអាជ្ញា នឹងត្រូវកំណត់ថាតើត្រូវចាត់វិធានការអនុវត្តច្បាប់ទល់ទប់នឹងមន្ត្រីប្រតិបត្តិនោះស្របតាមបទប្បញ្ញត្តិនោះដែរឬទេ។ ការពិចារណាដ៏សំខាន់នោះ គឺថាតើបុគ្គលនោះ មានការគ្រប់គ្រងឬឥទ្ធិពលជាក់ស្ដែងលើការប្រព្រឹត្តរបស់ក្រុមហ៊ុនសាជីវកម្មក្នុងបញ្ហាពាក់ព័ន្ធដែរឬទេ។ វិធានការអនុវត្តច្បាប់ក្រោមបទប្បញ្ញត្តិស្ដីពីទំនួលខុសត្រូវរបស់មន្ត្រីប្រតិបត្តិ អាចអនុវត្តបានលុះត្រាតែភស្តុតាងបានផ្សាភ្ជាប់មនុស្សជាមួយសកម្មភាពខុសច្បាប់របស់ក្រុមហ៊ុនសាជីវកម្ម។

ឧទាហរណ៍ ភស្តុតាងនោះ អាចនឹងបង្ហាញថា មន្ត្រីប្រតិបត្តិរូបនោះ ៖

- មានចេតនាចូលរួមក្នុងសកម្មភាព ឬការខកខានមិនបានទប់ស្កាត់សកម្មភាពនោះ
- មានការធ្វេសប្រហែសឬមិនប្រុងប្រយ័ត្នទាក់ទងនឹងសកម្មភាព ឬការខកខានមិនបានទប់ស្កាត់សកម្មភាពនោះ
- មានចេតនាបន្លំនាយកដ្ឋាន

- ខកខានមិនបានគ្រប់គ្រងឬវាយតម្លៃជាប្រចាំនិងមិនបានគ្រប់គ្រងហានិភ័យទាក់ទងនឹងសកម្មភាពពាក់ព័ន្ធរបស់ក្រុមហ៊ុនសាជីវកម្ម ឬមិនបានត្រួតពិនិត្យប្រព័ន្ធឬកម្មវិធីទ្រទ្រង់នានា

នៅក្នុងប្រទេសជាច្រើន មន្ត្រីប្រតិបត្តិ នឹងមិនទទួលខុសត្រូវចំពោះមុខច្បាប់ទេ នៅពេលដែលមន្ត្រីប្រតិបត្តិរូបនោះ មិនស្ថិតក្នុងឋានៈដែលមានឥទ្ធិពលលើការប្រព្រឹត្តរបស់ក្រុមហ៊ុនសាជីវកម្ម។ ឬមន្ត្រីរូបនោះ បានចាត់វិធានការសមហេតុផលទាំងអស់ដើម្បីធានាថាក្រុមហ៊ុនសាជីវកម្មគោរពតាមច្បាប់។

ក្នុងករណីជាច្រើន សេចក្តីសម្រេចថាអ្នកណា នឹងត្រូវបានកាត់ទោស នឹងពឹងផ្អែកលើភស្តុតាងដែលបានប្រមូលមក។ អ៊ីម៉ែល លិខិត និងឯកសារដែលបានចុះហត្ថលេខាដោយបុគ្គលនានា សុទ្ធតែផ្តល់នូវភស្តុតាងនៃការផ្សារភ្ជាប់ទៅនឹងសកម្មភាពដែលនាំឱ្យមានបទល្មើស។

## ៤.២ អំពើពុករលួយ និងបទឧក្រិដ្ឋកាកសំណល់

អំពើពុករលួយ ពិតជាអាចត្រូវបានគេចាត់ទុកថាជាកត្តាជំរុញឲ្យមានការដឹកជញ្ជូនកាកសំណល់ឆ្លងដែនដោយខុសច្បាប់។ វាដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដល់ពាណិជ្ជកម្មក្លែងបន្លំ ការទទួលបានអាជ្ញាប័ណ្ណនិងវិញ្ញាបនប័ត្រនាំចូល/នាំចេញដោយខុសច្បាប់ ដែលបោកបញ្ឆោតប្រព័ន្ធច្បាប់តាមរយៈមន្ត្រីពុករលួយនិងឯកសារនានា។

អំពើពុករលួយក្នុងករណីបែបនេះ អាចមានការចូលរួមពីតួអង្គផ្សេងៗ រាប់ចាប់ពីរូបវន្តបុគ្គល រហូតដល់នីតិបុគ្គល រហូតដល់រដ្ឋនានា ដែលរួមមាន៖ អ្នកនយោបាយ មន្ត្រីគយ ម្ចាស់ដី ប៉ូលីស ក្រុមហ៊ុនដឹកជញ្ជូន និងអ្នកនាំចេញ/នាំចូល និងតួអង្គផ្សេងៗទៀត។

វាគឺជាដំណើរការដ៏ស្មុគស្មាញមួយក្នុងការចូលរួមក្នុងការកាត់ទោសប្រកបដោយជោគជ័យចំពោះជនល្មើសដែលគេសង្ស័យពីបទឧក្រិដ្ឋបរិស្ថាននិងអំពើពុករលួយ ។ ប្រភពដើមនៃការលំបាកបែបនេះ កើតឡើងពីតថភាពដែលថាច្បាប់នៅក្នុងរដ្ឋជាច្រើន មិនទាន់ទទួលយកភាពធ្ងន់ធ្ងរនិងលក្ខណៈបំផ្លិចបំផ្លាញនៃបទឧក្រិដ្ឋបរិស្ថាននិងអំពើពុករលួយដែលប៉ះពាល់មិនត្រឹមតែលើបរិស្ថានប៉ុណ្ណោះទេប៉ុន្តែថែមទាំងលើសុខភាពមនុស្សផងដែរ។ ទាក់ទងនឹងបញ្ហានេះ ការផ្តន្ទាទោស មិនថាជាការដាក់ពន្ធនាគារក្តីឬការផាកពិន័យក្តី ជាទូទៅមានភាពមិនសមស្របនិងតឹងរឹងគ្រប់គ្រាន់ ដើម្បីបង្កការខ្លាចរអាដល់ជនល្មើសនៅឡើយទេ នៅពេលដែលគេធ្វើការថ្លឹងថ្លែងពីលក្ខណៈនៃឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្ត។

លើសពីនេះទៅទៀត គេ អាចនិយាយបានថាការពិចារណាអំពីការផាកពិន័យជាប្រាក់ឬការដាក់ពន្ធនាគារ មិនមែនគ្រាន់តែផ្អែកតែលើតម្លៃខាងសេដ្ឋកិច្ចនៃធនធានប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ វា ក៏គួរតែរាប់បញ្ចូលទាំងប្រាក់និងពេលវេលាដែលត្រូវចំណាយជំនួសឲ្យធនធានទាំងនេះ ហើយសំខាន់បំផុតនោះ គឺការចំណាយចុងក្រោយនៃការផុតពូជ រួមជាមួយផលវិបាកនានា ថាតើវា នឹងមានផលប៉ះពាល់ចំពោះសុខភាពមនុស្សក្នុងកម្រិតណា។ លទ្ធផលនៃកង្វះភាពរឹងមាំនៃផ្នែកនីតិបញ្ញត្តិ ធ្វើឲ្យអត្រានៃការផ្តន្ទាទោសជាទូទៅមានកំរិតទាប

ដោយសារសមត្ថភាពរបស់ភ្នាក់ងារអនុវត្តច្បាប់នៅមានកម្រិត ហើយបញ្ហាដែលបានលើកឡើងខាងលើទាក់ទងនឹងអំពើពុករលួយនិងធន្ធៈនយោបាយនៅមានកម្រិត។

នៅក្នុងបរិបទនៃការកាត់ទោសចំពោះបទឧក្រិដ្ឋកាកសំណល់ តួនាទីនៃអាកប្បកិរិយាដែលពុករលួយ ត្រូវតែត្រូវបានពិចារណាជាពិសេសថាតើមានសន្និបាតអន្តរជាតិផ្សេងៗប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងប្រឆាំងនឹងអំពើពុករលួយទាំងនោះដែរឬទេ។ ការកាត់ទោសចំពោះអំពើពុករលួយ ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងការលាងលុយកខ្វក់ គឺហួសពីវិសាលភាពនៃគោលការណ៍ណែនាំនេះ ប៉ុន្តែវាជាបញ្ហាដែលត្រូវពិចារណាដោយព្រះរាជអាជ្ញា។ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ សូមមើលឯកសារសន្និបាតរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (UN Convention Against Corruption, ) និង ឯកសារនៃសន្និបាតរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (UN Convention against Transnational Organised Crime. )។

## ៤.៣ ក្រុមអង្គការចាត់តាំងឧក្រិដ្ឋកម្ម

យោងតាមអង្គការ Europol សំណុំរឿងជួញដូរកាកសំណល់ដោយខុសច្បាប់ ក៏បង្ហាញពីទំនាក់ទំនងនិងការចូលរួមរបស់ក្រុមឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង។ (Europol Environmental Threat Assessment, 2013) ដែលជំរុញទឹកចិត្តដោយផលចំណេញអតិបរមានិងការចំណាយអប្បបរមា។ ប្រសិនបើអាចធ្វើទៅបាន ការកាត់ទោសដែលមានគោលបំណងបង្ក្រាបក្រុមឧក្រិដ្ឋជនទាំងនេះ គប្បីផ្តោតលើការកំណត់អត្តសញ្ញាណសមាជិកនិងតួនាទីរបស់ពួកគេនៅក្នុងអង្គការចាត់តាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀតដែលអាចកើតមាន ហើយគប្បីស្វែងរកផលនៃឧក្រិដ្ឋកម្មរបស់ពួកគេ។

ក្នុងករណីសំណុំរឿងឆ្លងដែនពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង[6] សន្និបាតរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (United Nations Convention against Transnational Organised Crime)(UNTOC) ណែនាំឲ្យប្រើមធ្យោបាយដែលមានប្រយោជន៍មួយចំនួនដើម្បីពង្រឹងការស៊ើបអង្កេតនិងការកាត់ទោស ក្នុងនោះរួមមាន បច្ចេកទេសស៊ើបអង្កេត ការស៊ើបអង្កេតពិសេស ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ការរឹបអូសនិងការដកហូតប្រាក់ឬទ្រព្យសម្បត្តិដែលទទួលបានដោយខុសច្បាប់ ការអនុម័តក្របខណ្ឌថ្មីសម្រាប់ជំនួយយោគយល់គ្នាផ្នែកច្បាប់ កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ និងប

---

[6] ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ត្រូវបានកំណត់និយមន័យដោយសន្និបាតអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (UNTOC) ថាជា "ក្រុមដែលមានរចនាសម្ព័ន្ធនៃមនុស្សបីនាក់ឬច្រើនជាងនេះ ដែលបង្កើតឡើងសម្រាប់រយៈពេលណាមួយ ដោយមានគោលបំណងប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរនិងបទល្មើសមួយឬច្រើន ដោយយោងតាមសន្និបាតនេះ ដើម្បីទទួលផលចំណេញផ្នែកហិរញ្ញវត្ថុឬផលចំណេញចាំបាច់ផ្សេងៗទៀត" (មាត្រា ២ (a))

# ជំពូក ៥ ការផ្តន្ទាទោស និងការរៀបចំរបាយការណ៍

ការផ្តន្ទាទោស គឺជារឿងសម្រាប់តុលាការឬសាលាក្តីដែលពាក់ព័ន្ធ ហើយការផ្តន្ទាទោស អាចត្រូវបានកំណត់ដោយកត្តាមួយចំនួនដែលមានកម្រិតរហូតដល់ការពិន័យទោសអតិបរមាដែលមានចែងដោយច្បាប់និងការអនុវត្តរបស់ប្រទេសពាក់ព័ន្ធ។

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ បណ្តាប្រទេសមួយចំនួន បានអនុម័តសេចក្តីណែនាំស្តីពីការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មបរិស្ថានដើម្បីជួយក្នុងការកំណត់ទោសនានា។ គោលការណ៍ណែនាំស្តីពីនិយមន័យទាក់ទងនឹងបទល្មើសបរិស្ថានរបស់ចក្រភពអង់គ្លេស(Environmental Offences Definitive Guidelines) គឺជាឧទាហរណ៍មួយនៃគោលការណ៍ណែនាំបែបនេះ។ ការបង្កើតគោលការណ៍ណែនាំសម្រាប់ការផ្តន្ទាទោសដើម្បីដោះស្រាយឧក្រិដ្ឋកម្មកាកសំណល់ ដែលក្នុងនោះរួមមានបទប្បញ្ញត្តិផ្តន្ទាទោសបន្ទាប់បន្សំ និងបទប្បញ្ញត្តិស្តីពីការស្តារមកវិញនូវប្រព័ន្ធយុត្តិធម៌ក្នុងកម្រិតថ្នាក់ជាតិ ត្រូវតែគោរពតាមវិធានរបស់តុលាការក្នុងដែនយុត្តាធិការរបស់ជាតិនីមួយៗ។

## ៥.១ ការផ្តន្ទាទោសចំពោះសំណុំរឿងកាកសំណល់

ប្រសិនបើការកាត់ទោសមានគោលបំណងដើម្បីធានាថាច្បាប់ស្តីពីការដឹកជញ្ជូនកាកសំណល់ខុសច្បាប់ ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ នោះការផ្តន្ទាទោស ចាំបាច់ត្រូវមានសារៈសំខាន់ដើម្បីដើរតួជាការធ្វើឲ្យខ្លាចរអាដល់អ្នកដឹកជញ្ជូននិងគេងចំណេញពីកាកសំណល់ខុសច្បាប់។ ការពិន័យជាធម្មតា មានចែងនៅក្នុងច្បាប់ជាតិស្តីពីកាកសំណល់ ឬអាចត្រូវបានកែប្រែដោយយោងតាមការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនោះ។

ការផាកពិន័យជាអតិបរមា ជាទូទៅមានចែងនៅក្នុងច្បាប់ដែលពាក់ព័ន្ធ។ លក្ខខណ្ឌកាត់បន្ថយទោសនិងស្ថានទម្ងន់ទោស អាចត្រូវយកមកពិចារណានៅពេលកាត់ទោស។ ដែនយុត្តាធិការខ្លះ មានគោលការណ៍ណែនាំយ៉ាងទូលំទូលាយដែលរួមបញ្ចូលនូវលក្ខខណ្ឌទាំងនេះដោយស្របតាមគោលការណ៍ដែលបានបង្កើតឡើងដើម្បីផ្តល់នូវភាពស្ថិតស្ថេរនិងកម្រិតនៃការផ្តន្ទាទោសដែលគេចង់បានឬដែលចាំបាច់។

រឿងនេះ ពិតជាមានតម្លៃណាស់ក្នុងការផ្តល់ប្រសិទ្ធភាពចំពោះកាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌ៤នៃមាត្រា ៤ នៃសន្និបាត Basel៖ *"ក្នុងចាត់វិធានការផ្នែកច្បាប់ ផ្នែករដ្ឋបាល និងវិធានការសមស្របនានាផ្សេងទៀតដើម្បីពង្រឹងនិងអនុវត្តបទប្បញ្ញត្តិនៃសន្និបាតនេះ ក្នុងនោះរួមមានវិធានការក្នុងការទប់ស្កាត់និងផ្តន្ទាទោសចំពោះការប្រព្រឹត្តិផ្ទុយនឹងសន្និបាតនេះ"*។

វិធីសាស្រ្តដែលប្រើគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោស អាចមានតំលៃជាពិសេសសម្រាប់សំណុំរឿងដែលកាត់ទោសនៅក្នុងតុលាការដែលមិនមានជំនាញពិសេស ដែលប្រហែលមានការកាត់ទោសផ្នែកបរិស្ថានតិចតួច។ លើសពីនេះទៀត ចំពោះអ្វីដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌរបស់សហភាពអឺរ៉ុប ឧទាហរណ៍នានានៃសំណុំរឿងដែលត្រូវបានដោះស្រាយដោយតុលាការយុត្តិធម៌របស់សហភាពអឺរ៉ុប អាចត្រូវបានគេប្រើជាឧបករណ៍សម្រាប់បកស្រាយនិងអនុវត្តច្បាប់ជាតិ។[7]

គោលការណ៍ដ៏មានប្រយោជន៍ជាច្រើនដែលត្រូវយកមកពិចារណានៅពេលកំណត់ការផ្តន្ទាទោស ដោយផ្អែកលើសំណួរដែលគេជារឿយៗចោទសួរ អាចត្រូវបានអនុវត្តចំពោះការពិចារណាលើផ្តន្ទាទោសណាមួយទាក់ទងនឹងការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។ តួយ៉ាង មាត្រា៣នៃសារាចរ ២០០៨/៩៩/EC មាត្រា ៣៦នៃសារាចរស្តីពីក្របខ័ណ្ឌកាកសំណល់ និងមាត្រា៥០ នៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់ បានចែងថា ការផ្តន្ទាទោសចំពោះបទល្មើសដែលបានលើកឡើង ត្រូវតែមាន "**ប្រសិទ្ធភាព លក្ខណៈសមរម្យ និងលក្ខណៈបង្កឲ្យមានការខ្លាចរអា**"។ គំនិតទាំងបីនេះ អនុញ្ញាតឱ្យផ្សារភ្ជាប់ភាពធ្ងន់ធ្ងរនៃការផ្តន្ទាទោសទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស (សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់ព័ត៌មានលម្អិត)។

ការពិចារណាលើការផ្តន្ទាទោស គឺជាកត្តាទូទៅដែលអាចពិចារណាដោយតុលាការ/ចៅក្រមនៅពេលធ្វើសេចក្តីសម្រេចលើការផ្តន្ទាទោស។ ជាធម្មតា ការពិចារណាទាំងនេះ មានចែងក្រោមច្បាប់ដែលពាក់ព័ន្ធ។ ខាងក្រោមនេះ គឺជាបញ្ជីមិនពេញលេញនៃកត្តាដែលអាចត្រូវបានគេពិចារណានៅកម្រិតការផ្តន្ទាទោស ក្នុងការរៀបចំដាក់ស្នើកាត់ទោស៖

- ផលប៉ះពាល់ឬផលប៉ះពាល់ដែលអាចមាន ដែលបណ្តាលមកពីបទល្មើស រួមមាន៖
    - ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ ឬហានិភ័យនៃផលប៉ះពាល់ លើបរិស្ថាន
    - ឬ សក្តានុពលនៃផលប៉ះពាល់ដែលនឹងត្រូវកែតម្រូវ ឬកាត់បន្ថយ។
- ពិរុទ្ធភាពនៃបទល្មើស ដែលរួមមាន៖
    - វិធានការដែលអនុវត្តដោយចុងចោទដើម្បីកែតម្រូវ ឬកាត់បន្ថយផលប៉ះពាល់
    - កម្រិតនៃការសហការរបស់ចុងចោទជាមួយនឹងនាយកដ្ឋាន
    - ការកាត់ទោសពីមុនៗចំពោះចុងចោទ ពាក់ព័ន្ធនឹងបញ្ហាដែលគេកំពុងពិចារណា
    - ផលប្រយោជន៍ណាមួយ ឬផលចំណេញដែលចុងចោទទទួលបានពីការប្រព្រឹត្តបទល្មើស។
- កម្រិតនៃការផ្តន្ទាទោសដើម្បីទប់ស្កាត់អ្នកដទៃកុំឲ្យប្រព្រឹត្តទង្វើស្រដៀងគ្នានេះ
- ភាពទូទៅនៃបទល្មើស

[7] សម្រាប់ឧទាហរណ៍ សូមមើលបណ្តុំនៃសំណុំរឿងអំពីការដឹកជញ្ជូនកាកសំណល់ ដែលមាននៅក្នុងគេហទំព័រ៖ https://ec.europa.eu/environment/waste/shipments/case_law.htm ឬមើលក្នុងគេហទំព័ររបស់តុលាការនៃសហភាពអឺរ៉ុប ៖ https://curia.europa.eu/jcms/jcms/j_6/en/

- វត្តមាននិងភាពសមរម្យនៃសាលក្រមកាត់ទោសបន្ទាប់បន្សំ
- ការផ្តន្ទាទោសអតិប្បរមាចំពោះបទល្មើស
- រឿងក្តីកាត់ទោសពីមុនឬសំណុំរឿងស្រដៀងគ្នានេះផ្សេងៗទៀត

បន្ថែមពីលើការផ្តន្ទាទោស ការផាកពិន័យ ឬដីការបង្គាប់បញ្ជាណាមួយដែលអាចនឹងធ្វើឡើងដោយតុលាការក្រោមច្បាប់ដែលពាក់ព័ន្ធ បទប្បញ្ញត្តិស្តីពីឧក្រិដ្ឋកម្មបរិស្ថានមួយចំនួន បានចែកនូវបទបញ្ជាដាក់លាក់បន្ថែមលើការផ្តន្ទាទោសជនល្មើសពីបទល្មើសជាក់លាក់មួយចំនួន។ វត្តមាននៃបទបញ្ជាបន្ថែមទាំងនេះ គឺដើម្បីផ្តល់ជូនតុលាការនូវភាពបត់បែនក្នុងការផ្តន្ទាទោស ឬការបង្គាប់បញ្ជាដែល៖

- មានភាពសមរម្យ និងបង្កើតឡើងស្របតាមកាលទេសៈជាក់ស្តែងនៃសំណុំរឿង
- នឹងពង្រឹងការអនុលោមតាមច្បាប់ និងធ្វើការទប់ស្កាត់ប្រកបដោយជោគជ័យ
- នឹងធ្វើឲ្យមានការផ្តល់ជាសំណងចំពោះផលប៉ះពាល់នានាដែលកើតមាន
- នឹងទទួលបានមកវិញនូវផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុដែលគេទទួលបានពីការរំលោភបំពានច្បាប់។
- នឹងស្តារនិងបង្កើននូវផលប្រយោជន៍សាធារណៈ

ដែនយុត្តាធិការផ្សេងទៀតនៅជុំវិញពិភពលោក បានបញ្ចូលបទបញ្ជាទាំងនេះចូលទៅក្នុងច្បាប់របស់ខ្លួន ហើយជួនកាលបានអនុវត្តបទបញ្ជាទាំងនេះប្រកបដោយជោគជ័យផងដែរ។ ទាំងនេះ អាចរួមបញ្ចូលការទូទាត់ចូលក្នុងមូលនិធិស្តារបរិស្ថានឡើងវិញ បទបញ្ជាឲ្យបោះពុម្ពផ្សាយ និងបទបញ្ជាឲ្យផ្លាស់ប្តូរគោលនយោបាយនិងការអនុវត្តនានាដែលរួមមានការបណ្តុះបណ្តាលបុគ្គលិកក្រុមហ៊ុនផងដែរ ដើម្បីទប់ស្កាត់បទល្មើសផ្សេងៗទៀត។

## ៥.២ ការផ្តន្ទាទោសចាំបាច់នានា

ច្បាប់មួយចំនួនស្តីពីកាកសំណល់ ផ្តល់នូវបញ្ជីមួយអំពីហេតុផលក្នុងការព្យួរឬការលុបចោលនូវលិខិតអនុញ្ញាតអាជ្ញាប័ណ្ណ ឬសិទ្ធិនានា។ ហេតុផលទាំងនេះ អាចរួមមាន ការខកខានមិនបានអនុវត្តនូវលក្ខខណ្ឌផ្នែករដ្ឋបាលដូចជាការបង់ថ្លៃសេវាឬការមិនបានបង់ពន្ធជាដើម។ ហេតុផលទាំងនេះ ក៏អាចរួមបញ្ចូលនូវម្ចាស់អាជ្ញាបណ្ណដែលត្រូវបានផ្តន្ទាទោសដោយច្បាប់នោះឬមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យសមស្របរបស់លិខិតអនុញ្ញាតអាជ្ញាប័ណ្ណ ឬសិទ្ធិទាំងនោះ។

ការទូទាត់ប្រាក់តាមពេលវេលាកំណត់ ក្រោមច្បាប់ គឺជាកាតព្វកិច្ចដ៏សំខាន់របស់អ្នកដែលទទួលបានលិខិតអនុញ្ញាតពីនាយកដ្ឋាន។ ប្រតិបត្តិករដែលខកខានមិនបានបង់ប្រាក់ ទទួលបានអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្មពីដៃគូប្រកួតប្រជែងរបស់ខ្លួន ហើយអាចធ្វើឱ្យកាត់បន្ថយភាពស្របច្បាប់នៃបទប្បញ្ញត្តិផងដែរ។ ក្នុងករណីដែលច្បាប់ត្រូវបានអនុវត្តដោយលិខិតអនុញ្ញាតដែលចេញដោយនាយកដ្ឋាន នោះនាយកដ្ឋាន អាចនឹងផ្អាកឬលុប

ចោលនូវលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬសិទ្ធិដែលពាក់ព័ន្ធរបស់ប្រតិបត្តិករនោះដែលមិនបានបង់ប្រាក់តាមការកំណត់។ នៅពេលសម្រេចថាតើត្រូវលុបចោលឬព្យួរអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬសិទ្ធិរបស់ប្រតិបត្តិការ គេ ត្រូវតែអនុលោមតាមលក្ខខណ្ឌច្បាប់។ គោលបំណងនៃការលុបចោលឬការព្យួរលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬសិទ្ធិនានានោះ មិនមែនជាទណ្ឌកម្មទេ។ ផ្ទុយទៅវិញវា ផ្អែកលើលក្ខខណ្ឌក្នុងការពារភាពសុច្ចរិតនៃច្បាប់បរិស្ថាននិងសហគមន៍ពីប្រតិបត្តិករដែលមិនសមស្រប។

បន្ថែមលើបញ្ហាខាងលើ ការវាយតម្លៃលើការខូចខាតចំពោះបរិស្ថានដែលជាផ្នែកមួយនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ នឹងចាំបាច់ត្រូវធ្វើឡើងដោយស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ជាតិ។ ដែនយុត្តាធិការខ្លះ អាចមានបទប្បញ្ញត្តិច្បាប់ជាក់លាក់សម្រាប់ការលុបចោលឬការព្យួរអាជ្ញាប័ណ្ណឬកិច្ចព្រមព្រៀងនានាដែលនឹងហាមឃាត់ឬកម្រិតសមត្ថភាពរបស់ភាគីដែលត្រូវបានផ្តន្ទាទោសមិនឲ្យធ្វើការទាក់ទងនឹងអាជីវកម្មកាកសំណល់ទៀត។ បញ្ហានេះ អាចដាក់បន្ទុកផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំងទៅលើភាគីដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកាកសំណល់ និងជាការអនុវត្តដ៏ល្អមួយនៃគោលការណ៍អំពីអ្នកបំពុលបរិស្ថានត្រូវតែទទួលខុសត្រូវក្នុងការចំណាយនានា (សូមមើលផ្នែកពាក់ព័ន្ធនៅក្នុងសេចក្តីផ្តើម)។

ទោះបីជាគេ មិនបានលើកឡើងដោយផ្ទាល់នៅក្នុងសន្និបាត Basel ក៏ដោយ គេ បានព្រមព្រៀងជាទូទៅថាភាគីដែលទទួលខុសត្រូវចំពោះការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ គប្បីទទួលខុសត្រូវផងដែរចំពោះការចំណាយលើការបញ្ជូនឬការធ្វើបត្យាប័នកាកសំណល់ត្រឡប់មកវិញ។ នៅក្នុងសហគមន៍អឺរ៉ុបមាត្រា ២៥ នៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់ លើកឡើងថាការចំណាយលើការធ្វើការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញ ជាចំបងត្រូវតែទូទាត់ដោយអ្នកដែលបានរៀបចំដឹកជញ្ជូនកាកសំណល់។ ក្នុងករណីដែលបុគ្គលនោះ មិនមានវត្តមានឬមិនអាចបង់ថ្លៃចំណាយនោះបាន ប្រទេសដើមនៃកាកសំណល់ ត្រូវតែបង់ថ្លៃដឹកជញ្ជូនកាកសំណល់ត្រឡប់ទៅវិញ។ គេ ក៏ផ្តល់និយមន័យចំពោះការចំណាយនៃការបញ្ជូនកាកសំណល់ត្រឡប់ទៅវិញផងដែរ ដែលរួមមានថ្លៃដឹកជញ្ជូនទំនិញ ថ្លៃជួលទូរកុងតឺន័រ និងសកម្មភាពបោសសម្អាតនានាដែលគេតម្រូវឲ្យធ្វើក្រោយពេលបញ្ជូនកាកសំណល់ទៅប្រទេសដើមវិញ។

## ៥.៣ ការរាយការណ៍និងការត្រួតពិនិត្យ

ទីភ្នាក់ងារអេយ្យការ គប្បីផ្តល់របាយការណ៍ដ៏ល្អជូនសហគមន៍អំពីសកម្មភាពនានាដែលគេបានអនុវត្តក្នុងការដោះស្រាយឧក្រិដ្ឋកម្មបរិស្ថាន។ ការរាយការណ៍ជាទៀងទាត់អំពីជោគជ័យនិងបរាជ័យនានា អាចជួយកទប់ស្កាត់ឧក្រិដ្ឋកម្មកាកសំណល់បាន និងជំរុញឲ្យមានការរាយការណ៍បន្ថែមទៀតអំពីឧក្រិដ្ឋកម្មកាកសំណល់។

លើសពីនេះទៀត សន្និសីទរបស់រដ្ឋភាគីនៃសន្និបាត Basel បានស្នើសុំឱ្យភាគីនានារាយការណ៍អំពីករណីឬសំណុំរឿងដែលគេបានចោទប្រកាន់ថាជាចរាចរណ៍កាកសំណល់ខុសច្បាប់ ជូនទៅលេខាធិការដ្ឋាននៃសន្និបាត Basel ឲ្យបានដឹង និងផ្តល់នូវព័ត៌មានចាំបាច់នានាទាំងអស់ ដើម្បីចាត់វិធានការសមស្របណាមួយ។ ទម្រង់បែបបទពិសេសមួយ មាននៅលើគេហទំព័ររបស់លេខាធិការដ្ឋាននៃសន្និបាតនេះ (website)។

ការត្រួតពិនិត្យបទបញ្ញាផ្នែករដ្ឋបាលនិងការដោះស្រាយឬការបញ្ជាឲ្យលាងសម្អាតបរិស្ថាន  ក៏សំខាន់ផងដែរក្នុង ការធានាថាប្រព័ន្ធអនុលោមតាមច្បាប់និងការអនុវត្តច្បាប់ មានដំណើរការល្អ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ – យន្តការអន្តរជាតិ

សន្និបាតស្តីអំពីការគ្រប់គ្រងលើការដឹកជញ្ជូនឆ្លងដែននិងការបោះចោលនូវកាកសំណល់គ្រោះថ្នាក់ (Basel Convention, 1989)

សន្និបាតស្តីអំពីពាណិជ្ជកម្មអន្តរជាតិចំពោះប្រភេទសត្វនិងរុក្ខាជាតិដែលរងការគំរាមកំហែង (CITES 1963)

សន្និបាតអន្តរជាតិ ស្តីអំពីការទប់ស្កាត់ការបំពុលបរិស្ថានពីនាវា (MARPOL, 1973)

ផែនការសកម្មភាពអន្តរជាតិដើម្បីបង្កា ទប់ស្កាត់ និងកាត់បន្ថយការនេសាទខុសច្បាប់ដែលមិនបានរាយការណ៍ និងដែលមិនមានការគ្រប់គ្រង (FAO, 2001)

សន្និបាត Minamata ស្តីអំពីបារត (Minamata Convention, 2013)

ពិធីសារ Montreal ស្តីអំពីសារធាតុដែលធ្វើឲ្យធ្លុះធ្លាយស្រទាប់អូសូន (Montreal Protocol, 1987)

សន្និបាត Rotterdam ស្តីអំពីនិតិវិធីបង្ហាញការយល់ព្រមដែលបានទទួលដំណឹងជាមុន សម្រាប់សារធាតុគីមី និងថ្នាំសម្លាប់សត្វល្អិត នៅក្នុងពាណិជ្ជកម្មអន្តរជាតិ (Rotterdam Convention, 1998)

សន្និបាត Stockholm ស្តីអំពីសារធាតុសរីរាង្គបំពុលបរិស្ថាន (Stockholm Convention, 2001)

សេចក្តីប្រកាស Stockholm (1972)

សន្និបាត Vienna សម្រាប់ការការពារស្រទាប់អូសូន (Vienna Convention, 1985)

## ឧបសម្ព័ន្ធ ២ – និយមន័យនានា ក្រោមសន្និបាត Basel

ខាងក្រោមនេះ គឺជានិយមន័យដែលពាក់ព័ន្ធ ក្រោមសន្និបាត Basel ( Secretariat of the Basel Convention and UNEP, 2012 )

"**កាកសំណល់**" គឺជាសារធាតុ ឬវត្ថុដែលត្រូវបានគេបោះចោល ឬមានបំណងបោះចោល ឬតំរូវអោយបោះចោល ដោយបទប្បញ្ញត្តិនៃច្បាប់ជាតិ។

"**ការគ្រប់គ្រងកាកសំណល់**" មានន័យថាការប្រមូល ការដឹកជញ្ជូន និងការបោះចោលកាកសំណល់ដែលមានគ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ក្នុងនោះរួមមានការថែរក្សាទីតាំងនោះក្រោយពេលបោះចោលកាកសំណល់ ផងដែរ។

"**ការចល័តកាកសំណល់ឆ្លងដែន**" មានន័យថាការចល័តណាមួយនៃកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងៗទៀតចេញពីតំបន់មួយដែលស្ថិតនៅក្រោមដែនយុត្តាធិការជាតិនៃរដ្ឋមួយទៅ ឬឆ្លងកាត់តំបន់មួយទៀតដែលស្ថិតនៅក្រោមដែនយុត្តាធិការជាតិនៃរដ្ឋមួយផ្សេងទៀត ឬឆ្លងកាត់តំបន់ដែលមិនស្ថិតក្រោមដែនយុត្តាធិការជាតិនៃរដ្ឋណាមួយ ដោយយ៉ាងហោចណាស់មានរដ្ឋចំនួនពីរពាក់ព័ន្ធនឹងការចល័តកាកសំណល់នោះ។

"**ការបោះចោលកាកសំណល់**" មានន័យថាប្រតិបត្តិការកាកសំណល់ណាមួយដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី IV នៃសន្និបាតនេះ។

"**កន្លែងឬទីតាំងដែលទទួលបានការអនុញ្ញាត**" មានន័យថា កន្លែង ឬទីតាំងសម្រាប់បោះចោលកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតដែលត្រូវទទួលបានសិទ្ធិឬលិខិតអនុញ្ញាតិឱ្យដំណើរការសម្រាប់គោលបំណងនេះ ដោយអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋដែលទីតាំងឬកន្លែងនោះស្ថិតនៅក្នុង។

"**អាជ្ញាធរមានសមត្ថកិច្ច**" មានន័យថាជាអាជ្ញាធររដ្ឋាភិបាលដែលត្រូវបានកំណត់ដោយភាគីមួយឲ្យទទួលខុសត្រូវក្នុងតំបន់ភូមិសាស្ត្រនានាដែលភាគីនោះ គិតថាសក្តិសម ដើម្បីទទួលបានសេចក្តីជូនដំណឹងអំពីការដឹកឆ្លងកាត់ព្រំដែននូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត និងព័ត៌មានដែលទាក់ទងនឹងការដឹកជញ្ជូននោះ ហើយដើម្បីឆ្លើយតបនឹងសេចក្តីជូនដំណឹងណាមួយ ដូចដែលមានចែងក្នុងមាត្រា ៦ ។

"**ស្ថាប័នកណ្តាល**" មានន័យថាអង្គភាពរបស់ភាគីមួយ ដែលមានចែងក្នុងមាត្រា៥ក្នុងការទទួលខុសត្រូវចំពោះការទទួលនិងបញ្ជូនព័ត៌មាន ដូចមានចែងក្នុងមាត្រា ១៣ និង ១៦ ។

"**ការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតដោយមិនឲ្យប៉ះពាល់ដល់បរិស្ថាន**" មានន័យថាការចាត់វិធានការជាក់ស្តែងទាំងអស់ ដើម្បីធានាថាកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់

ផ្សេងទៀត ត្រូវបានគ្រប់គ្រងតាមលក្ខណៈដែលនឹងការពារសុខភាពមនុស្សនិងបរិស្ថាន ដោយចៀសវាងផលប៉ះពាល់អវិជ្ជមានដែលអាចបណ្តាលមកពីកាកសំណល់។

"**តំបន់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចជាតិរបស់រដ្ឋ**" មានន័យថាដែនដី ដែនទឹក ឬដែនអាកាសដែលរដ្ឋអនុវត្តទំនួលខុសត្រូវផ្នែករដ្ឋបាលនិងផ្នែកបទប្បញ្ញត្តិស្របតាមច្បាប់អន្តរជាតិដែលទាក់ទងនឹងការការពារសុខភាពមនុស្ស ឬបរិស្ថាន។

"**រដ្ឋនាំចេញកាកសំណល់**" មានន័យថាជាភាគីមួយដែលគេ គ្រោងនឹងចាប់ផ្តើមឬផ្តួចផ្តើមធ្វើការដឹកឆ្លងកាត់ព្រំដែន នូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ។

"**រដ្ឋនាំចូលកាកសំណល់**" មានន័យថាជាភាគីមួយដែលគេបានគ្រោងឬធ្វើការដឹកឆ្លងកាត់ព្រំដែន នូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ក្នុងគោលបំណងបោះចោលកាកសំណល់ទាំងនោះនៅទៅនោះ ឬក្នុងគោលបំណងរក្សាទុកកាកសំណល់ មុនពេលគេបោះចោលកាកសំណល់ទាំងនោះនៅក្នុងតំបន់ណាមួយដែលមិនស្ថិតនៅក្រោមដែនសមត្ថកិច្ចជាតិរបស់រដ្ឋណាមួយ។

"**រដ្ឋកាកសំណល់ឆ្លងកាត់**" មានន័យថាជារដ្ឋណាមួយដែលមិនមែនជារដ្ឋនាំចេញឬនាំចូល តែជារដ្ឋដែលគេ គ្រោងនឹងដឹកកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតឆ្លងកាត់។

"**រដ្ឋពាក់ព័ន្ធ**" មានន័យថាជាភាគីដែលជារដ្ឋនាំចេញកាកសំណល់ឬនាំចូលកាកសំណល់ឬរដ្ឋដែលកាកសំណល់ឆ្លងកាត់ ជាភាគីឬមិនមែនជាភាគី។

"**បុគ្គល**" មានន័យថាជារូបវន្តបុគ្គលឬនីតិបុគ្គល។

"**អ្នកនាំចេញកាកសំណល់**" មានន័យថាបុគ្គលណាមួយដែលស្ថិតក្រោមដែនយុត្តិធិការរបស់រដ្ឋនាំចេញកាកសំណល់ ដែលជាអ្នករៀបចំកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀតដើម្បីនាំចេញ ។

"**អ្នកនាំចូលកាកសំណល់**" មានន័យថាជាបុគ្គលណាមួយដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់រដ្ឋនាំចូលកាកសំណល់ ដែលជាអ្នករៀបចំកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ដើម្បីនាំចូលកាកសំណល់។

"**អ្នកដឹកជញ្ជូន**" មានន័យថាជាបុគ្គលណាមួយដែលដឹកជញ្ជូនកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត។

"**អ្នកបង្កើតកាកសំណល់**" មានន័យថាបុគ្គលណាមួយដែលមានសកម្មភាពផលិតកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត ឬប្រសិនបើគេ មិនស្គាល់បុគ្គលនោះទេ អ្នកបង្កើតកាកសំណល់នោះ ជាបុគ្គលដែល កាន់កាប់ និង/ឬគ្រប់គ្រងកាកសំណល់ទាំងនោះ។

"**អ្នកបោះចោលកាកសំណល់**" មានន័យថាជាបុគ្គលណាមួយដែលគេបានដឹកកាកសំណល់ទៅឲ្យ និងជាអ្នកដែលយកកាកសំណល់ទៅបោះចោល។

"**អង្គការសមាហរណកម្មនយោបាយនិង/ឬសេដ្ឋកិច្ច**" មានន័យថាជាអង្គការមួយដែលត្រូវបានបង្កើតឡើងដោយរដ្ឋអធិបតេយ្យ ដែលរដ្ឋជាសមាជិករបស់ខ្លួន បានផ្ទេរសមត្ថកិច្ចឲ្យ ចំពោះបញ្ហានានាដែលមានចែងដោយសន្និបាតនេះ ហើយដែលទទួលបានការអនុញ្ញាតត្រឹមត្រូវស្របតាមនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួល អនុញ្ញាត បញ្ជាក់ជាផ្លូវការ ឬយល់ព្រមនឹងសន្និបាតនេះ។

"**ចរាចរណ៍កាកសំណល់ខុសច្បាប់**" មានន័យថាជាដឹកឆ្លងកាត់ព្រំដែននូវកាកសំណល់គ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត៖ (a) ដោយមិនមានការជូនដំណឹងស្របតាមបទប្បញ្ញត្តិនៃសន្និបាតនេះ ទៅឲ្យរដ្ឋទាំងអស់ដែលពាក់ព័ន្ធ។ ឬ (b) ដោយមិនមានការយល់ព្រមពីរដ្ឋដែលពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិនៃសន្និបាតនេះ ឬ (c) ដោយមានការយល់ព្រមពីរដ្ឋដែលពាក់ព័ន្ធតាមរយៈការបោកប្រាស់ ការបង្ហាញព័ត៌មានមិនពិត ឬការក្លែងបន្លំ។ ឬ (d) ដែលមិនអនុលោមតាមនីតិវិធីឯកសារ។ ឬ (e) ដែលនាំឱ្យមានការបោះចោលដោយចេតនានូវកាកសំណល់ដែលមានគ្រោះថ្នាក់ឬកាកសំណល់ផ្សេងទៀត (ឧទាហរណ៍ ការចាក់ចោលកាកសំណល់) ដោយបំពានលើសន្និបាតនេះនិងគោលការណ៍ទូទៅនានានៃច្បាប់អន្តរជាតិ។ សកម្មភាពទាំងនេះ នឹងត្រូវចាត់ទុកជាចរាចរណ៍កាកសំណល់ដោយខុសច្បាប់។

## ឧបសម្ព័ន្ធ ៣ – ក្របខណ្ឌច្បាប់កាកសំណល់របស់សហភាពអឺរ៉ុប

ផ្នែកនេះផ្តល់ព័ត៌មានលម្អិតអំពីក្របខ័ណ្ឌគតិយុត្តដែលអាចអនុវត្តបាននៅក្នុងសហភាពអឺរ៉ុប។[8] ដូចដែលបានបញ្ជាក់រួចមកហើយ ខណៈដែលវិសាលភាពនៃគោលការណ៍ណែនាំនេះ ផ្តោតលើការធ្វើពាណិជ្ជកម្មកាកសំណល់ឆ្លងដែនដោយខុសច្បាប់ វា ក៏មានបំណងផ្តល់ការណែនាំក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មកាកសំណល់ជាទូទៅផងដែរ។

បន្ថែមលើក្របខ័ណ្ឌគតិយុត្តថ្នាក់តំបន់ ឧបសម្ព័ន្ធ ៤ ក៏បានផ្តល់នូវបញ្ជីច្បាប់ជាតិពាក់ព័ន្ធផងដែរ។ មានការផ្លាស់ប្តូរជាច្រើនផងដែរនៅក្នុងច្បាប់និងបទប្បញ្ញត្តិជាតិស្តីពីកាកសំណល់ ដែលអាចជះឥទ្ធិពលដល់ការស៊ើបអង្កេតនិងការចោទប្រកាន់ឧក្រិដ្ឋកម្មកាកសំណល់។

### សារាចរ ២០០៨/៩៩/EC ស្តីអំពីការការពារបរិស្ថាន តាមរយៈច្បាប់ព្រហ្មទណ្ឌ

សារាចរនៅឆ្នាំ ២០០៨ / ៩៩ / EC (Directive 2008/99/EC) ស្តីពីឧក្រិដ្ឋកម្មបរិស្ថាន ផ្តោតលើការការពារបរិស្ថានក្នុងកម្រិតខ្ពស់របស់សន្ធិសញ្ញាស្តីពីការបំពេញមុខងាររបស់សហភាពអឺរ៉ុប (សូមមើលមាត្រា ១១ និង ១៩១)។ គេ បានបញ្ជាក់យ៉ាងច្បាស់ថា *"ប្រព័ន្ធនៃការផ្តន្ទាទោសដែលមានស្រាប់ មានលក្ខណៈមិនគ្រប់គ្រាន់ដើម្បីសម្រេចបាននូវការអនុលោមតាមច្បាប់ដើម្បីការការពារបរិស្ថាននៅឡើយទេ"* ហើយថាការអនុវត្តន៍បែបនេះ គប្បីត្រូវបានពង្រឹងតាមរយៈការប្រើប្រាស់ការផ្តន្ទាទោសព្រហ្មទណ្ឌបន្ថែមលើការផ្តន្ទាទោសផ្នែករដ្ឋបាល និងផ្នែករដ្ឋប្បវេណី ដើម្បីឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវកម្រិតនៃការមិនពេញចិត្តរបស់សង្គមចំពោះឧក្រិដ្ឋកម្មបរិស្ថាន។ សារាចរនេះ បង្កើតវិធានអប្បបរមាសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌនៅទូទាំងសហភាពអឺរ៉ុបជាកន្លែងដែលសកម្មភាពទាំងនេះ ត្រូវបានគេប្រព្រឹត្តដោយចេតនាឬដោយការធ្វេសប្រហែសខ្លាំង ហើយសារាចរនេះ អនុញ្ញាតឱ្យរដ្ឋជាសមាជិកអនុវត្តវិធានការតឹងរ៉ឹងជាងមុន (ដូចជាទំនួលខុសត្រូវចំពោះមុខច្បាប់យ៉ាងតឹងរ៉ឹងជាដើម) ប្រសិនបើវិធានការទាំងនេះ ត្រូវគ្នានឹងបទប្បញ្ញត្តិនៃសន្ធិសញ្ញារបស់សហគមន៍អឺរ៉ុប។ ជាពិសេស មាត្រា ៣ រួមបញ្ចូលការនាំចេញកាកសំណល់ខុសច្បាប់ (ប្រសិនបើធ្វើឡើងក្នុងបរិមាណមិនធ្វេសប្រហែស) ទៅក្នុងបញ្ជីបទល្មើសដែលត្រូវតែចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ។

សារាចរនៅឆ្នាំ ២០០៨ / ៩៩ / EC (Directive 2008/99/EC) បានចូលជាធរមាននៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ដោយមានកាលបរិច្ឆេតផុតកំណត់សម្រាប់ការកែតម្រូវថ្នាក់ជាតិនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០។

[8] ចំណាំ៖ ទាំងបទប្បញ្ញត្តិ ទាំងសារាចរ បានធ្វើនិយ័តកម្មលើក្របខណ្ឌកាកសំណល់នៅក្នុងសហភាពអឺរ៉ុប។ បទប្បញ្ញត្តិ អាចគេយកទៅអនុវត្តបានដោយផ្ទាល់នៅក្នុងរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុបទាំងអស់ ខណៈដែលសារាចរ ត្រូវបានគេបំលែងទៅជាច្បាប់ជាតិជាមុនសិនទើបអាចអនុវត្តបាន។

## សារាចរស្តីពីក្របខណ្ឌកាកសំណល់(WFD)

សារាចរ ២០០៨ /៩៩/ EC ស្តីពីក្របខណ្ឌកាកសំណល់(Waste Framework Directive 2008/98/EC ) បង្កើតទស្សនៈគោលនានានិងនិយមន័យមូលដ្ឋានទាក់ទងនឹងការគ្រប់គ្រងកាកសំណល់ ដូចជានិយមន័យនៃកាកសំណល់ ការកែច្នៃ និងការជួសជុលកាកសំណល់។ វា ពន្យល់ថានៅពេលណាដែលកាកសំណល់ឈប់ជាកាកសំណល់ ហើយក្លាយជាវត្ថុធាតុដើមបន្ទាប់បន្សំវិញ (ដែលគេហៅថាលក្ខណៈវិនិច្ឆ័យនៃកាកសំណល់ចុងក្រោយ) និងបង្កើតវិធីបែងចែករវាងកាកសំណល់និងផលិតផលនៃកាកសំណល់។ សារាចរនេះ ចែងអំពីគោលការណ៍ក្នុងការគ្រប់គ្រងកាកសំណល់ជាមូលដ្ឋានមួយចំនួន ដូចជា៖ វា តម្រូវឱ្យមានការគ្រប់គ្រងកាកសំណល់ដោយមិនបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សនិងមិនបង្កអន្តរាយដល់បរិស្ថាន និងជាពិសេសមិនបង្កហានិភ័យដល់ទឹក ខ្យល់ ដី រុក្ខជាតិ ឬសត្វ ដោយមិនបង្កភាពរំខានតាមរយៈសំលេងរំខានឬក្លិន ហើយនិងដោយមិនប៉ះពាល់ដល់ទីជនបទឬកន្លែងដែលមានចំណាប់អារម្មណ៍ពិសេស។ សារាចរនេះ បានគូសបញ្ជាក់ម្តងហើយម្តងទៀតអំពីគោលការណ៍"អ្នកបំពុលបរិស្ថាន ជាអ្នកទទួលខុសត្រូវចំពោះការចំណាយ" នៃសន្ធិសញ្ញារបស់សហភាពអឺរ៉ុប និងណែនាំអំពី "ទំនួលខុសត្រូវកាន់តែច្រើនរបស់អ្នកផលិត" - ដែលការរចនានិងការផលិតទំនិញ គប្បីតែជួយសម្រួលដល់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពក្នុងវដ្តជីវិតទាំងមូលរបស់ទំនិញ ក្នុងនោះរួមមានការជួសជុល ការប្រើប្រាស់ឡើងវិញ ការបំបែក និងការកែច្នៃឡើងវិញ ដោយមិនកែប្រែចរាចរទំនិញដោយសេរីនៅលើទីផ្សារផ្ទៃក្នុង។ សារាចរនេះ រួមមាននិយមន័យនៃកាកសំណល់និងកាកសំណល់គ្រោះថ្នាក់ដូចខាងក្រោម។ យោងតាមមាត្រា ៣ "កាកសំណល់" មានន័យថាជាសារធាតុឬវត្ថុណាមួយដែលគេបោះចោល ឬមានបំណងឬ ត្រូវបានគេតម្រូវអោយបោះចោល។

សារាចរអំពីក្របខណ្ឌកាកសំណល់ បានចូលជាធរមាននៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៨ ដោយមានថ្ងៃផុតកំណត់សម្រាប់ការកែតម្រូវថ្នាក់ជាតិនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១០។ ព័ត៌មានបន្ថែមស្តីពីការកែតម្រូវនេះ អាចរកបាននៅលើគេហទំព័ររបស់សហភាពអឺរ៉ុប (EU website.)។

បញ្ជីនៃសេចក្តីសម្រេចអំពីកាកសំណល់ឆ្នាំ២០០០/៥៣២/EC ( List of Waste Decision 2000/532/EC[9] ) បង្កើតនូវប្រព័ន្ធធ្វើចំណាត់ថ្នាក់មួយសម្រាប់កាកសំណល់នានា ក្នុងនោះរួមការបែងចែករវាងកាកសំណល់គ្រោះថ្នាក់និងគ្មានគ្រោះថ្នាក់។ កាកសំណល់គ្រោះថ្នាក់ ត្រូវបានសម្គាល់ដោយសញ្ញាផ្កាយ។ បញ្ជីនេះ បង្កើតនូវប្រភេទនៃកាកសំណល់ចំនួន ២០ ប្រភេទដែលប្រភេទនីមួយៗមានប្រភេទរងរបស់ខ្លួន ហើយប្រភេទនីមួយៗត្រូវបានគេផ្តល់លេខកូដចំនួន ៦ ខ្ទង់។ បញ្ជីនេះ បង្កើតកម្មវិធីនៃការបែងចែកប្រភេទទូទៅសម្រាប់កាកសំណល់នានានៅទូទាំងសហភាពអឺរ៉ុប និងសម្រួលដល់ការត្រួតពិនិត្យកាកសំណល់ពីដើមរហូតដល់ចប់។ បញ្ជីនេះ ត្រូវ

[9] ត្រូវបានធ្វើវិសោធនកម្មដោយសម្រេចក្តីសម្រេចរបស់គណកម្មការអឺរ៉ុប Commission Decision (EU) No 2014/955/EU ដែលធ្វើវិសោធនកម្មលើសេចក្តីសម្រេច ២០០០/៥៣២/EC នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៤ លើបញ្ជីនៃកាកសំណល់យោងតាមសារាចរស្តីពីក្របខណ្ឌកាកសំណល់ លេខ ២០០៨/៩៨/ EC (OJ L 370, 30.12.2014, p. 44–86)

បានផ្សាភ្ជាប់ល្អិតល្អន់ទៅនឹងបញ្ជីនៃលក្ខណៈសំខាន់ៗដែលនាំឱ្យមានកាកសំណល់គ្រោះថ្នាក់ដែលមាននៅក្នុងឧបសម្ព័ន្ធទី III ទៅនឹងក្នុងសារាចរស្តីអំពីក្របខណ្ឌកាកសំណល់ ។[10]

សេចក្តីជូនដំណឹងរបស់គណកម្មការអឺរ៉ុប ២០១៨/C១២៤/០១ (Commission notice 2018/C124/01)ស្តីពីការណែនាំផ្នែកបច្ចេកទេសស្តីពីការធ្វើចំណាត់ថ្នាក់កាកសំណល់ ផ្តល់នូវការបញ្ជាក់និងណែនាំដល់អាជ្ញាធរជាតិនានាដែលរួមមានអាជ្ញាធរមូលដ្ឋាននិងអាជីវកម្មនានា ស្តីពីការបកស្រាយនិងការអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់ពាក់ព័ន្ធរបស់សហភាពអឺរ៉ុបទាក់ទងនឹងចំណាត់ថ្នាក់នៃកាកសំណល់ មានដូចជាការកំណត់អត្តសញ្ញាណលក្ខណៈគ្រោះថ្នាក់របស់កាកសំណល់ ដោយធ្វើការវាយតម្លៃថាតើកាកសំណល់មានលក្ខណៈ គ្រោះថ្នាក់ឬទេ ហើយចុងក្រោយ ធ្វើចំណាត់ថ្នាក់កាកសំណល់ទាំងនោះថាជាកាកសំណល់គ្រោះថ្នាក់ឬមិនគ្រោះថ្នាក់។

## បទប្បញ្ញត្តិស្តីអំពីការដឹកជញ្ជូនកាកសំណល់ខុសច្បាប់ (WSR)

បទបញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់(Waste Shipment Regulation 1013/2006/EC) (ក្នុងទម្រង់កែតម្រូវ) មានចែងនូវនីតិវិធីសម្រាប់ការដឹកឆ្លងដែន (ឧទាហរណ៍ ការដឹកជញ្ជូន) នៃកាកសំណល់ និងបញ្ចូលបទប្បញ្ញត្តិនៃសន្និបាត Basel ចូលទៅក្នុងច្បាប់របស់សហភាពអឺរ៉ុប និងសេចក្តីសម្រេចរបស់អង្គការ OECD ។ បទប្បញ្ញត្តិនេះ រួមបញ្ចូលទាំងការហាមឃាត់ចំពោះការនាំចេញនូវកាកសំណល់គ្រោះថ្នាក់ទៅប្រទេសដែលមិនមែនជាសមាជិករបស់អង្គការ OECD មិនថាដើម្បីបោះចោលឬជួសជុលឡើងវិញឡើយ និងមានការហាមឃាត់មិនឲ្យនាំចេញកាកសំណល់ដើម្បីបោះចោលទៅគ្រប់ទីកន្លែង (វិសោធនកម្មបំរាមរបស់សន្និបាត Basel (Basel Ban Amendment)បានចូលជាធរមាននៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៩) ។

ដើម្បីធានាឲ្យបាននូវការស្វែងយល់ជាទូទៅនៃរបៀបដែលគេបានបកស្រាយបទប្បញ្ញត្តិ (EC) (លេខ ១០៣១/២០០៦) ស្តីពីការដឹកជញ្ជូនកាកសំណល់ គោលការណ៍ណែនាំរបស់ភាគីទទួលបន្ទុក(Correspondents' Guidelines ) ត្រូវបានព្រមព្រៀងដោយភាគីនានាដែលទទួលបន្ទុកដឹកជញ្ជូនកាកសំណល់របស់រដ្ឋដែលជាសមាជិករបស់សហភាពអឺរ៉ុប។ បណ្តាញព្រះរាជអាជ្ញានៃសហអឺរ៉ុបដើម្បីបរិស្ថាន (ENPE) ក៏បានផ្សព្វផ្សាយវីដេអូណែនាំ(video)ដែលពន្យល់អំពីគោលការណ៍គ្រឹះនៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់ផងដែរ។

បទប្បញ្ញត្តិ WSR ចូលជាធរមាននៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៦ ហើយអាចអនុវត្តបានដោយផ្ទាល់នៅគ្រប់រដ្ឋជាដែលជាសមាជិករបស់សហភាពអឺរ៉ុប។

## តើអ្វីទៅជាកាកសំណល់? និយមន័យនៃកាកសំណល់ក្រោមបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប

10 ត្រូវបានធ្វើវិសោធនកម្មដោយគណកម្មការនិយ័តកម្មរបស់សហភាពអឺរ៉ុប (EU) លេខ ១៣៥៧/២០១៤ ដែលធ្វើការជំនួសឧបសម្ព័ន្ធ III នៃសារាចរ ២០០៨/៩៨/EC នៃសភាអឺរ៉ុប និងនៃក្រុមប្រឹក្សាអំពីកាកសំណល់និងធ្វើមោឃភាពនូវសារាចរមួយចំនួន (OJ L 365/89, 19.12.2014)

ដើម្បីអនុវត្តបទប្បញ្ញត្តិ WSR (និងសន្និបាត Basel )បាន សារជាតុដែលគេកំពុងដឹកជញ្ជូន ត្រូវតែជាកាកសំណល់។ ការកាត់ទោសភាគច្រើន នឹងផ្អែកលើថាតើវត្ថុឬសារជាតុនោះ ជាកាកសំណល់ឬមិនមែន។ ដោយបានបង្កើតជាតុដ៏សំខាន់បំផុតនេះរួចហើយ ជំហានបន្ទាប់ គឺត្រូវកំណត់ថាតើការដឹកជញ្ជូននេះខុសច្បាប់ឬទេ។ បទប្បញ្ញត្តិ WSR ពឹងផ្អែកទៅលើសារាចរអំពីក្របខ័ណ្ឌកាកសំណល់ឆ្នាំ ២០០៨ សម្រាប់និយមន័យសំខាន់ៗទាំងអស់។ ដូច្នេះ៖

*កាកសំណល់ត្រូវបានគេឲ្យនិយមន័យថាជា "សារជាតុឬវត្ថុណាមួយដែលគេបានបោះចោល ឬមានបំណងបោះចោល ឬត្រូវបានគេតម្រូវឱ្យបោះចោល"* និង

កាកសំណល់គ្រោះថ្នាក់ គឺជាកាកសំណល់ណាមួយដែលមានលក្ខណៈមួយឬច្រើនដែលបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធទី ៣ នៅក្នុងសារាចរ WFD ។

មានច្បាប់យុត្តិសាស្ត្រ ជាច្រើនបានថែងពីនិយមន័យនៃកាកសំណល់ ប៉ុន្តែ គោលការណ៍សំខាន់ៗ ត្រូវបានសង្ខេបដូចតទៅ៖

គេ មិនអាចបកស្រាយយ៉ាងតឹងរ៉ឹងទេចំពោះទស្សនៈអំពីកាកសំណល់ឡើយ ។ សំណុំរឿងនីមួយៗ ត្រូវតែកំណត់ដោយអង្គហេតុរៀងៗខ្លួន។ ជាឧទាហរណ៍ វា អាចនិយាយថាតើក្រដាសដែលគេបានបោះចោល គឺជាកាកសំណល់ដែលវា មានភាពងាយស្រួលជាងគ្រឿងអគ្គីសនី ឬផលិតផលបន្ទាប់បន្សំដែលកើតចេញពីផលិតកម្ម។

ការបោះចោល មានន័យថា ការបោះបង់អ្វីមួយដែលគេលែងត្រូវការប្រើតាមគោលបំណងដំបូងឡើយរបស់វាពីព្រោះវា មិនសមស្រប គេលែងចង់បានវា ឬគេមានតម្រូវការបន្ថែមពីលើវត្ថុនោះ ហើយការបោះចោលវត្ថុនោះត្រូវតែធ្វើការបកស្រាយដោយផ្អែកលើគោលបំណងរបស់សារាចរWFD, សន្ធិសញ្ញាEC ក៏ដូចជាបទប្បញ្ញត្តិ WSR ផងដែរ។

អង្គហេតុដែលថាវត្ថុដែលត្រូវបានគេបោះចោលមានតម្លៃផ្នែកសេដ្ឋកិច្ច មិនបានរារាំងវត្ថុនោះមិនឲ្យក្លាយជាកាកសំណល់នោះទេ។;

ប្រសិនបើវត្ថុមួយជាកាកសំណល់ តើមានអ្វីកើតឡើងចំពោះវាក្នុងកម្រិតណាដែលអាចផ្លាស់ប្តូរស្ថានភាពរបស់វាពីកាកសំណល់ទៅជាមិនមែនជាកាកសំណល់វិញ។ បើមិនដូច្នោះទេ វត្ថុនោះនៅតែជាកាកសំណល់ដដែល។ លក្ខណៈវិនិច្ឆ័យនៃកាកសំណល់ក្នុងលក្ខណៈចុងក្រោយរបស់វា ត្រូវបានកំណត់នៅក្នុងមាត្រា ៦ (១)និង(២) នៃសារាចរ WFD ហើយគណៈកម្មការអឺរ៉ុបបានរៀបចំនូវលក្ខណៈវិនិច្ឆ័យអំពីលក្ខណៈចុងក្រោយនៃប្រភេទកាកសំណល់ជាអាទិភាពផងដែរ(set of end-ofwaste criteria for priority waste streams. )។

កាកសំណល់ខុសគ្នាពី"ផលិតផលបន្ទាប់បន្សំក្រោយផលិកម្ម" ដែលកំណត់ដោយមាត្រា ៥ នៃសារាចរ WFD ថាជា"សារជាតុឬវត្ថុដែលបានមកពីដំណើរការផលិតកម្មដែលមិនមានគោលបំណងចម្បងក្នុងការផលិតវត្ថុនោះ"។

គណៈកម្មការអឺរ៉ុប បានបង្កើតគោលការណ៍ណែនាំស្តីពីបញ្ហាកាកសំណល់និងផលិតផលបន្ទាប់បន្សំក្រោយផលិតកម្ម (guidance on the issue of waste and by-products. )។

បន្ថែមពីលើបទប្បញ្ញត្តិនិងច្បាប់យុត្តិសាស្ត្រ គេ អាចមានឯកសារណែនាំដែលអាចជួយក្នុងការបញ្ជាក់ថាតើវត្ថុមួយជាកាកសំណល់ឬមិនមែន ឯកសារទាំងនោះមានដូចជាគោលការណ៍ណែនាំជាតិស្តីពីសុវត្ថិភាពសំបកកង់ គោលការណ៍ណែនាំដែលចេញផ្សាយដោយអង្គភាពពាណិជ្ជកម្មនានា (ឧទាហរណ៍ដូចជា ក្រដាសកំប៉ុសឬកាកសំណល់ក្រដាស) ឬសហភាពអឺរ៉ុប។ ជាក់ស្តែង៖

គោលការណ៍ណែនាំរបស់ភាគីទទួលបន្ទុករបស់សហភាពអឺរ៉ុប(EU Correspondents' Guidelines )ត្រូវបានព្រមព្រៀងដោយភាគីទទួលបន្ទុកក្នុងការដឹកជញ្ជូនកាកសំណល់នៃរដ្ឋដែលជាសមាជិករបស់សហភាពអឺរ៉ុប និងតំណាងឱ្យការយល់ដឹងរួមគ្នាអំពីវិធីដែល គេ គប្បីបកស្រាយបទប្បញ្ញត្តិ WSR ។ ឯកសារទាំងនេះ មិនមែនជាឯកសារច្បាប់នោះទេ ប៉ុន្តែវា ផ្តល់នូវការណែនាំផ្នែកបច្ចេកទេសស្តីពីការកំណត់ថាតើវត្ថុមួយ ទំនងជាកាកសំណល់ឬទេ។

ទាំងអស់នេះ គឺជាភស្តុតាងដ៏មានប្រយោជន៍ (ឬដោយខ្វះមិនបាន) ដើម្បីប្រមូលទុក នៅពេលបង្ហាញថាវត្ថុមួយដែលត្រូវគេដឹកជញ្ជូនគឺជាកាកសំណល់ ហើយមិនមែនជាទំនិញឧបករណ៍អគ្គីសនីមួយទឹកដែលនៅដំណើរការនោះទេ។

ក្រៅពីនិយមន័យនៃកាកសំណល់ នៅមាននិយមន័យពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងបទប្បញ្ញត្តិ WSR ដើម្បីធ្វើការពិចារណា (សូមមើលមាត្រា ២ នៃបទប្បញ្ញត្តិ WSR សម្រាប់បញ្ជីនៃនិយមន័យទាំងស្រុង) ។

ជាឧទាហរណ៍៖

- "**ការជួសជុលឡើងវិញ**" ឬ "**ការបោះចោល**" កាកសំណល់ ត្រូវបានកំណត់ដោយនិយមន័យនិងប្រភេទនៃសកម្មភាពនៅក្នុងសារាចរ WFD និងឧបសម្ព័ន្ធរបស់សារាចរនេះ។
- "**ការនាំចេញ**" មានន័យថាជាសកម្មភាពនៃកាកសំណល់ដែលចាកចេញពីសហភាពអឺរ៉ុប។
- "**ការដឹកជញ្ជូន** (transport)" មានន័យថាការដឹកជញ្ជូនកាកសំណល់តាមផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស ឬផ្លូវសមុទ្រ។
- "**ការដឹកជញ្ជូន**(shipment)" មានន័យថាការដឹកជញ្ជូនកាកសំណល់ដែលមានគោលបំណងធ្វើការជុសជុលឡើងវិញ ឬបោះចោល ដែលគេគ្រោងនឹងធ្វើឬកំពុងធ្វើដូច្នោះ
- "**ការដឹកជញ្ជូនដោយខុសច្បាប់**" មានការដឹកជញ្ជូនចំនួន ៧ ប្រភេទផ្សេងគ្នាដែលអាចសង្ខេបជា ៣ ប្រភេទសំខាន់ៗ។ ការពិពណ៌នាទាំងស្រុងនៃឯកសារទាំងនេះ អាចរកឃើញនៅក្នុងផ្នែកនៃទិដ្ឋភាពច្បាប់ ក្នុងជំពូកទី ១៖

ក្នុងករណីមានការហាមឃាត់ទាំងស្រុងចំពោះការនាំចេញកាកសំណល់ មិនថាសម្រាប់ការបោះចោលឬការជួសជុលឡើងវិញទេ ពីព្រោះកាកសំណល់នេះ ត្រូវបានគេហាមឃាត់ មានគ្រោះថ្នាក់ ជាកាកសំណល់តាមផ្ទះ ឬដោយសារវា ជាកាកសំណល់ដែលប្រទេសគោលដៅមិនចង់បាន។

ក្នុងករណីដែលកាកសំណល់ ត្រូវបាននាំចេញដោយគ្មានការជូនដំណឹងនិង/ឬមិនការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬក្នុងករណីដែលទទួលបានការយល់ព្រមតាមរយៈការក្លែងបន្លំ ឬការបង្ហាញព័ត៌មានមិនពិត ឬក្នុងករណីដែលមានបញ្ហាខ្វះខាតឯកសារនានានៅក្នុងឯកសារដឹកជញ្ជូនដែលភ្ជាប់មកជាមួយ។ និង

ក្នុងករណីដែលការជួសជុលឡើងវិញឬការបោះចោលកាកសំណល់ បណ្តាលឲ្យមានការរំលោភបំពានច្បាប់របស់សហភាពអឺរ៉ុបឬច្បាប់អន្តរជាតិ។

- “**អ្នកជូនដំណឹង**” គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់រដ្ឋជាសមាជិកដែលមានបំណងធ្វើការដឹកជញ្ជូន។ បន្ទាប់មកមានបញ្ជីតាមលំដាប់ឋានៈពីលើចុះក្រោម ដើម្បីកំណត់ថាអ្នកណាជាអ្នកជូនដំណឹង ដោយចាប់ផ្តើមដំបូងគេគឺអ្នកផលិតកាកសំណល់ដំបូងគេនិងរួមទាំងអ្នកប្រមូលកាកសំណល់ដែលបានប្រមែប្រមូលផ្តុំកាកសំណល់ចាប់ផ្តើមពីកន្លែងតែមួយពីអ្នកជួញដូរកាកសំណល់ដែលបានចុះបញ្ជី ឬឈ្មួញកណ្តាលដែលទទួលបានការអនុញ្ញាតឱ្យធ្វើការងារឲ្យអ្នកផលិតឬអ្នកប្រមូលទិញកាកសំណល់។ ក្នុងករណីដែលគេ មិនស្គាល់បុគ្គលទាំងនេះ ឬបុគ្គលទាំងនេះ បានក្ស័យធន អ្នកកាន់កាប់កាកសំណល់ ត្រូវបានគេចាត់ទុកថាជាអ្នកជូនដំណឹង (មាត្រា ២ (១៥) បទប្បញ្ញត្តិ WSR) ។ និង
- “**អ្នកកាន់កាប់កាកសំណល់**” មាននិយមន័យថាជាអ្នកផលិតកាកសំណល់ឬជារូបវន្តបុគ្គលឬនីតិបុគ្គលដែលជាម្ចាស់កម្មសិទ្ធិលើកាកសំណល់។

## តើមានការដឹកជញ្ជូនកាកសំណល់ខុសច្បាប់ឬទេ?

ដោយបានចែងថាវត្ថុឬសារធាតុមួយ ជាកាកសំណល់រួចហើយ នោះបទប្បញ្ញត្តិរបស់សារាចរWFDនិងបទប្បញ្ញត្តិ WSR ត្រូវបានគេយកមកអនុវត្ត។ បទប្បញ្ញត្តិ WSR អនុវត្តនូវវិធី “ភ្លើងចរាចរណ៍” ចំពោះការដឹកជញ្ជូនកាកសំណល់អាស្រ័យលើចំណាត់ថ្នាក់ ទិសដៅរបស់កាកសំណល់ និងថាតើកាកសំណល់នឹងត្រូវបានជួសជុលឬបោះចោលឬយ៉ាងណា៖ ភ្លើងបៃតងនិងលឿង គឺជាការគ្រប់គ្រងកាកសំណល់ក្រោមសេចក្តីសម្រេចរបស់អង្គការ OECD និងការហាមឃាត់ (ភ្លើងក្រហម) គឺជាការនាំចេញនៃកាកសំណល់គ្រោះថ្នាក់។ ជាឧទាហរណ៍៖

កាកសំណល់ដែលត្រូវបានចុះក្នុង “បញ្ជីភ្លើងបៃតង” ដូចជាកាកសំណល់ជាក្រដាសឬប្លាស្ទិក ដែលត្រូវបានផ្ញើទៅធ្វើការស្តារយកមកប្រើប្រាស់ឡើងវិញនៅក្នុងសហភាពអឺរ៉ុបនិងបណ្តាប្រទេសជាសមាជិករបស់អង្គការ

OECD តម្រូវឱ្យមានការយល់ព្រមពីអាជ្ញាធរជាជាងការគ្រប់គ្រងធម្មតាដែលធ្វើឡើងនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មទេ។ ការដឹកជញ្ជូននៃកាកសំណល់ដែលមានក្នុងបញ្ជីភ្លើងបៃតងសម្រាប់ការស្តារយកមកប្រើប្រាស់ឡើងវិញ ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវព័ត៌មានដែលមានចែងក្នុងមាត្រា ១៨ និងឯកសារដែលមាននៅក្នុង**ឧបសម្ព័ន្ធ** VII នៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់។ បណ្តាប្រទេសមិនមែនជាសមាជិករបស់ OECD អាចទទួលយកការត្រួតពិនិត្យបញ្ជីភ្លើងបៃតងសម្រាប់ប្រភេទកាកសំណល់ទាំងនេះ ប្រសិនបើគេ បានជូនដំណឹងដល់សហភាពអឺរ៉ុបអំពីរឿងនេះរួចហើយ។ ប្រសិនបើគេ មិនទាន់បានជូនដំណឹងទេ នោះគេ ត្រូវអនុវត្តនីតិវិធីដើម គឺត្រូវមានការជូនដំណឹងនិងមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរមានសមត្ថកិច្ចទាំងអស់នៃការបញ្ជូនកាកសំណល់នោះ[11] អាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសដែលកាកសំណល់ឆ្លងកាត់ និងអាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសគោលដៅចុងក្រោយ[12]

ការដឹកជញ្ជូនកាកសំណល់គ្រោះថ្នាក់និងការដឹកជញ្ជូនកាកសំណល់ដែលមានបំណងដើម្បីបោះចោលនៅក្នុងអឺរ៉ុបនិងOECD ជាទូទៅត្រូវមានសេចក្តីជូនដំណឹងនិងការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនដែលគេហៅថា **នីតិវិធីបង្ហាញការយល់ព្រមដោយបានជូនដំណឹងជាមុន (PIC)** ដូចមានចែងក្នុងជំពូក I និងជំពូក II នៃបទប្បញ្ញត្តិ WSR ។ និង

ការនាំចេញកាកសំណល់ដែលមានគ្រោះថ្នាក់ (និងកាកសំណល់តាមផ្ទះ) ទៅប្រទេសដែលមិនមែនជាសមាជិករបស់ OECD ត្រូវបាន**ហាមឃាត់** មិនថាក្នុងគោលបំណងដើម្បីបោះចោលក្តី ដូចដែលមានចែងក្នុងមាត្រា ៣៤ ឬសម្រាប់ជួសជុលយកមកប្រើឡើងវិញក្តី ដូចមានចែងក្នុងមាត្រា ៣៦។

មាត្រា៣៦ នៃបទប្បញ្ញត្តិWSR ចែងអំពីព័ត៌មានស្តីពីការនាំចេញកាកសំណល់ក្នុងគោលបំណងជួសជុល ទៅកាន់បណ្តាប្រទេសដែលមិនមែនជាសមាជិករបស់អង្គការ OECD។

## មាត្រា៣៦

## បំរាមចំពោះការនាំចេញកាកសំណល់

១. ការនាំចេញពីសហគមន៍នូវកាកសំណល់ខាងក្រោមដែលមានគោលបំណងដើម្បីស្តារឡើងយកទៅប្រើឡើងវិញនៅក្នុងប្រទេសដែលមិនបានទទួលការអនុវត្តដោយសេចក្តីសម្រេចរបស់ OECD ត្រូវបានហាមឃាត់៖

[11] ‘អាជ្ញាធរមានសមត្ថកិច្ចក្នុងការបញ្ជូនទំនិញ’ មានន័យថាជាអាជ្ញាធរនៅកន្លែងដែលគេចាប់ផ្តើមឬនឹងចាប់ផ្តើមធ្វើការដឹកជញ្ជូនទំនិញ (មាត្រា២(១៩) បទប្បញ្ញត្តិ WSR).

[12] បទប្បញ្ញត្តិរបស់គណៈកម្មការ (EC) លេខ ១៤១៨ ២០០៧ អនុម័តនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីអំពីការនាំចេញដើម្បីជួសជុលចំពោះកាកសំណល់មួយចំនួននៅក្នុងឧបសម្ព័ន្ធ III ឬ IIIA ដល់ បទប្បញ្ញត្តិ លេខ១០១៣/២០០៦ នៃសភាសហភាពអឺរ៉ុប និងនៃក្រុមប្រឹក្សារបស់ប្រទេសមួយចំនួនដែលសេចក្តីសម្រេចរបស់អង្គការ OECD ស្តីអំពីការចល័តកាកសំណល់ឆ្លងដែន បានរួមបញ្ចូល (OJ L ៣១៦/, ៤.១២.២០០៧)។

(a) កាកសំណល់ដែលត្រូវបានចុះបញ្ជីជាកាកសំណល់គ្រោះថ្នាក់នៅក្នុងឧបសម្ព័ន្ធ V ។

(b) កាកសំណល់ដែលចុះបញ្ជីក្នុងឧបសម្ព័ន្ធទី V ផ្នែកទី ៣ (កាកសំណល់ប្រមូលតាមផ្ទះ)

(c) កាកសំណល់គ្រោះថ្នាក់ដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ នៅក្រោមបញ្ជីតែមួយនៅក្នុងឧបសម្ព័ន្ធ V ។

(d) ល្បាយនៃកាកសំណល់គ្រោះថ្នាក់នានា និងល្បាយនៃកាកសំណល់គ្រោះថ្នាក់ជាមួយនឹងកាកសំណល់ដែលគ្មានគ្រោះថ្នាក់ មិនត្រូវបានធ្វើចំណាត់ថ្នាក់នៅក្នុងបញ្ជីតែមួយនៅក្នុងឧបសម្ព័ន្ធ V ។

(e) កាកសំណល់ដែលប្រទេសគោលដៅ បានជូនដំណឹងថាជាកាកសំណល់គ្រោះថ្នាក់ក្រោមមាត្រា៣នៃសន្និបាត Basel

(f) កាកសំណល់ដែលការនាំចូលរបស់វា ត្រូវបានគេហាមឃាត់ដោយប្រទេសគោលដៅ ឬ

(g) កាកសំណល់ដែលអាជ្ញាធរមានសមត្ថកិច្ចនៃការបញ្ជូនកាកសំណល់នោះ មានហេតុផលដែលជឿជាក់ថាកាកសំណល់នោះ នឹងមិនត្រូវបានគ្រប់គ្រងដោយមិនមានគ្រោះថ្នាក់ដល់បរិស្ថានក្នុងប្រទេសគោលដៅ ដូចដែលមានចែងក្នុងមាត្រា៤៩ ។

មាត្រា ៣៦ (១) នៃបទប្បញ្ញត្តិ WSR បានចុះបញ្ជីចំណាត់ថ្នាក់កាកសំណល់ចំនួន ៧ ប្រភេទដែលត្រូវបានហាមឃាត់មិនឱ្យនាំចេញពីសហគមន៍អឺរ៉ុបទៅប្រទេសមិនមែនជាសមាជិករបស់OECD។[13] កាកសំណល់ទាំងនេះ រួមបញ្ចូលទាំងកាកសំណល់គ្រោះថ្នាក់ និងល្បាយនៃកាកសំណល់គ្រោះថ្នាក់និងកាកសំណល់ផ្សេងៗទៀត កាកសំណល់តាមផ្ទះ កាកសំណល់ដែលត្រូវបានជូនដំណឹងដោយប្រទេសមិនមែនជាសមាជិករបស់ OECD ថាជាកាកសំណល់គ្រោះថ្នាក់ យោងតាមមាត្រា៣ នៃសន្និបាត Basel និងកាកសំណល់ដែលប្រទេសរបស់ខ្លួន បានហាមឃាត់មិនឱ្យនាំចូលមកក្នុងដែនយុត្តាធិការរបស់ខ្លួន។

ការដឹកជញ្ជូនកាកសំណល់ដែលរំលោភលើមាត្រា ៣៦ ស្ថិតក្នុងប្រភេទនៃការដឹកជញ្ជូនខុសច្បាប់ដែលកំណត់ដោយមាត្រា ២(៣៥) នៃបទប្បញ្ញត្តិ WSR ។

ដើម្បីបង្ហាញថាមានការរំលោភលើមាត្រា ៣៦ និងជាហេតុធ្វើឲ្យមានការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ដែលត្រូវបានសង្ស័យ គេ នឹងពិចារណានូវធាតុផ្សំនានាខាងក្រោម៖

តើវត្ថុធាតុនោះជាកាកសំណល់មែនឬទេ? ប្រសិនបើមែន សូមបន្តទៅចំណុចទី 2 ប្រសិនបើមិនមែន នោះបទប្បញ្ញត្តិ WSR (និងសារាចរWFD) មិនត្រូវយកមកអនុវត្តទេ ហើយមិនមានការរំលោភបំពានទេ។

[13] មាត្រា៣៤ ហាមប្រាមការនាំចេញនៃកាកសំណល់ ដើម្បីបោះចោល មានករណីលើកលែងដែលកម្រមួយចំនួន។

តើកាកសំណល់នោះស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទកាកសំណល់ទាំង៧ប្រភេទដែលមានចុះបញ្ជីក្នុងមាត្រា ៣៦ ដែរឬទេ? បើដូច្នេះមែន សូមបន្តទៅចំណុចទី៣ ។

តើមានការនាំចេញពីសហភាពអឺរ៉ុបស្របតាមនិយមន័យនៃការនាំចេញនិងដឹកជញ្ជូនកាកសំណល់ដែរឬទេ? បើមាន សូមបន្តទៅចំណុចទី៤ ។

តើកាកសំណល់ មានគោលបំណងដើម្បីជួសជុលយកទៅប្រើឡើងវិញមែនឬទេ? បើមែន សូមបន្តទៅចំណុចទី៥ ។

ហើយតើកាកសំណល់នោះ មានគោលបំណងដើម្បីជួសជុលយកទៅប្រើឡើងវិញនៅក្នុងប្រទេសដែលមិនមែនជាសមាជិករបស់ OECD មែនឬទេ?

ប្រសិនបើគេ អាចបង្ហាញនូវធាតុផ្សំទាំងអស់នេះ វា ទំនងជាមានការរំលោភបំពានតាមការចោទប្រកាន់ តាមមាត្រា៣៦ ហើយដូច្នេះនាំឲ្យមានការសង្ស័យថាមានការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់។ ដោយបានបង្ហាញថាមានការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់រួចហើយ នោះវា ពឹងផ្អែកលើច្បាប់ជាតិដើម្បីកំណត់ថាតើគេ បានប្រព្រឹត្តបទល្មើសមែនឬទេ ប្រសិនបើមែន តើអ្នកណាជាអ្នកប្រព្រឹត្តបទល្មើសនេះ តើត្រូវធ្វើការស៊ើបអង្កេតអ្វីខ្លះ និងថាតើត្រូវបន្តទៅដំណាលនៃការកាត់ទោសដែរឬទេ (សូមមើលជំពូកបន្ទាប់)។ នៅទីបំផុតតុលាការ នឹងកំណត់ថាតើវត្ថុនោះជាកាកសំណល់ឬមិនមែន ហើយការដឹកជញ្ជូនវត្ថុនោះខុសច្បាប់ឬទេ ដោយផ្អែកលើអង្គហេតុនិងភស្តុតាងនៃសំណុំរឿងជាក់លាក់នីមួយៗ។

ខណៈដែលមាត្រា ៣៦ ចែងអំពីបំរាមនៃការនាំចេញ ការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ជាច្រើនពីអឺរ៉ុបទៅកាន់ប្រទេសដែលមិនមែនជាសមាជិករបស់OECD ដែលត្រូវគេបានរកឃើញនៅក្នុងសហគមន៍អឺរ៉ុប ទាក់ទងទៅនឹងការរំលោភបំពាន**មាត្រា ៣៧** នៃបទប្បញ្ញត្តិWSR ។ ក្នុងករណីកាកសំណល់ដែលត្រូវបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ III ឬ IIIA និងការនាំចេញនៃកាកសំណល់ទាំងនោះដែលមិនត្រូវបានហាមឃាត់តាមមាត្រា ៣៦នោះទេ គណៈកម្មការនឹងផ្ញើសំណើជាលាយលក្ខណ៍អក្សរទៅកាន់ប្រទេសនីមួយៗដែលសេចក្ដីសម្រេចរបស់ OECD មិនត្រូវបានយកមកអនុវត្ត ក្នុងរយៈពេល២០ថ្ងៃចាប់ពីថ្ងៃចូលជាធរមាននៃបទប្បញ្ញត្តិនេះ ដោយទាមទារឲ្យមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរបញ្ជាក់ថាកាកសំណល់ អាចត្រូវបាននាំចេញពីសហគមន៍អឺរ៉ុបដើម្បីជួសជុលយកទៅប្រើឡើងនៅក្នុងប្រទេសនោះនិងទាមទារឲ្យមានការបង្ហាញថាតើគេ នឹងអនុវត្តនីតិវិធីត្រួតពិនិត្យណាមួយ(ប្រសិនបើមាន) នៅក្នុងប្រទេសគោលដៅ។

ប្រទេសនីមួយៗដែលមិនប៉ះពាល់ដោយសេចក្ដីសម្រេចរបស់OECDទេ នឹងទទួលបាននូវជម្រើសនានាដូចខាងក្រោម៖

ការហាមឃាត់

ឬ នីតិវិធីនៃការជូនដំណឹងនិងការយល់ព្រមជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងមាត្រា៣៥

មិនមានការគ្រប់គ្រងណាមួយ នៅក្នុងប្រទេសគោលដៅទេ។

ចម្លើយរបស់បណ្តាប្រទេសនានា ត្រូវបានចុះបញ្ជីនៅក្នុងបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប ១៤១៨/២០០៧ (EU Regulation 1418/2007)។ នៅពេលដែលប្រទេសណាមួយ មិនបានឆ្លើយតប គេ អាចនឹងបញ្ជូនកាកសំណល់នោះចេញក្នុងករណីដែលមានលិខិត PIC តែប៉ុណ្ណោះ។

## បទប្បញ្ញត្តិសម្រាប់ការកាត់ទោសនៅក្នុងសហភាពអឺរ៉ុប

មាត្រា ៣ នៃសារាចរ២០០៨/៩៩/EC មាត្រា៣៦ នៃសារាចរស្តីពីក្របខ័ណ្ឌកាកសំណល់ និងមាត្រា៥០ នៃបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនកាកសំណល់ ចែងថាការផ្តន្ទាទោសចំពោះបទល្មើសដែលបានលើកឡើងខាងលើ ត្រូវតែប្រកបដោយ "ប្រសិទ្ធភាព សមាមាត្រ និងបង្កឲ្យមានការខ្លាចអោ" ។ ទស្សនៈទាំងបីនេះ អនុញ្ញាតឱ្យផ្សាភ្ជាប់ភាពធ្ងន់ធ្ងរនៃការផ្តន្ទាទោសទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស ដូច្នេះទស្សនៈទាំងនេះ តែងតែត្រូវបានគេលើកឡើងនៅក្នុងតុលាការយុត្តិធម៌នៃច្បាប់យុត្តិសាស្ត្ររបស់សហភាពអឺរ៉ុប។ ខាងក្រោមនេះ គឺជាការចង្អុលបង្ហាញថាតើពាក្យគន្លឹះផ្សេងៗ មានន័យយ៉ាងដូចម្តេចនៅក្នុងបរិបទនេះ (ClientEarth, 2018) ៖

*ការផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាព ធានាថាគោលដៅបានចែងដោយអ្នកបង្កើតច្បាប់ ទទួលបានការសម្រេច ទោះបីមានការកែតម្រូវក៏ដោយ ហើយវា មានចេតនាដើម្បីទប់ស្កាត់គ្រោះថ្នាក់នាពេលអនាគតមិនអោយកើតឡើង។*

*ការផ្តន្ទាទោសធ្វើឲ្យមានការខ្លាចអោ គឺជាការផ្តន្ទាទោសមួយដែលបង្កឲ្យមានការខ្លាចអោពិតប្រាកដ ដោយសារតែភាពធ្ងន់ធ្ងរនិងហានិភ័យនៃការផ្តន្ទាទោសប្រភេទនេះចំពោះជនល្មើស ។ ការផ្តន្ទាទោស បង្កឲ្យមានការខ្លាចអោពិតប្រាកដ នៅពេលដែលការប្រើវិធានការគាបសង្កត់ដើម្បីបង្កើតសម្ពាធសមល្មមដើម្បីធានាថាស្ថានភាពដែលបានចែងនៅក្រោមច្បាប់របស់សហភាពអឺរ៉ុប ត្រូវបានគេទទួលស្គាល់នៅក្នុងការអនុវត្តជាក់ស្តែង ហើយនៅពេលដែលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច មិនមែនជាកត្តាជំរុញឲ្យមានការមិនអនុលោមតាមច្បាប់ ។*

*ការផ្តន្ទាទោសដែលសមាមាត្រ អនុញ្ញាតឲ្យសម្រេចបាននូវកម្មវត្ថុនានាដែលចែងដោយច្បាប់ និងដែលមិនលើសពីអ្វីដែលចាំបាច់ដើម្បីសម្រេចបាននូវកម្មវត្ថុទាំងនេះឡើយ។ លក្ខខណ្ឌទី ១ មានន័យថា មានបទដ្ឋានអប្បបរមាជាក់លាក់មួយដែលបានរៀបចំឡើងសម្រាប់ការការផ្តន្ទាទោសចំពោះការរំលោភបំពានលើច្បាប់របស់សហភាពអឺរ៉ុបដែលចាំបាច់គេត្រូវតែអនុវត្តតាម។* (ClientEarth, 2018)

ការកំណត់ថាតើការផ្តន្ទាទោសនោះ មានប្រសិទ្ធិភាព សមរម្យ និងបង្កឲ្យមានការខ្លាចរអាឬយ៉ាងណា ទាមទារឱ្យមានពិចារណាអំពីកាលៈទេសៈជាក់លាក់នៃអង្គហេតុនិងច្បាប់ជាតិពាក់ព័ន្ធដែលគេអាចនឹងយកមកអនុវត្ត។

រឿងនេះ ក៏ត្រូវបានពិពណ៌នាផងដែរនៅក្នុងកញ្ចប់ការងារនៃការបណ្តុះបណ្តាលស្តីពីការអនុវត្តផ្នែកព្រហ្មទណ្ឌនៃច្បាប់ស្តីអំពីកាកសំណល់របស់សហភាពអឺរ៉ុប( training package on EU Waste legislation ) សម្រាប់ចៅក្រម ដែលមានជាសំណុំនៃឧបករណ៍សម្រាប់ការបណ្តុះបណ្តាលដែលបានបង្កើតឡើងដោយសហគមន៍អឺរ៉ុបដើម្បីទ្រទ្រង់ដល់រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាលទាំងអស់ដែលមានចំណាប់អារម្មណ៍លើច្បាប់ស្តីពីកាកសំណល់របស់សហភាពអឺរ៉ុប។ នៅសហភាពអឺរ៉ុប ភាគច្រើននៃការអនុវត្តចំពោះបទឧក្រិដ្ឋទាក់ទងនឹងច្បាប់ស្តីពីកាកសំណល់ ត្រូវតែទាក់ទងនឹងការដឹកជញ្ជូនកាកសំណល់ឆ្លងដែននិងការចាក់ដីលុបកាកសំណល់ដោយខុសច្បាប់។ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចលើការដឹកជញ្ជូនកាកសំណល់និងអាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសគោលដៅ ជាធម្មតាមិនអនុញ្ញាឲ្យមានការដឹកជញ្ជូនបែបនោះទេ នោះការប៉ុនប៉ងណាមួយនៃការដឹកជញ្ជូនកាកសំណល់ សុទ្ធតែអាចធ្វើទៅបានដោយខុសច្បាប់។ ចៅក្រមព្រហ្មទណ្ឌ អាចនឹងកំណត់លក្ខណៈនៃដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់ ហើយសម្រេចថាតើការផ្តន្ទាទោសណាមួយ គួរតែត្រូវបានយកមកអនុវត្ត។ ខណៈពេលដែលមានការកំណត់នូវលក្ខខណ្ឌសមរម្យនានា តុលាការ អាចនឹងត្រូវគិតអំពីកម្រិតនៃផលប៉ះពាល់អវិជ្ជមាននៃការដឹកជញ្ជូនកាកសំណល់ដោយខុសច្បាប់មកលើសុខភាពមនុស្សនិងបរិស្ថាន (European Commission, 2019)។

## ឧបសម្ព័ន្ធ ៤ – ច្បាប់ស្តីពីកាកសំណល់ តាមបណ្តាប្រទេសក្នុងសហភាពអឺរ៉ុប និងអាស៊ីអាគ្នេយ៍

ទិដ្ឋភាពទូទៅនៃច្បាប់ជាតិទាក់ទងនឹងសារាចរ ២០០៨/៩៨/EC និងបទប្បញ្ញត្តិ ១០១៣/២០០៦/EC[14]

| ប្រទេស | ច្បាប់ |
|---|---|
| **អូទ្រីស** | ច្បាប់ស្តីពីការគ្រប់គ្រងកាកសំណល់ថ្នាក់សហព័ន្ធនៃអូទ្រីស ២០០២ អនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ |
| **បែលហ្សិក** | ក្រឹត្យ Flemish អនុម័តនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០១១ ពាក់ព័ន្ធនឹងការគ្រប់គ្រងវដ្តនៃវត្ថុធាតុ និងកាកសំណល់ ប្រកបដោយចីរភាព (ប្រកាសរដ្ឋបែលហ្សិក, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២); សេចក្តីសម្រេចនៃរដ្ឋាភិបាល Flemish អនុម័តនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ (ប្រកាសរដ្ឋបែលហ្សិក, ថ្ងៃទៅ២៣ ខែឧសភា ឆ្នាំ២០១២; Err ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២); ក្រិត្យ Walloon អនុម័តនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ (ប្រកាសរដ្ឋបែលហ្សិក, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២) និងដោយសេចក្តីសម្រេចរបស់រដ្ឋាភិបាល Walloon អនុម័តនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ (ប្រកាសរដ្ឋបែលហ្សិក, ថ្ងៃទី4 ខែមិថុនា ឆ្នាំ២០១២); បទបញ្ជាក្នុងតំបន់រដ្ឋធានីBrussels អនុម័តនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីអំពីកាកសំណល់ (ប្រកាសរដ្ឋបែលហ្សិក, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២); ច្បាប់អនុម័តនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨៤ ទាក់ទងនឹងការនាំចូល ការនាំចេញនិងការឆ្លងកាត់នៃកាកសំណល់ (តាមការកែតម្រូវ)។ |
| **ប៊ុលហ្គារី** | ច្បាប់ស្តីពីការគ្រប់គ្រងកាកសំណល់ ប្រកាសឲ្យប្រើជាផ្លូវការនូវ SG 53/ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១២ |
| **ក្រូអាត** | ច្បាប់ស្តីអំពីប្រកាសជាផ្លូវការអំពីការគ្រប់គ្រងកាកសំណល់ប្រកបដោយចីរភាព៩៤/១៣; ច្បាប់ស្តីពីកាកសំណល់ (ប្រកាសផ្លូវការ លេខ១៧៨/០៤, ១១១/០៦, ៦០/០៨, ៨៧/០៩; បទប្បញ្ញត្តិស្តីអំពីការគ្រប់គ្រងការដឹកកាកសំណល់ឆ្លងដែន (ប្រកាសផ្លូវការ ៦៩/២០០៦ តាមវិសោធនកម្ម)។ |
| **ស៊ីប (Cyprus)** | ច្បាប់ស្តីពីកាកសំណល់ លេខ 185 (I)/២០១១; ច្បាប់ស្តីអំពីកាកសំណល់រឹងនិងគ្រោះថ្នាក់ ២១៥ (I)/ ២០០២ និងបទប្បញ្ញត្តិដែលកើតចេញពីច្បាប់នេះ |

[14] ដោយផ្អែកលើ European Commission (2011), Assessment and guidance for the implementation of EU waste legislation in Member States, ENV.G.4/SER/2009/0027, https://ec.europa.eu/environment/waste/shipments/pdf/Annex%20VII.pdf; European Commission, Support to Implementation - Municipal Waste, https://ec.europa.eu/environment/waste/framework/support_implementation.htm; EEA (2018), Resource efficiency and waste, https://www.eea.europa.eu/themes/waste;

| | |
|---|---|
| **សាធារណរដ្ឋឆែក** | ច្បាប់ស្តីពីកាកសំណល់ លេខ ១៨៥/២០០១ វិសោធនកម្មចុងក្រោយ នៅខែ កុម្ភៈ ឆ្នាំ២០០៨ (លេខ ៣៤/២០០៨) |
| **អាឡឺម៉ង់** | ច្បាប់ស្តីអំពីការគ្រប់គ្រងកាកសំណល់ (KrWG) អនុម័តនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០១២; AbfVerbrG (ច្បាប់ស្តីពីការដឹកជញ្ជូនកាកសំណល់) អនុម័តនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ |
| **ដាណាម៉ាក** | Bekendtgørelse om overførsel af affald (BEK nr ៧៩៩ af ២៨/០៦/២០០៧) |
| **អេស្តូនី (Estonia)** | ច្បាប់ស្តីអំពីកាកសំណល់ អនុម័តនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៤ |
| **អេស្ប៉ាញ** | ច្បាប់ ១០/១៩៩៨ ស្តីអំពីកាកសំណល់ និងច្បាប់ ២៦/២០០៧ ស្តីអំពីទំនួលខុសត្រូវផ្នែកបរិស្ថាន |
| **ហ្វាំងឡង់** | ច្បាប់ស្តីអំពីកាកសំណល់នៃប្រទេសហ្វាំងឡង់ (១០៧២/៩៣, វិសោធនកម្មចុងក្រោយបង្អស់ ១៥៨៣/២០០៩); ក្រឹត្យស្តីអំពីកាកសំណល់ (១៣៩០/៩៣, វិសោធនកម្មចុងក្រោយបង្អស់ ១៨១៥/២០០៩); ច្បាប់ស្តីអំពីការការពារបរិស្ថាន (៨៦/២០០០) និងក្រឹត្យ (១៦៩/២០០០) |
| **បារាំង** | ច្បាប់ ២០១០-៧៨៨ អនុម័តនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ស្តីអំពីការប្តេជ្ញាចិត្តថ្នាក់ជាតិចំពោះបរិស្ថាន; បទបញ្ជា ២០១០-១៥៧៩ អនុម័តនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ចែងនូវបទប្បញ្ញត្តិផ្សេងៗដើម្បីសម្របតាមច្បាប់របស់សហភាពអឺរ៉ុបក្នុងវិស័យកាកសំណល់; ក្រឹត្យ ២០១១-៨២៨ អនុម័តនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ចែងអំពីបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងការទប់ស្កាត់និងការគ្រប់គ្រងកាកសំណល់; ក្រឹត្យ ២០១៦ -៨១១ អនុម័តនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៦ ទាក់ទងនឹងផែនការនៃការទប់ស្កាត់និងការគ្រប់គ្រងកាកសំណល់ថ្នាក់តំបន់; សារាចរ ២០០៧ សម្រាប់ការអនុវត្តបទប្បញ្ញត្តិ WSR; ក្រមស្តីអំពីបរិស្ថាន (មាត្រា L ៥៤១-៤៤ ff ; កែតម្រូវដោយបទបញ្ជាចាប់ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩) |
| **ក្រិច** | សេចក្តីសម្រេចរួមថ្នាក់រដ្ឋមន្ត្រី ១៣៥៨៨/៧២៥/២០០៦ (OJJ ៣៨៣ B) - ការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់; សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រី ៥០៩១០/២៧២៧/២០០៣ (OJJ ១៩០៩ B) - ការគ្រប់គ្រងកាកសំណល់ដែលមិនមានគ្រោះថ្នាក់ (ធ្វើបទប្បញ្ញត្តិចំពោះការប្រមូលនិងការដឹកជញ្ជូនកាកសំណល់ រួមមានការដឹកជញ្ជូនឆ្លងព្រំដែនផងដែរ) |
| **ហុ៊ងគ្រី** | ច្បាប់ CLXXXV/២០១២ ស្តីអំពី កាកសំណល់; ក្រឹត្យរបស់រដ្ឋាភិបាល លេខ ១៨០/២០០៧ (VII.៣.) ស្តីអំពីការដឹកជញ្ជូនកាកសំណល់ឆ្លងព្រំដែន (ចូលជាធរមាន៖ ១២.០៧.២០០៧) |
| **អៀរឡង់ (Ireland)** | យន្តការលក្ខន្តិកៈ លេខ ៤១៩ នៃបទប្បញ្ញត្តិគ្រប់គ្រងកាកសំណល់ឆ្នាំ២០០៧ (ការដឹកជញ្ជូនកាកសំណល់) |

| | |
|---|---|
| **អ៊ីតាលី** | ក្រិត្យជាតិស្តីអំពីការចាក់ដីកប់កាកសំណល់ (d.lgs. ៣៦/០៣) និងមានការកែតម្រូវនិងអន្តរកម្មជាបន្តបន្ទាប់។ លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកកាកសំណល់ បច្ចុប្បន្ននេះត្រូវបានផ្លាស់ប្តូរតាមរយៈ D.M. (ក្រិត្យរបស់ក្រសួង) ២៧/០៩/២០១០, ដែលបានលុបចោលនិងធ្វើបច្ចុប្បន្នភាពក្រិត្យពីមុនៗ (=LFD), បទប្បញ្ញត្តិ ២១៥០/២០០២/EC ត្រូវបានផ្លាស់ប្តូរទៅជាច្បាប់; ក្រិត្យរដ្ឋមន្ត្រី ៣៧០/១៩៩៨ ស្តីអំពីសារាចរអំពីការធានាផ្នែកហិរញ្ញវត្ថុ; ក្រិត្យច្បាប់ (decreto legislativo) ស្តីពីបទដ្ឋានបរិស្ថាន, n. ១៥២ពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៦ និងវិសោធនកម្មរបស់ក្រិត្យនេះ |
| Latvia | ច្បាប់ស្តីអំពីការគ្រប់គ្រងកាកសំណល់នៃប្រទេស Latvia អនុម័តនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ |
| Lithuania | ច្បាប់ស្តីអំពីការគ្រប់គ្រងកាកសំណល់ អនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៨, Nr. VIII-៧៨៧, តាមវិសោធនកម្ម |
| Luxembourg | ច្បាប់ អនុម័តនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ស្តីអំពីការគ្រប់គ្រងកាកសំណល់ និងវិសោនកម្ម ច្បាប់មួយនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ១៩៩៩ ស្តីអំពីការបង្កើតមូលនិធិសម្រាប់កាកការពារបរិស្ថាន។ 2 ច្បាប់ អនុម័តនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ ស្តីអំពីប្រតិបត្តិការនិងហិរញ្ញប្បទានដល់វិធានការ SuperDrecksKescht; បទប្បញ្ញត្តិ Grand-ducal អនុម័តនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងនឹងគុណភាពមួយចំនួននៃការអនុវត្តបទប្បញ្ញត្តិ (EC) ១០១៣/២០០៦; បទប្បញ្ញត្តិ Grand-ducal អនុម័តនៅថ្ងៃទី7 ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងនឹងលក្ខខណ្ឌផ្នែកនីតិវិធីនៃបទប្បញ្ញត្តិ WSR ថ្នាក់ជាតិ |
| Malta | បទប្បញ្ញត្តិស្តីអំពីការគ្រប់គ្រងកាកសំណល់(ការដឹកជញ្ជូនកាកសំណល់) (S.L.549.65) |
| **ហូឡង់** | ច្បាប់ស្តីអំពីការគ្រប់គ្រងបរិស្ថាន (Wet milieubeheer -. Wm); ច្បាប់ស្តីអំពីបទល្មើសសេដ្ឋកិច្ច ឆ្នាំ1950. |
| **ប៉ូឡូញ** | ច្បាប់អនុម័តនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០១ ស្តីអំពីកាកសំណល់ (ការបោះពុម្ពផ្សាយអំពីច្បាប់ ឆ្នាំ២០១០, លេខ ១៨៥, ចំណុច ១២៤៣, ជាមួយនឹងវិសោធនកម្មក្រោយៗ); ច្បាប់ អនុម័តនៅ ២៩.០៦.២០០៧ ស្តីអំពីការដឹកជញ្ជូនកាកសំណល់ (OJ ឆ្នាំ2007 លេខ ១២៤ ចំណុច៨៥៩) |
| **ព័រទុយហ្កាល់** | ក្រិត្យនៃប្រទេសព័រទុយហ្កាល់ ៧៣/២០១១ អនុម័តនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដោយធ្វើវិសោធនកម្មច្បាប់ក្រិត្យ ១៧៨/២០០៦ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៦ ដោយកំណត់អំពីគោលការណ៍បង្កើតទស្សនៈសម្រាប់ការគ្រប់គ្រងកាកសំណល់; ក្រិត្យ លេខ ៤៥/២០០៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨ |
| **រ៉ូម៉ានី** | ច្បាប់ ២១១/២០១១ ស្តីអំពីកាកសំណល់ ការផ្លាស់ប្តូរសារាចរស្តីពីក្របខណ្ឌកាកសំណល់ ២០០៨/៩៨/ECៈ សេចក្តីសម្រេចរបស់រដ្ឋាភិបាល ៧៨៨/២០០៧ ទាក់ទងនឹងការរៀបចំ |

| | |
|---|---|
| | មធ្យោបាយមួយចំនួន សម្រាប់ការអនុវត្តបទប្បញ្ញត្តិ WSR ដោយកែតម្រូវដោយសេចក្តីសម្រេចរបស់រដ្ឋាភិបាល ១៤៥៣/២០០៨ |
| **ស៊ុយអ៊ែត** | បទបញ្ជាស្តីអំពីកាកសំណល់នៃប្រទេសស៊ុយអ៊ែត (២០១១:៩២៧); បទបញ្ជានៃប្រទេសស៊ុយអ៊ែតស្តីអំពីការដឹកជញ្ជូនកាកសំណល់ឆ្លងព្រំដែន (SFS ២០០៧:៣៨៣); បទបញ្ជានៃប្រទេសស៊ុយអ៊ែត (១៩៩៨:៩០០) ស្តីអំពីអធិការកិច្ច និងការអនុវត្តច្បាប់ ដោយយោងតាមក្រមស្តីពីបរិស្ថាន |
| **ស្លូវ៉ានី** | ក្រិត្យស្តីអំពីកាកសំណល់ (ប្រកាសផ្លូវការនៃ RS, លេខ ៣៧/១៥) ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៥<br><br>ក្រិត្យស្តីអំពីការអនុវត្តបទប្បញ្ញត្តិ (EC) លេខ ១០១៣/២០០៦ ស្តីអំពីការដឹកជញ្ជូនកាកសំណល់ (OJ RS លេខ ៧១/២០០៧) |
| **ស្លូវ៉ាគី** | ច្បាប់លេខ ២២៣ /២០០១ Coll. ស្តីអំពីកាកសំណល់ និងស្តីអំពីវិសោធនកម្មនៃច្បាប់មួយចំនួនតាមវិសោធនកម្ម |
| **ចក្រភពអង់គ្លេស** | បទប្បញ្ញត្តិស្តីពីកាកសំណល់ (អង់គ្លេសនិង Wales) ឆ្នាំ២០១១ (S.I. ២០១១ លេខ៩៨៨); បទប្បញ្ញត្តិកាកសំណល់ (Northern Ireland) ឆ្នាំ២០១១ (SR ២០១១ លេខ១២៧); បទប្បញ្ញត្តិ (Scotland)[15] |

## ទិដ្ឋភាពទូទៅនៃច្បាប់ជាតិទាក់ទងនឹងកាកសំណល់និងការគ្រប់គ្រងកាកសំណល់នៅអាស៊ី

[15] សម្រាប់ព័ត៌មានបន្ថែម៖ https://www.isonomia.co.uk/wp-content/uploads/2018/09/UK-Waste-Framework-Directive-Implementation-Report-2016.pdf

| | |
|---|---|
| **អូស្ត្រាលី** | ច្បាប់ស្ដីអំពីកាកសំណល់គ្រោះថ្នាក់ (បទប្បញ្ញត្តិនៃការនាំចេញ និងការនាំចូលកាកសំណល់) ឆ្នាំ១៩៨៩ |
| **កម្ពុជា** | ច្បាប់ស្ដីអំពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦<br><br>អនុក្រិត្យលេខ៣៦ស្ដីអំពីការគ្រប់គ្រងកាកសំណល់រឹង<br><br>គោលការណ៍ណែនាំផ្នែកបរិស្ថាន ស្ដីអំពីការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ |
| **ចិន** | ច្បាប់ស្ដីអំពីការទប់ស្កាត់ និងការគ្រប់គ្រងការបំពុលបរិស្ថាន ដែលបណ្ដាលមកពីការសំណល់រឹង ឆ្នាំ២០០៤ |
| **ឥណ្ឌូនេស៊ី** | ច្បាប់ស្ដីអំពីការគ្រប់គ្រងនិងការការពារបរិស្ថាន ឆ្នាំ២០០៩<br><br>បទប្បញ្ញត្តិឥណ្ឌូនេស៊ីស្ដីអំពីការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់ និងសារធាតុពុល (លេខ ១០១ ឆ្នាំ 2014) |
| **ម៉ាឡេស៊ី** | ច្បាប់ស្ដីអំពីគុណភាពនៃបរិស្ថាន ឆ្នាំ១៩៧៤<br><br>ច្បាប់គយ ឆ្នាំ១៩៦៧ (ដូចនឹងឆ្នាំ២០១៦)<br><br>ច្បាប់ស្ដីអំពីការគ្រប់គ្រងកាកសំណល់និងការលាងសម្អាតសាធារណៈ ឆ្នាំ២០០៧<br><br>បទបញ្ជាគយ (បំរាមនៃការនាំចូល) |
| **មីយ៉ាន់ម៉ា** | ច្បាប់ស្ដីអំពីការការពារបរិស្ថាន ឆ្នាំ២០១២ |
| **ហ្វីលីពីន** | ច្បាប់ស្ដីអំពីការគ្រប់គ្រងកាកសំណល់នុយក្លេអ៊ែ កាកសំណល់គ្រោះថ្នាក់ និងសារធាតុពុល ឆ្នាំ១៩៩០ (ច្បាប់សាធារណរដ្ឋ លេខ៦៩៦៩)<br><br>ច្បាប់ស្ដីអំពីការគ្រប់គ្រងកាកសំណល់រឹងផ្នែកអេកូឡូស៊ី ឆ្នាំ២០០១<br><br>ការកែតម្រូវនីតិវិធីនិងបទដ្ឋាន សម្រាប់ការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់ ឆ្នាំ២០១៣ (កែតម្រូវ DAO ២០០៤-៣៦) DNER AO ២០១៣-២២ |
| **សិង្ហបុរី** | ច្បាប់ស្ដីអំពីកាកសំណល់គ្រោះថ្នាក់ (ការគ្រប់គ្រងការនាំចេញ ការនាំចូល និងការឆ្លងកាត់នៃកាកសំណល់) និងបទប្បញ្ញត្តិ ឆ្នាំ១៩៩៨ |

| | |
|---|---|
| ថៃ | ច្បាប់ស្តីអំពីសារធាតុគ្រោះថ្នាក់ ព.ស ២៥៣៥ (១៩៩២)<br>ការនាំចេញ និងការនាំចូលទំនិញ ព.ស ២៥២២ (១៩៧៩) |
| វៀតណាម | ច្បាប់ស្តីអំពីការគ្រប់គ្រងកាកសំណល់ និងសារធាតុពុលនិងគ្រោះថ្នាក់ ឆ្នាំ១៩៩៩<br>ច្បាប់ស្តីអំពីធនធានទឹក ឆ្នាំ១៩៩៨ |

## ឧបសម្ព័ន្ធ ៥ – ករណីសិក្សា

**ករណីសិក្សាទី១៖ ពិរុទ្ធភាពកាកសំណល់ដ៏ធំធេងនៃការនាំចេញកាកសំណល់ដែលគេហាមឃាត់**

ទីភ្នាក់ងារបរិស្ថាន បានចោទប្រកាន់ក្រុមហ៊ុន Biffa Waste Services Ltd ពីបទដឹកជញ្ជូនកាកសំណល់ទៅប្រទេសចិន។ កាកសំណល់នោះ ជាកាកសំណល់ដែលគេបានប្រមូលតាមផ្ទះសំបែងនានា ដែលមានដូចជាកញ្ចប់នំនិងម្ហូបអាហារ ដែលក្រុមហ៊ុនអះអាងថាជាកាកសំណល់ក្រដាស។ ការនាំចេញកាកសំណល់តាមផ្ទះសម្រាប់កែច្នៃដោយមិនបានបែងចែងប្រភេទនៃកាកសំណល់ដែលដឹកពីចក្រភពអង់គ្លេសទៅកាន់ប្រទេសចិន ត្រូវបានហាមឃាត់ចាប់តាំងពីឆ្នាំ២០០៦។

បន្ទាប់ពីធ្វើការជំនុំជម្រះក្តីនេះរយៈពេល ៣ សប្តាហ៍ គណៈវិនិច្ឆ័យនៅតុលាការ Wood Green Crown បានរកឃើញថាក្រុមហ៊ុន Biffa មានពិរុទ្ធពីបទរំលោភបំពានច្បាប់ចំនួន ២ នៅក្នុងខែឧសភានិងខែមិថុនាឆ្នាំ ២០១៥ ។ គេ អាចបញ្ជូនក្រដាសទៅសាធារណរដ្ឋប្រជាមានិតចិនបានដោយស្របច្បាប់ ប៉ុន្តែគេ មិនអាចបញ្ជូនកាកសំណល់កខ្វក់ខ្លាំងផ្សេងទៀតបានឡើយ។ គណៈវិនិច្ឆ័យ មិនទទួលយកការរៀបរាប់ព្រឹត្តិការណ៍របស់ក្រុមហ៊ុន Biffa ដែលអះអាងថាទំនិញកាកសំណល់នេះ បានចេញពីឃ្លាំងនៅEdmontonដោយស្របច្បាប់តាំងពីបួនឆ្នាំមុនមកម្ល៉េះ ព្រោះកាកសំណល់នោះគឺជាកាកសំណល់ក្រដាស នោះទេ។ ភស្តុតាងដែលប្រមូលបានដោយកអ្នកស៊ើបអង្កេតនៅឯកំពង់ផែ Felixstowe បានកំណត់យ៉ាងច្បាស់នូវវត្ថុដែលមានក្នុងទូរកុងតឺន័រមានទម្ងន់២៥តោនចំនួន៧កុងតឺន័រដែលត្រូវបានដឹកឆ្ពោះទៅប្រទេសចិន ក្នុងនោះរួមមានកញ្ចក់ ប្លាស្ទិក ឧបករណ៍អគ្គិសនី និងលោហៈ។ តាមពិត នៅពេលមន្ត្រីភ្នាក់ងារបរិស្ថានបានឆែកឆេរទំនិញ ពួកគេ បានរកឃើញវត្ថុនានាទាំងអស់ចាប់ពីខោទ្រនាប់ស្ត្រីនិងដបប្លាស្ទិក រហូតដល់បំពង់ដែកនិងសូម្បីតែថាស់ឌីសចម្រៀងជំនាន់ឆ្នាំ៩០របស់ក្រុម Deee-Lite ទំហំ១២អ៊ីញ។ ជំនួសឱ្យក្រដាសសំរាម អ្នកស៊ើបអង្កេត បានរកឃើញកម្ទេចកម្ទីផ្សេងៗដែលត្រូវបានគេបោះបង់ចោល ដូចជាស្បែកជើង កាបូបប្លាស្ទិច ឆ័ត្រ ស្រោមជើង កន្សែងដៃស្រោមអនាម័យដែលមិនទាន់ប្រើ កាសែតវីដេអូ ក្រដាសបង្គន់អនាម័យ និងខ្សែភ្លើង។ កន្ទបកូនង៉ែតនិងកន្សែងអនាម័យ បញ្ចេញនូវក្លិន«គួរឲ្យចង់ក្អួត»នៅពេលដែលមន្ត្រីភ្នាក់ងារបរិស្ថាន ធ្វើការត្រួតពិនិត្យ។ ក្រុមហ៊ុន Biffa ក៏បានព្យាយាមនាំចេញបន្ទះកម្រាលរនាប ស្មារាវងារ ធុងដាក់ចំណីសត្វចិញ្ចឹម ក្រដាសបង្គន់អនាម័យ ស្រោមដៃជ័រ ទៅប្រទេសចិនផងដែរ។

សមាជិកគណៈវិនិច្ឆ័យ បានលឺថា ក្រុមហ៊ុន Biffa បានប្រើក្រុមហ៊ុនចំនួនពីរ ឬប្រើឈ្មួញកណ្ដាល ដើម្បីធ្វើជាអន្តរការី ដើម្បីចាត់ចែងកិច្ចព្រមព្រៀងបញ្ជូនកាកសំណល់ទៅកន្លែងចែកចាយចំនួនពីរនៅទីក្រុងសិនជិននិងក្វាងដុងនៅឆ្នេរសមុទ្រចិនខាងត្បូង។ ឈ្មួញកណ្ដាលដំបូងគេ បានទទួលយកសំណើពីអតិថិជនចិនកាលពីខែមេសាឆ្នាំ ២០១៥ ដើម្បីរៀបចំការដឹកជញ្ជូនកាកសំណល់ជាក្រដាសចំរុះទម្ងន់ ៥.៨៦៣ តោន ដោយទាក់ទងទៅក្រុមហ៊ុន Biffa ។ គេ ធ្វើការព្រមព្រៀងនាំចេញក្នុងតម្លៃប្រហែល ៣៥០.០០០ ផោន ដែលនឹងធ្វើឡើងនៅខែបន្ទាប់។ ស្របពេលជាមួយគ្នានេះ ក្រុមហ៊ុន Biffa បានយល់ព្រមជាមួយឈ្មួញកណ្ដាលទីពីរក្នុងការបញ្ជូនកាកសំណល់ក្រដាសចម្រុះទម្ងន់៤.៩៩២តោន នៅក្នុងកិច្ចសន្យាមួយដែលមានតម្លៃជិត ២៩០,០០០ ផោន។ ទីភ្នាក់ងារបរិស្ថាន បានរាំងទូរកុងតឺន័រណាមួយក្នុងចំណោមកុងតឺន័រទាំងប្រាំពីរមិនឲ្យចាកចេញពី Felixstowe ឡើយ។

ក្រុមហ៊ុន Biffa បានសារភាពទទួលពិរុទ្ធភាពនៅសវនាការដំបូង ចំពោះបទចំនួន ២ នៃការរំលោភបំពានលើបទប្បញ្ញត្តិ ២៣នៃបទប្បញ្ញត្តិឆ្នាំ ២០០៧ស្ដីអំពីការដឹកជញ្ជូនកាកសំណល់ឆ្លងព្រំដែន។ ក្រោមបទប្បញ្ញត្តិនានា វា គឺជាបទល្មើសដែលរំលោភបំពានមាត្រា ៣៦ នៃបទប្បញ្ញត្តិ ១០១៣/២០០៦ស្ដីអំពីការដឹកជញ្ជូនកាកសំណល់របស់សហភាពអឺរ៉ុបដែលបានហាមឃាត់នូវការនាំចេញកាកសំណល់ដែលប្រមូលបានពីតាមផ្ទះសំបែងដែលគេដឹកទៅប្រទេសចិន។ លោកចៅក្រម Simon Auerbach បានពន្យាពេលការប្រកាសសាលក្រមរហូតដល់ថ្ងៃទី ២៧ ខែកញ្ញា។ មានគេប្រាប់តុលាការថាទីភ្នាក់ងារបរិស្ថាននិងក្រុមហ៊ុន Biffa បានយល់ព្រមបង់ប្រាក់ចំនួន ៩,៩១២ ផោន ដែលជាផលនៃឧក្រិដ្ឋកម្ម។

ប្រភព៖ UK Environment Agency, Waste giant guilty of exporting banned waste, Press release, 24 June 2019.

**ករណីសិក្សាទី២៖ ការនាំចេញកាកសំណល់ពីប្រទេសបារាំងដោយខុសច្បាប់**

ក្នុងឆ្នាំ ២០១២ ប្រធានគ្រប់គ្រងពីររូបនៃក្រុមហ៊ុនកែច្នៃរបស់បារាំង ត្រូវបានផ្ដន្ទាទោសអោយជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ ត្រូវបានផាកពិន័យ ៦០០០€ និង€៣០០០, ត្រូវបានដកសិទ្ធិជាអចិន្ត្រៃយ៍ពីការធ្វើជានាយកក្រុមហ៊ុនពាណិជ្ជកម្ម ឬសិប្បករបែបនេះ និងតែត្រូវសម្អាតទីតាំងនោះ។ ពួកគេ ក៏ត្រូវបានបញ្ជាឱ្យបង់ប្រាក់សំណងចំនួន ១០,០០០€ ដល់សមាគមបារាំងដែលបានដាក់ពាក្យបណ្ដឹងផងដែរ។

ក្រុមហ៊ុនដែលមានឯកទេសក្នុងការដឹកជញ្ជូន រុះរើ ចាត់ចែង ជួសជុល និងបំបែកកាកសំណល់អេឡិចត្រូនិចនេះ បានបង្កើនបរិមាណកាកសំណល់ដែលផ្ទុកនៅលើទីតាំងរបស់ខ្លួន ហើយបន្ទាប់មកផ្ទេរសកម្មភាពរបស់ខ្លួនដោយមិនប្រកាសប្រាប់ដំណឹងដូចដែលមានចែងក្នុងកាតព្វកិច្ចរបស់ខ្លួន។

ក្រុមហ៊ុននេះ បានកំពុងនាំចេញកាកសំណល់អេឡិចត្រូនិចទៅក្រៅប្រទេស (ប៊ែលហ្ស៊ិក ទួរគី អារ៉ាប់រួម វៀតណាម ហុងកុងតំបន់រដ្ឋបាលពិសេសរបស់ចិន) ដោយមិនបានអនុវត្តតាមសេចក្ដីប្រកាសនិងតាមបែបបទផ្លូវការផ្នែករដ្ឋបាលជាច្រើនដែលចែងដោយបទប្បញ្ញត្តិនានាស្ដីពីការដឹកជញ្ជូនកាកសំណល់ឆ្លងព្រំដែន។ យោងទៅតាមចុងចោទ វាមិនមែនជាកាកសំណល់ទេ ប៉ុន្តែវា ជា "ផលិតផលមួយទឹក" ដែលពួកគេបានធ្វើការជួសជុលឬយកទៅប្រើប្រាស់ឡើងវិញ។ តាមពិត គេ រកឃើញកាកសំណល់ទាំងនោះចេញពីរដ្ឋបាលជាច្រើនដែលក្រុមហ៊ុនបានយកមកបំបែក និងបញ្ជូនទៅអោយអ្នកលក់អេតចាយនៅក្រៅប្រទេស ។

ប្រភព៖ France Nature Environnement, Communiqué de presse ( press release ), 2012

**ករណីសិក្សាទី៣៖ ឧក្រិដ្ឋជនកាកសំណល់ត្រូវបានកាត់ទោសជាប់ពន្ធនាគារសរុបចំនួន១៦ឆ្នាំ**

ឧក្រិដ្ឋកម្មកាកសំណល់ បានបោកប្រាស់ឧស្សាហកម្មកែច្នៃកាកសំណល់អគ្គិសនីចំនួន ២,២ លានផោនក្នុងឆ្នាំ ២០១៦ ។ ឧក្រិដ្ឋជន បានក្លែងបន្លំឯកសារ ដើម្បីអះអាងដោយខុសច្បាប់ថាក្រុមហ៊ុនរបស់ខ្លួន បានប្រមូលនិងកែច្នៃកាកសំណល់អគ្គិសនីតាមផ្ទះចំនួន១៩.៥០០តោនក្នុងឆ្នាំ២០១១។ តាមការពិត គេ មិនដែលបានចាត់ចែងចំពោះកាកសំណល់ទាំងនេះឡើយ ស្របពេលដែលខ្លួន បានទទួលបានប្រាក់ពីគ្រោងការណ៍អនុលោមតាមច្បាប់របស់អ្នកផលិត។ ឧក្រិដ្ឋជននេះ ក៏ធ្លាប់ត្រូវបានផ្តន្ទាទោសពីមុនពីបទក្លែងបន្លំនិងនាំចេញកាកសំណល់គ្រោះថ្នាក់ដែលគេបានហាមឃាត់ដោយខុសច្បាប់ទៅប្រទេសនីហ្សេរីយ៉ា។

គាត់ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៧ ឆ្នាំ ៦ ខែ។ ដំបូង បុរសនេះ ត្រូវបានបញ្ជាឱ្យសងប្រាក់ជាង ១,៣ លានផោន នៃទឹកប្រាក់សរុប២,២ លានផោនដែលគាត់បានទទួលបានតាមរយៈសកម្មភាពខុសច្បាប់ដែលបន្ថែមពីលើទឹកប្រាក់ជាង ៧៩.០០០ ផោនពីការកាត់ទោសដោយទីភ្នាក់ងារបរិស្ថានពីមុនពីបទនាំចេញកាកសំណល់គ្រោះថ្នាក់ទៅប្រទេសនីហ្សេរីយ៉ាក្នុងឆ្នាំ ២០១១ និងទឹកប្រាក់ជាង ១៧.០០០ ផោនពីបទក្លែងបន្លំពន្ធលើតម្លៃបន្ថែម( VAT )នៅឆ្នាំ ២០១៥ ។

ទោះបីជាមានការបញ្ជាពីតុលាការក៏ដោយ គាត់ ក៏នៅតែមិនបង់ប្រាក់ទាំងនេះឡើយ។

**ការកាត់ទោស៖** ដោយសារមិនមានសង្ឃឹមជាក់ស្តែងថាគាត់ នឹងបង់ប្រាក់ដ៏ច្រើននោះ គេ បានដាក់ទោសគាត់ឲ្យជាប់ក្នុងពន្ធនាគាររយៈពេល ៨ ឆ្នាំបន្ថែមទៀត ពីបទមិនបានបង់ប្រាក់តាមបទបញ្ជាចំនួន ១,៣ លានផោន និងទោស ១៦ ខែក្នុងពន្ធនាគារ សម្រាប់បទបញ្ជាផ្សេងៗទៀត។ បន្ថែមសរុបគាត់ ទទួលទោសជាប់ពន្ធនាការចំនួន១៦ ឆ្នាំ ។

ប្រភព៖ https://www.gov.uk/government/news/convicted-waste-fraudster-has-more-than-9-years-added-to-jail-time-for-failing-to-repay-1-3-million-in-ill-gotten-gains

## ឧបសម្ព័ន្ធ ៦ – ការធ្វើសំណាកគំរូ និងវិភាគសំណាកគំរូ

ជាតុផ្សំនៃការគោលការណ៍ណែនាំ សម្រាប់ការត្រួតពិនិត្យរក ការទប់ស្កាត់ និងការគ្រប់គ្រងចរាចរណ៍កាកសំណល់គ្រោះថ្នាក់ ដោយខុសច្បាប់ ( កិច្ចប្រជុំCOP Basel លើកទី6 )

ការធ្វើសំណាកគំរូ និងការវិភាគសំណាកគំរូ

A. គុណភាពនៃការស៊ើបអង្កេត

១. វា មានសារៈសំខាន់ណាស់ដែលមន្ត្រីស៊ើបអង្កេត ត្រូវដឹងអំពីនីតិវិធីធ្វើសំណាកគំរូនិងការវិភាគសំណាកគំរូ មុនពេលបន្តការស៊ើបអង្កេត។ ការប្រមូលភស្តុតាងមិនត្រឹមត្រូវ អាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពនៃការកាត់ទោសប្រកបដោយជោគជ័យ។ ដូច្នេះ មន្ត្រីស៊ើបអង្កេត គប្បីទទួលបានការបណ្តុះបណ្តាលក្នុងការកំណត់នីតិវិធីនៃខ្សែសង្វាក់នៃការរក្សាទុកសំណាកគំរូ និងនីតិវិធីសន្តិសុខដែលក្រុមធ្វើសំណាកគំរូនិងមន្ទីរពិសោធន៍ ចង់ធ្វើ។

២. ទីភ្នាក់ងាររដ្ឋាភិបាលដែលមានបទពិសោធន៍ក្នុងការដោះស្រាយចំពោះឧក្រិដ្ឋកម្មបរិស្ថានជាប្រចាំ នឹងមានមូលដ្ឋានគ្រឹះនិងជំនាញពាក់ព័ន្ធដើម្បីអនុវត្តការស៊ើបអង្កេតប្រកបដោយបទដ្ឋានខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមន្ត្រីមូលដ្ឋានមិនសូវមានបទពិសោធន៍ កំពុងយកសំណាកគំរូ អ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេត នឹងត្រូវការធានាថានីតិវិធីនៃខ្សែសង្វាក់នៃរក្សាទុកសំណាកគំរូ ត្រូវបានអនុវត្តបានយ៉ាងត្រឹមត្រូវ។

B. គុណភាពនៃការវិភាគ

៣. ដូចគ្នានេះដែរ គេ មិនអាចសន្មត់បានទេថាមន្ទីរពិសោធន៍ នឹងមិនចាំបាច់អនុវត្តតាមនីតិវិធីសមស្របណាមួយនៅពេលដែលគេ យកសំណាកគំរូ។ នេះ ជាការពិត ជាពិសេសសម្រាប់មន្ទីរពិសោធន៍ឬបុគ្គលិកដែលមិនមានបទពិសោធន៍ក្នុងការប្រមូលនិងវិភាគសំណាកគំរូសម្រាប់ប្រើក្នុងនីតិវិធីព្រហ្មទណ្ឌ។ ហេតុដូច្នេះ វា ជារឿងចាំបាច់ណាស់ដែលគេ ត្រូវការធ្វើការជាមួយមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ឬមានអាជ្ញាបណ្ណដែលស្គាល់ច្បាស់អំពីនីតិវិធីពាក់ព័ន្ធនានា។

C. នីតិវិធីនៃការធ្វើសំណាកគំរូ

៤. គេ អាចចោទជាសំណួរមួយចំនួនដើម្បីធានាឲ្យបាននូវការចាត់ចែងសំណាកគំរូឲ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

(a) តើទម្រង់បែបបទនៃខ្សែសង្វាក់នៃការរក្សាសំណាកគំរូ ត្រូវបានគេភ្ជាប់ជាមួយសំណាកគំរូចាប់តាំងពីពេលដែលគេបានគេយកសំណាកគំរូ រហូតដល់ពេលដែលគេបានបញ្ជូនសំណាកគំរូទៅមន្ទីរពិសោធន៍ដើម្បីធ្វើការវិភាគ ឬទេ?

(b) ប្រសិនបើការយកសំណាកគំរូមានរយៈពេលលើសពីមួយថ្ងៃ ឬប្រសិនបើ គេ តម្រូវឲ្យរក្សាទុកសំណាកគំរូមុនពេលបញ្ជូនទៅមន្ទីរពិសោធន៍ អ្នកស៊ើបអង្កេត គប្បីកំណត់ថាតើគេនឹងយកសំណាកគំរូអ្វីទៅប្រើប្រាស់ដើម្បីអ្វី ហើយគេ ត្រូវមាននីតិវិធីរក្សាសន្តិសុខអ្វីខ្លះ ដើម្បីការពារសំណាកគំរូដែលមាន។ នីតិវិធីនានា គប្បីធានានូវសន្តិសុខក្នុងការរក្សាទុកសំណាកគំរូទាំងអស់រយៈពេលមួយយប់ ដែលគេ នឹងប្រើសំណាកគំរូទាំងនោះធ្វើជាភស្តុតាងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ។ តួយ៉ាង ប្រសិនបើគេ តម្រូវឲ្យរក្សាសំណាកគំរូទុកនៅក្នុងយានយន្តដែលចាក់សោរ ដូច្នេះ យានយន្តនេះ គប្បីត្រូវបានរក្សាទុកនៅក្នុងការ៉ាសដែលមានសន្តិសុខត្រឹមត្រូវ។ ប្រសិនបើគេធ្វើសំណាកគំរូ ដើម្បីកំណត់តម្លៃចំណាយសម្រាប់ការសម្អាតបរិស្ថានសម្រាប់សំណុំរឿងរដ្ឋប្បវេណី នោះ ការរក្សា

ទុកសំណាកគំរូ មិនចាំបាច់ត្រូវតែមានសន្តិសុខនោះទេ។ គេ ក៏គួរតែកំណត់ថាតើមានលក្ខខណ្ឌក្នុងការរក្សាទុក ឬវេចខ្ចប់សំណាកគំរូដែលទាក់ទងនឹងវត្ថុធាតុនៃសំណាកគំរូនោះ ហើយគប្បីត្រួតពិនិត្យមើលថាតើសំណាកគំរូនឹងត្រូវបានវេចខ្ចប់យ៉ាងដូចម្តេច។ ជាឧទាហរណ៍គេ គប្បីរក្សាទុកសំណាកគំរូនៅកន្លែងដែលមានសីតុណ្ហភាពណាមួយជាក់លាក់ នៅកន្លែងងងឹតនិង/ឬឆ្ងាយពីសំណើម រហូតដល់គេត្រូវធ្វើការវិភាគ ដើម្បីធានានូវការជឿទុកលើសំណាកគំរូនោះ។ ត្រូវធានាថា គេ បានបំពេញរាល់លក្ខខណ្ឌទាំងអស់នៃការវេចខ្ចប់និងរក្សាទុកសំណាកគំរូ។

(c) តើមានបានបង្កើតនីតិវិធីនៃខ្សែសង្វាក់នៃការរក្សាទុកសំណាកគំរូឬកំណត់ត្រាផ្សេងៗទៀត នៅពេលមន្ទីរពិសោធន៍ទទួលបានសំណាកគំរូ ដែរឬទេ?

(d) តើមន្ទីរពិសោធន៍រក្សាទុកសំណាកគំរូមុនពេលវិភាគសំណាកគំរូយ៉ាងដូចម្តេច?

(e) តើសំណាកគំរូ នឹងត្រូវបានចាត់ចែងដោយបុគ្គលិកច្រើននាក់ក្នុងកំឡុងពេលកំពុងធ្វើការវិភាគ ដែរឬទេ? បើដូច្នេះ តើកំណត់ត្រាអ្វីខ្លះដែលគេត្រូវរក្សាទុកដើម្បីតាមដានសំណាកគំរូនិងនីតិវិធីសំណាកគំរូ?

(f) តើត្រូវធ្វើអ្វីខ្លះចំពោះសំណាកគំរូបន្ទាប់ពីវិភាគរួចហើយ? តើមន្ទីរពិសោធន៍រក្សាទុកសំណាកគំរូដែរឬទេ? បើដូច្នេះមែន តើសំណាកគំរូត្រូវបានរក្សាទុកយូរប៉ុណ្ណា ហើយតើសំណាកគំរូមានសន្តិសុខ ដែរឬទេ?

<u>៥. D. សមត្ថភាពរបស់មន្ទីរពិសោធន៍</u>

(a) តើ គេមានវិធីសាស្ត្រធ្វើតេស្តដែលគេអនុញ្ញាតឲ្យប្រើ ដើម្បីវិភាគសំណាកគំរូដែរឬទេ ហើយតើគេ បានប្រើវិធីសាស្ត្រត្រឹមត្រូវ តាមកាលៈទេសៈជាក់លាក់ ដែរឬទេ?

(b) តើគេ បានអនុវត្តនូវនីតិវិធីនៃការធានាគុណភាព/ការគ្រប់គ្រងគុណភាពសមស្រប យ៉ាងតឹងរ៉ឹងដែរឬទេ?

(c) តើមន្ទីរពិសោធន៍ មានកំណត់ត្រាតាមដានក្នុងការផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់សម្រាប់ការស៊ើបអង្កេតបទឧក្រិដ្ឋ ដែរឬទេ? បទពិសោធន៍និងកេរ្តិ៍ឈ្មោះរបស់មន្ទីរពិសោធន៍ដែលធ្វើការវិភាគសំណាកគំរូនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើគុណភាពនៃការវិភាគសំណាកគំរូ។ វិញ្ញាបនប័ត្រឬការទទួលស្គាល់មន្ទីរពិសោធន៍ គួរតែជាតម្រូវការអប្បបរមាសម្រាប់គ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតបទឧក្រិដ្ឋ។ នៅទីបញ្ចប់ គេ គប្បីពិចារណាចំពោះការបង្កើតបណ្តាញនៃមន្ទីរពិសោធន៍ក្នុងតំបន់ដែលមានការទទួលស្គាល់ដែលអាចត្រូវបានប្រើសម្រាប់គោលបំណងនេះ។

(d) តើមន្ទីរពិសោធន៍យល់ពីគោលបំណងនៃការស៊ើបអង្កេត ដែរឬទេ?

<u>E. សមត្ថភាពរបស់មន្ត្រីអធិការកិច្ច</u>

6. គេ ប្រហែលជាចោទសួរនូវសំណួរមួយចំនួន ដើម្បីធានានូវសមត្ថភាពរបស់មន្ទីរពិសោធន៍ ដូចខាងក្រោម៖

(a) តើអ្នកស៊ើបអង្កេតយល់អំពីនីតិវិធីនៃការវិភាគសំណាកគំរូដ៏ត្រឹមត្រូវដែលគេត្រូវអនុវត្តតាមដែរឬទេ ហើយតើគេ ត្រូវការព័ត៌មានអ្វីខ្លះ? ដូចគ្នានឹងការយកសំណាកគំរូដែរ វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ជូនបុគ្គលិកផ្នែកវិទ្យាសាស្ត្រនូវសារៈតារពាក់ព័ន្ធរបស់សំណុំរឿងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន មុនពេលធ្វើការវិភាគសំណាកគំរូ ដើម្បីបង្កើនភាពប្រាកដប្រជានៃលទ្ធផល។

(b) តើអ្នកស៊ើបអង្កេតអាចបកស្រាយលទ្ធផល បានត្រឹមត្រូវដែរឬទេ? បើមិនដូច្នោះទេ តើគាត់ មានបានបញ្ជាក់ផ្នែកណាមួយនៃការភាន់ច្រលំដែរឬទេ? វា មានសារៈសំខាន់ណាស់ក្នុងការទទួលបានការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលទ្ធផលនៃការវិភាគ នៅក្នុងករណីដែលអាចមានការភ័ន្តច្រឡំឬកង្វះការយល់ដឹងណាមួយ។

(c) អ្នកស៊ើបអង្កេត បានស្នើសុំឱ្យមន្ទីរពិសោធន៍រក្សាសំណាកគំរូសម្រាប់រយៈពេលចាំបាច់នៃពេលវេលាណាមួយ ដែរឬទេ?

F. ការចាត់ចែងភស្តុតាងជាវីដេអូ និងរូបភាព

7. តាមវិធានទូទៅ ភស្តុតាងជារូបភាពឬវីដេអូ មិនត្រូវបានណែនាំសម្រាប់នីតិវិធីនៃការវិភាគនិងការធ្វើសំណាកគំរូទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគេ ត្រូវការភស្តុតាងជារូបថតឬវីដេអូ គេ គប្បីត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

(a) មិនគប្បីថតរូបឬវីដេអូរបស់បុគ្គលិកដែលធ្វើសំណាកគំរូឬវិភាគសំណាកគំរូទេ។

(b) គេ គប្បីថតរូបឬវដេអូរបស់តំបន់នៃសំណាកគំរូនិងប្រអប់ដាក់សំណាកគំរូ មុននិងក្រោយពេលយកសំណាកគំរូ ដើម្បីធ្វើជាកំណត់ត្រាដែលបញ្ជាក់ថាគេ បានអនុវត្តនូវនីតិវិធីបានយ៉ាងត្រឹមត្រូវត្រូវ។

(c) ប្រសិនបើ គេ ថតវីដេអូនៃនីតិវិធីនៃការធ្វើសំណាកគំរូនិងការវិភាគសំណាកគំរូ គេ គប្បីប្រើកាសែតវីដេអូថ្មីបិទសំឡេង ហើយកាសែតច្បាប់ដើមនោះ គួរតែត្រូវបានរក្សាទុកដោយអ្នកស៊ើបអង្កេតដែលទទួលបន្ទុក។

(d) ប្រសិនបើ គេថតរូបថតនីតិវិធីនៃការធ្វើសំណាកគំរូនិងការវិភាគសំណាកគំរូ គេ គប្បីរក្សាទុកកំណត់ត្រានៃភស្តុតាងជារូបថតទាំងអស់ ដែលក្នុងនោះរួមមានលេខលំដាប់រូបថត ការពិពណ៌នាអំពីរូបថត និងពេលវេលានិងកាលបរិច្ឆេទនៃការថតរូប។ ដូចគ្នានឹងភស្តុតាងជាវីដេអូ ដុំហ្វីល គួរតែត្រូវបានរក្សាទុកដោយអ្នកស៊ើបអង្កេតដែលទទួលបន្ទុក។

(e) ប្រសិនបើក្រុមហ៊ុនដែលស្ថិតក្រោមការស៊ើបអង្កេត ស្នើសុំសិទ្ធិក្នុងការថតរូបឬថតវីដេអូនៃនីតិវិធីយកសំណាកគំរូនិងវិភាគសំណាកគំរូ គេ មិនគួរអនុញ្ញាតឡើយ ប្រសិនបើមានហានិភ័យធ្វើឲ្យប៉ះពាល់ដល់ការធ្វើសំណាកគំរូដែលគេកំពុងធ្វើ។

G. ការចាត់ចែងចំពោះឯកសារច្បាប់ដើម

8. គេ គប្បីជូនដំណឹងដល់ក្រុមធ្វើសំណាកគំរូនិងបុគ្គលិកផ្នែកបច្ចេកទេសដទៃទៀតដែលចូលរួមក្នុងការស៊ើបអង្កេត ថារាល់ឯកសារច្បាប់ដើមទាំងអស់ ត្រូវរក្សាទុកក្នុងទីតាំងមានសុវត្ថិភាពរហូតដល់អ្នកស៊ើបអង្កេត ជូនដំណឹងដល់ពួកគេថាគេ លែងត្រូវការឯកសារទាំងនោះទៀត។ ឯកសារទាំងនេះ រួមមានទម្រង់បែបបទនៃខ្សែសង្វាក់រក្សាទុកសំណាកគំរូ កំណត់ត្រានៅទីតាំងផ្ទាល់ និងរបាយការណ៍នានា។

9. ដូចគ្នានេះដែរ គេ គប្បីស្នើមន្ទីរពិសោធន៍ដែលទទួលខុសត្រូវក្នុងការវិភាគសំណាកគំរូឱ្យរក្សាឯកសារច្បាប់ដើមទាំងអស់ដែលទាក់ទងនឹងការវិភាគសំណាកគំរូ រហូតដល់មានការជូនដំណឹងណាមួយផ្សេងទៀត។ ឯកសារទាំងនេះ រួមមានកំណត់ត្រាមន្ទីរពិសោធន៍ ក្រូម៉ាតូក្រាម(chromatogram)និងរបាយការណ៍ចុងក្រោយនានា។

H. ការងារនៅក្នុងមន្ទីរពិសោធន៍

10. ការងារនៅក្នុងមន្ទីរពិសោធន៍ រួមមានប្រតិបត្តិការដូចខាងក្រោម៖

(a) ការងារមុនធ្វើសំណាកគំរូ៖ ភាពដូចគ្នា ការធ្វើសំណាកគំរូរង ការទាញយកសំណាកគំរូ ការសម្អាត ការបន្សុទ្ធ វិទ្យុសកម្ម ។ល។

(b) ការបំបែកសមាសធាតុគីមី លក្ខណៈគីមីវិទ្យា និងលក្ខណៈគីមីរូបវិទ្យា។

(c) វិធានការសម្រាប់សមាសធាតុគីមី៖ ការត្រួតពិនិត្យរក ការកំណត់អត្តសញ្ញាណ ការកំណត់បរិមាណសមាសធាតុគីមី។

I. លទ្ធផល និងទិន្នន័យ

11. ភាពប្រាកដប្រជានៃទិន្នន័យនៃការវិភាគសំណាកគំរូ មានន័យថាវា មានភាពច្បាស់លាស់និងពិតប្រាកដ។ គេ សម្រេចបាននូវភាពច្បាស់លាស់ នៅពេលគេ អាចកាត់បន្ថយកំហុសដោយចៃដន្យនានា។ គេ អាចសម្រេចបាននូវភាពប្រាកដប្រជានៃទិន្នន័យបាន នៅពេលគេ អាចលុបបំបាត់កំហុសជាប្រព័ន្ធនានា។

# ឯកសារយោង និងឯកសារណែនាំ


| | |
|---|---|
| BASEL 2012 | Instruction manual on the prosecution of illegal traffic of hazardous wastes or other wastes, Secretariat of the Basel Convention, 2012 |
| Basel Convention | Conference of the Parties, Guidance Elements for Detection, Prevention and Control of Illegal Traffic in Hazardous Wastes (approved by decision VI/15 of the Basel Convention Conference of the Parties, at its sixth meeting) |
| Basel Convention 2019 | The Basel Convention Ban Amendment. Available at: http://www.basel.int/Implementation/LegalMatters/BanAmendment/Overview/tabid/1484/Default.aspx |
| Bell et al 2008 | Stuart Bell, Dinald McGillivray, Ole Pedersen, Environmental Law 2008. |
| Bricknell 2010, | Bricknell, Environmental Crime in Australia, AIC Report 109, Australian Institute of Criminology, 2010. |
| Client Earth 2018 | National EUTR penalties: are they sufficiently effective, proportionate and dissuasive? Client Earth, March 2018 |
| Code for Crown Prosecutors 2018 | Code for Crown Prosecutors, 2018 (England and Wales) available at https://www.cps.gov.uk/sites/default/files/documents/publications/Code-for-Crown-Prosecutors-October-2018.pdf |
| ENPRO 2016 | ENPRO 2016 Manual on prosecuting environmental crime in the Baltic sea region, 2016 |
| Environmental Agency UK , 2016 | Environmental Agency UK , 2016 Offence response Options, 2016 |
| EUNOMIA, ESAET 2017 | EUNOMIA, ESAET (2017), "Rethinking Waste Crime", Available at: http://www.esauk.org/application/files/7515/3589/6448/20170502_Rethinking_Waste_Crime.pdf |
| Europol 2013 | Threat assessment 2013 Environmental crime in the EU. Available at: https://www.europol.europa.eu/sites/default/files/documents/4aenvironmental_crime_threatassessment_2013_-_public_version.pdf |
| Government United Kingdom, 2019. | Policy paper Waste offences. https://www.gov.uk/government/publications/offence-response-options-environment-agency/waste-offences#transfrontier-shipment-of-waste-regulations-2007-tfs |

| | |
|---|---|
| Government Netherlands, 2019. | Areas of law Dutch Court System https://www.government.nl/topics/administration-of-justice-and-dispute-settlement/the-dutch-court-system |
| IMPEL Secretariat 2012 | Toolkit on E-waste Inspection and Enforcement |
| INTERPOL 2006 | Interpol Pollution Crimes Working Group, *Assessing the Links between Organised Crime and Pollution Crimes*, 2006 http://www.interpol.int/Public/EnvironmentalCrime/Pollution/organizedCrime.pdf. |
| INTERPOL 2007 | Advocacy Memorandum, Arguments for Prosecutors of Environmental Crimes, Interpol Pollution Crimes Working Group, Penalties Project, 5 June 2007, available at www.interpol.int/public/EnvironmentalCrime/Pollution/issues/ArgumentsProsecutorsEC.pdf. |
| INTERPOL 2018 | Project Sheet on ISTs, available at: https://www.interpol.int/en/content/download/632/file/IST_ProjectSheet_2018-01_EN_LR.pdf |
| OECD 2003 | Definition Environmental Externalities. Available at: https://stats.oecd.org/glossary/detail.asp?ID=824 |
| UNEP 2005 | Judicial handbook on Environmental Law |
| UNEP 2012 | Instruction manual on the prosecution of illegal traffic of hazardous wastes or other wastes |
| UNEP 2014 | Judicial Training Modules on Environmental Law |
| UNEP 2014 | Guide to good practices from Africa and Asia on enforcement of environmental law arose from an Africa-Asia Expert Meeting on Enforcement of Environmental Law, held in Beijing, China, 19-22 May 2014, and a Peer Review Meeting, held in Nairobi, Kenya, 13-14 August 2014. |
| UNEP 2015 | Enforcement Handbook on Controlling Illegal Shipments of Chemicals and Waste – For Asia Enforcement Officers, https://wedocs.unep.org/bitstream/handle/20.500.11822/9764/-Enforcement_Handbook_on_Controlling_Illegal_Shipments_of_Chemicals_and_Waste_-_For_Asia_Enforcement_Officers-2015Enforcement-handbook-controlling-ill.pdf?sequence=3&amp%3BisAllowed= |
| UNEP 2018 | *The State of Knowledge of Crimes that have Serious Impacts on the Environment*, United Nations Environment Programme, 2018. |

| | |
|---|---|
| UNEP 2019 | Environmental Rule of Law, First Global Report, United Nations Environment Programme, 2019 |
| UNEP/INTERPOL 2014 | Nellemann, C, Henriksen, R., Raxter, P., Ash, N., and Mrema, E. (Eds). 2014. *The Environmental Crime Crisis, Threats to Sustainable Development from Illegal Exploitation and Trade in Wildlife and Forest Resources*, A UNEP Rapid Response Assessment. United Nations Environment Programme and GRID-Arendal, www.grida.now |
| UNEP/INTERPOL 2016 | Nellemann, C. (Editor in Chief); Henriksen, R., Kreilhuber, A., Stewart, D., Kotsovou, M., Raxter, P., Mrema, E., and Barrat, S. (Eds). 2016. *The Rise of Environmental Crime – A Growing Threat to Natural Resources Peace, Development and Security*. A UNEP and INTERPOL Rapid Response Assessment. United Nations Environment Programme and RHIPTO Rapid Response–Norwegian Center for Global Analyses, www.rhipto.org Situ and Emmons 2000 Situ, Y., Emmons, D. 2000 "Environmental Crime: The Criminal Justice System's Role in Protecting the Environment" (California: Sage, 2000), 3. |